**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈកម្មការមូលបត្រកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៥ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៥

តាក់តែងឡើងដោយ

និស្សិតឈ្មោះ **លោក .ឆូ រិទ្ធី**

សាស្ត្រាចារ្យណែនាំ

**លោកស្រី ប៊ួយ ធីតា**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ១៥

ឆ្នាំចូលសិក្សា ២០១១

ឆ្នាំសរសេរសារណា ២០១៥

# មាតិកា

**បញ្ជីអក្សរកាត់** ........ I

**បញ្ជីពាក្យបច្ចេកទេស** ........ II

**សេចក្តីផ្តើម** ........ ១

## ជំពូកទី ១

## ប្រវត្តិនៃការបង្កើត និង រចនាសម្ព័ន្ធរបស់គណៈកម្មការមូលបត្រកម្ពុជា

**ផ្នែកទី ១ ប្រវត្តិ** ........ ៣

កថាខណ្ឌទី១ ការកកើតដំបូងរបស់គណៈកម្មការមូលបត្រ ........ ៣

កថាខណ្ឌទី២ លំហូរចូល នៃការកកើតរបស់គណៈកម្មការមូលបត្រនៅកម្ពុជា ........ ៤

**ផ្នែកទី ២ រចនាសម្ព័ន្ធថ្នាក់ដឹកនាំគណៈកម្មការមូលបត្រកម្ពុជា** ........ ៦

កថាខណ្ឌទី ១ សមាសភាពរបស់គណៈកម្មការមូលបត្រកម្ពុជា ........ ៦

កថាខណ្ឌទី ២ អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ........ ៨

កថាខណ្ឌទី ៣ ដំណើរការរបស់គណៈកម្មការមូលបត្រកម្ពុជា ........ ៩

**ផ្នែកទី ៣ រចនាសម្ព័ន្ធកំរិតបច្ចេកទេស និង អង្គភាពរបស់ គ.ម.ក** ........ ១១

កថាខណ្ឌទី១ នាយកដ្ឋានជំនាញ ........ ១១

ក. នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ........ ១១

ខ. នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ ........ ១២

គ. នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ........ ១២

ឃ.នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ ........ ១២

ង. នាយកដ្ឋានកិច្ចការគតិយុត្ត ........ ១៣

ច. នាយកដ្ឋានស្រាវជ្រាវបណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និង ទំនាក់ទំនងអន្តរជាតិ ........ ១៣

កថាខណ្ឌទី ២ អង្គភាពសវនកម្មផ្ទៃក្នុងនៃ គ.ម.ក ........ ១៤

## ជំពូកទី ២

## តួនាទី និង ភារកិច្ចរបស់គណៈកម្មការមូលបត្រកម្ពុជា

**ផ្នែកទី ១ តួនាទី និង ភារកិច្ចជាក្រុមប្រឹក្សា** ........ ១៦

កថាខណ្ឌទី ១ តួនាទី និង ភារកិច្ចជារួម ........ ១៦

ក.អាណាព្យាបាលលើវិស័យមូលបត្រ ........ ១៧

ខ. ជានិយ័តករក្នុងវិស័យមូលបត្រ ........ ១៩

គ. តួនាទីជាមន្ត្រីនគរបាលយុត្តិធម៌ ............ ២០
កថាខណ្ឌទី២ តួនាទីជាប្រធាន និង គ្រប់គ្រងការងាររបស់ គ.ម.ក ............ ២១
ក. អគ្គនាយក ............ ២១
ខ.សិទ្ធិអំណាចរបស់អគ្គនាយក ............ ២៣
**ផ្នែកទី ២ តួនាទី និង ភារកិច្ចកំរិតជំនាញរបស់ គ.ម.ក** ............ ២៥
កថាខណ្ឌទី ១ នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ............ ២៥
កថាខណ្ឌទី២. នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និង ទំនាក់ទំនងអន្តរជាតិ ............ ២៦
កថាខណ្ឌទី ៣ នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ ............ ២៧
កថាខណ្ឌទី ៤.នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ............ ២៨
កថាខណ្ឌទី ៥. នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ ............ ២៩
កថាខណ្ឌទី ៦. នាយកដ្ឋានកិច្ចការគតិយុត្ត ............ ៣១
**ផ្នែកទី៣ អង្គភាពសវនកម្មផ្ទៃក្នុងរបស់ គ.ម.ក** ............ ៣២
កថាខណ្ឌទី ១. ការិយាល័យសនវកម្មទី ១ ............ ៣៤
កថាខណ្ឌទី ២. ការិយាល័យសនវកម្មទី ២ ............ ៣៧

## ជំពូកទី ៣
## មន្ត្រី និង ធនធាន ព្រមទាំងការអភិវឌ្ឍន៍របស់ គ.ម.ក

**ផ្នែកទី ១ មន្ត្រី** ............ ៤០
កថាខណ្ឌទី ១មន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ ............ ៤០
កថាខណ្ឌទី ២ មន្ត្រីលក្ខន្តិកៈរបស់ គ.ម.ក ............ ៤២
**ផ្នែកទី ២ ប្រភពធនធាន និង ថវិការបស់ គ.ម.ក** ............ ៤៤
កថាខណ្ឌទី ១ ថវិកាជាតិ ............ ៤៤
កថាខណ្ឌទី ២ ថវិកាពីប្រភពផ្សេងៗ ............ ៤៥
**ផ្នែកទី ៣ សមិទ្ធិផលសម្រេចបានរបស់ គ.ម.ក** ............ ៤៦
កថាខណ្ឌទី ១ ការកសាងហេដ្ឋារចនាសម្ព័ន្ធបទដ្ឋានគតិយុត្ត ............ ៤៦
កថាខណ្ឌទី ២ការផ្តល់អាជ្ញាប័ណ្ណ ការទទួលស្គាល់ និង ការអនុញ្ញាត ............ ៤៧
កថាខណ្ឌទី ៣ការដាក់ឲ្យដំណើរការទីផ្សារមូលបត្រកម្ពុជា ............ ៤៩
**ផ្នែកទី ៤ ទិសដៅការងាររបស់ គណៈកម្មការមូលបត្រកម្ពុជា** ............ ៥១
កថាខណ្ឌទី ១ ការបន្តរការកសាងហេដ្ឋារចនាសម្ព័ន្ធគតិយុត្ត ............ ៥១
កថាខណ្ឌទី ២ ការពង្រឹងសមត្ថភាពស្ថាប័ន និង មន្ត្រីជំនាញរបស់ គ.ម.ក ............ ៥១
កថាខណ្ឌទី ៣ ការពង្រឹងការអនុវត្តច្បាប់ និង នីតិកម្ម ............ ៥២

កថាខណ្ឌទី ៤ ការរៀបចំយន្តការដោះស្រាយវិវាទនៅក្នុងវិស័យមូលបត្រ ..................... ៥២
កថាខណ្ឌទី ៥ ការបណ្តុះបណ្តាល ការផ្សព្វផ្សាយ និងទំនាក់ទំនងអន្តរជាតិ .................. ៥៣
**សេចក្តីសន្និដ្ឋាន** .............................................................................................. ៥៥
**អនុសាសន៍**....................................................................................................... ៥៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

- **គ.ម.ក** : គណៈកម្មការមូលបត្រកម្ពុជា
- SECC: Securities and Exchange Commission of Cambodia
- CSX: Cambodia Securities Exchange
- IPO: Initial Public Offering
- SM: Secondary Market
- ADB: Asian Development Bank
- PLC: Public Limited Company
- PE: Permitted Entity

# បញ្ជីពាក្យបច្ចេកទេស

**-មូលបត្រ** ( សន្ទានុក្រមរដ្ឋប្បវេណី) គឺជាបណ្ណដែលតំណាងឲ្យសិទ្ធិលើកម្មសិទ្ធិរបស់ម្ចាស់បណ្ណទៅលើក្រុមហ៊ុន ( បណ្ណហ៊ុន ) តំណាងឲ្យសិទ្ធិទំនាក់ទំនងផ្នែកឥណទេយ្យរវាងម្ចាស់បណ្ណនោះ និងក្រុមហ៊ុន ឬរដ្ឋាភិបាល(ឧ. បណ្ណរតនាគារ) ឬតំណាងឲ្យសិទ្ធិផ្សេងៗទៀតទៅម្ចាស់បណ្ណនោះ ។ ចំណែកឯ ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន មូលបត្រ គឺសំដៅដល់មូលបត្រដែលបានបោះផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលផ្សេងទៀត ដែលត្រូវបានអនុញ្ញាតឲ្យបោះផ្សាយលក់មូលបត្រជាសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមច្បាប់នេះ ។

**-ទីផ្សារមូលបត្រ** (Securities Market) សំដៅដល់ទីផ្សារ ឬទីកន្លែងជួញដូរមូលបត្រ ឬប្រព័ន្ធដែលផ្តល់មធ្យោបាយនៃការធ្វើសំណើរលក់ ផ្ទេរ ឬស្នើការទិញ-លក់មូលបត្រ ។

-ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត (Public Limited Company) សំដៅដល់ក្រុមហ៊ុនដែលបង្កើតឡើង និងចុះបញ្ជីតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក្នុងគោលបំណងបោះផ្សាយលក់មូលបត្រជាសាធារណៈ ។

**-នីតិបុគ្គលប្រតិស្រុត** (Permitted Entity) សំដៅដល់នីតិបុគ្គលដែលត្រូវបានអនុញ្ញាតឲ្យបោះផ្សាយ និងធ្វើសំណើលក់មូលបត្រជាសាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិផ្សេងទៀត ។ នីតិបុគ្គលនេះ មិនមែនជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលត្រូវបានបង្កើតឡើងនៅ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**-ហិរញ្ញប្បទាន** (Financing) សំដៅដល់ការផ្តល់ប្រាក់កចម្ចី ។

**-ប្រតិបត្តិកររក្សាទុកមូលបត្រ** (Securities Depository) បុគ្គលមួយយល់ព្រមជាមួយបុគ្គលមួយផ្សេងទៀត ដែលជាអតិថិជនរបស់ខ្លួនថា ផ្តល់សេវាកម្មដូចខាងក្រោមនេះ ទោះបីជាអតិថិជននោះធ្វើសកម្មភាពក្នុងនាមខ្លួនឯង ឬធ្វើសកម្មភាពក្នុងនាមបុគ្គលផ្សេងទៀតក៏ដោយ: ក- កាន់កាប់ចុះបញ្ជី សិទ្ធិស្របច្បាប់លើមូលបត្រ ឬឧបករណ៍ហិរញ្ញវត្ថុដទៃទៀត ក្នុងនាមអតិថិជន ឬបុគ្គលផ្សេងទៀត ដែលអតិថិជនតែងតាំង ។ ខ- ទទួលរក្សាទុកនូវមូលបត្រ ឬឧបករណ៍ហិរញ្ញវត្ថុដទៃទៀត ទោះបីមានរូបភាពជាវិញ្ញាបនបត្រកម្មសិទ្ធិ ឬជាទម្រង់អរូបីក្តី ដោយស្របទៅតាមវិធានប្រតិបត្តការរក្សាទុកមូលបត្រក្នុងនាមអតិថិជន ឬ បុគ្គលផ្សេងទៀត ដែលអតិថិជនតែងតាំង ។ គ-ផ្តល់សេវាកម្ម

និងលក្ខណៈងាយស្រួលផ្សេងៗទៀត ដែលអតិថិជនទិញ និងការផ្តល់សេវាកម្ម ដូចមានចែងក្នុងកថាខណ្ឌ (ក) និង(ខ) ។

**-ប្រព័ន្ធប្រតិបត្តិការជាត់ទាត់ និងទូទាត់មូលបត្រ** (Securities Clearance and Settlement Facility) គឺសំដៅដល់បុគ្គលដែលផ្តល់នូវប្រព័ន្ធលទ្ធភាពដល់ភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្របំពេញកាតព្វកិច្ចខ្លួនទៅវិញទៅមក ដោយការផ្ទៀងផ្ទាត់ប្រតិបត្តិការឲ្យបានច្បាស់លាស់ និងធានាឲ្យមានការទូទាត់ថ្លៃជូនអ្នកលក់ ដែលជាថ្នូរនឹងការផ្ទេរកម្មសិទ្ធិមូលបត្រទៅឲ្យអ្នកទិញ ។

**-ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរិវេទីវ** (Derivative Instrument) គឺជាកិច្ចសន្យាដែលផ្តល់សិទ្ធិ ឬកាតព្វកិច្ចនៃមូលបត្រដើមទៅឲ្យបុគ្គលណាមួយ ដោយរាប់បញ្ចូលទាំងសិទ្ធិ ឬកាតព្វកិច្ចទិញ លក់ ឬ ដាក់ពាក្យសុំទិញមូលបត្រក្នុងពេលអនាគត ដោយមិនគិតថា បុគ្គលនេះមានបំណងប្រើសិទ្ធិ ឬមិនប្រើសិទ្ធិនេះក៏ដោយ ។

**-អសាធនីយ** (Insolvent) សំដៅដល់ការមិនមានប្រាក់គ្រប់គ្រាន់ សម្រាប់ទូទាត់សងបំណុលដែលជំពាក់គេ ។

**-សញ្ច័យ** (Saving) ការសន្សំ ។

**-ពាណិជ្ជករមូលបត្រអញ្ញត្រកម្ម** (Exempt Securities Dealer) បុគ្គលដែលធ្វើអាជីវកម្មមូលបត្រ ដោយមិនចាំបាច់បំពេញលក្ខខណ្ឌតាមលក្ខខណ្ឌនៃច្បាប់នេះ ។ ពាណិជ្ជករមូលបត្រអញ្ញត្រកម្មនេះ នឹងមានចែងដោយអនុក្រឹត្យ ឬប្រកាស ។

**-ប្រតិបត្តិការមូលបត្រអញ្ញត្រកម្ម** (Exempt Securities Transaction) សំដៅដល់ប្រតិបត្តិការមូលបត្រដែលធ្វើដោយបុគ្គលជាក់លាក់ណាមួយ ឬ ដោយបុគ្គលផ្សេងទៀត ដើម្បីចុះឈ្មោះសុំទិញទិញ បោះផ្សាយលក់ ឬ ផ្ទេរមូលបត្រ ដោយមិនចាំបាច់បំពេញតាមលក្ខខណ្ឌនៃច្បាប់ ។

**-អ្នកធ្វើបរិវិសកម្ម** (Subscriber) អ្នកចុះឈ្មោះសុំទិញមូលបត្រនៅពេលក្រុមហ៊ុនធ្វើសំណើលក់មូលបត្រជាសាធារណៈ ។

# អារម្ភកថា

ខ្ញុំបាទស្រាវជ្រាវ និងចងក្រងឯកសារនេះឡើង ក្នុងគោលបំណង ដើម្បីឆ្លើយតបទៅនឹងការចាំបាច់ដែលសាកលវិទ្យាល័យតម្រូវអោយខ្ញុំបាទសរសេរសារណា ឬរបាយការណ៍កម្មសិក្សា ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្រ្ត ឆ្នាំ សិក្សា ២០១១-២០១៥ របស់ខ្ញុំបាទ និងដើម្បីរួមចំណែកបង្កើតនូវឯកសារសម្រាប់ការសិក្សាស្រាវជ្រាវ និងស្វែងយល់សម្រាប់មិត្តអ្នកអាន និងសម្រាប់ទុកជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយៗទៀត។

សារណាដ៏ស្តួចស្តើងស្តីអំពី " **ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មការមូលបត្រកម្ពុជា** " នេះត្រូវបានរៀបចំតាក់តែងឡើង ដោយធ្វើការសិក្សាវិភាគលើសារៈសំខាន់ និងភាពចាំបាច់នៃ គណៈកម្មការមូលបត្រកម្ពុជា នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងពិព័ណ៌នាទៅលើរចនាសម្ព័ន្ធតួនាទីនិងភារកិច្ច និងសម្ទិផលដែលគណៈកម្មការមូលបត្រកម្ពុជាសម្រេចបាន នៅក្នុងនាមជានិយ័តករនៅក្នុងការគ្រប់គ្រងលើវិស័យ មូលបត្រនៅកម្ពុជា ។

ខ្ញុំបាទសង្ឃឹមយ៉ាងមុតមាំថា សារណាមួយនេះនឹងជួយអ្នកអានអោយយល់ដឹងអំពីច្បាប់ និងបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធទៅនឹងអាជ្ញាធរវិស័យមូលបត្រ ព្រមទាំងការអនុវត្តរបស់អាជ្ញាធរនេះនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ប៉ុន្តែ វាក៏អាចនឹងមានការខ្វះខាត ឬខុសឆ្គងលើការសរសេរអត្ថាធិប្បាយ ឬការវិភាគខ្លះៗ ជាក់ជាមិនខានផងដែរ ។ ដូច្នេះ ខ្ញុំបាទរង់ចាំដោយក្តីសោមនស្សរីករាយដើម្បីទទួលនូវមតិរិះគន់កែលំអរពីលោក-លោកស្រីសាស្រ្តាចារ្យ និងមិត្តអ្នកសិក្សាស្រាវជ្រាវទាំងអស់ និងព្រមទាំងប្អូនៗជំនាន់ក្រោយៗទៀត ក្នុងការធ្វើអោយសារណានេះកាន់តែមានលក្ខណៈល្អប្រសើរឡើងថែមទៀត ។

ខ្ញុំបាទសូមប្រសិទ្ធិពរដល់លោក-លោកស្រីសាស្រ្តាចារ្យ និងអ្នកសិក្សាស្រាវជ្រាវទាំងអស់ សូមឲ្យជួបប្រទះតែនឹងសេចក្តីសុខគ្រប់ប្រការ និងសម្រេចបានជោគជ័យគ្រប់ភារកិច្ចទាំងអស់ ។

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ធូ រិទ្ធី** ជានិស្សិតបរិញ្ញាបត្រនីតិសាស្រ្ត ឆ្នាំទី ៤ ជំនាន់ទី ១៥ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច សូមសំដែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅចំពោះអ្នកមានគុណទាំងពីរ គឺលោកឪពុក **ធូ គឹមហ៊ាង** និងអ្នកម្តាយ **ហ៊ោ ស៊ីណេត** ដែលលោកទាំងពីរបានលះបង់អស់កំលាំងកាយ និងកំលាំងចិត្ត ក្នុងការប្រកបមុខរបរមិនថាយប់ ឬថ្ងៃ ដើម្បីផ្តល់ការផ្គត់ផ្គង់ដល់ខ្ញុំបាទអោយបានសិក្សារៀនសូត្រ រហូតដល់រូបខ្ញុំបាទទទួលបានជោគជ័យថ្នាក់បរិញ្ញាបត្រនីតិសាស្រ្ត ជាពិសេសក្នុងកិច្ចការសរសេរសារណាបញ្ចប់ការសិក្សានេះ ។

សូមថ្លែងអំណរគុណដល់ **ឯកឧត្តម សាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង លោកព្រឹទ្ធបុរស និងលោកព្រឹទ្ធបុរសរង ព្រមទាំងលោកគ្រូ-អ្នកគ្រូ** ជាសាស្រ្តាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានផ្តល់នូវពុទ្ធិដ៏ល្អប្រពៃ ជាពិសេសក្នុងមុខជំនាញនីតិសាស្រ្តដល់រូបខ្ញុំបាទ ក៏ដូចជានិស្សិតគ្រប់រូបក្នុងរយៈពេល ៤ ឆ្នាំ កន្លងមកនេះ ។ ជាពិសេស ខ្ញុំបាទសូមថ្លែងអំណរអរគុណដល់លោកស្រីសាស្រ្តាចារ្យ **ប៊ួយ ធីតា** ដែលជាសាស្រ្តាចារ្យដឹកនាំក្នុងកិច្ចការសរសេរសារណានេះ ដោយលោកស្រីសាស្រ្តាចារ្យបានចំណាយពេលវេលាដ៏មានតម្លៃ និងបានផ្តល់ដំបូន្មានល្អៗជួយឲ្យខ្ញុំអាចសម្រេចកិច្ចការនេះ ប្រកបដោយជោគជ័យ ។

សូមថ្លែងអំណរគុណជាអនេកដល់លោក **ឃឹម ឧត្តម** ប្រធានការិយាល័យស៊ើបអង្កេត និងលោក **ណា ពៅបញ្ញារិទ្ធ** ប្រធានការិយាល័យពង្រឹងការអនុវត្តច្បាប់ និងនីតិកម្ម នៃគណៈកម្មការមូលបត្រកម្ពុជា(**គ.ម.ក**)ដែលផ្តល់ជាគំនិត និងឯកសារបច្ចេកទេសចាំបាច់គ្រប់បែបយ៉ាង សម្រាប់ការសរសេរសារណានេះ។

សូមថ្លែងអំណរគុណដល់មិត្តរួមជំនាន់ទាំងអស់ ដែលបានផ្តល់មតិយោបល់ល្អៗ លើកទឹកចិត្តក្នុងការសិក្សារបស់ខ្ញុំ ។

ជាទីបញ្ចប់ ខ្ញុំសូមគោរពជូនពរ ឯកឧត្តម លោក លោកស្រី អ្នកនាងកញ្ញា និងមិត្តអ្នកអានទាំងអស់ សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ ។

# សេចក្តីផ្តើម

ជាការពិតណាស់ វិស័យហិរញ្ញវត្ថុជាកត្តាមួយដ៏សំខាន់នៅក្នុងការជំរុញនូវល្បឿនសេដ្ឋកិច្ចជាតិឲ្យមានការរីកចម្រើន។ ភាពរឹងមាំ និង រស់រវើកនៃវិស័យនេះ បានជួយជម្រុញក្នុងការអភិវឌ្ឍវិស័យឯកជន ព្រមទាំងធានាអោយមានកំណើនសេដ្ឋកិច្ចជាតិមួយប្រកបដោយចីរភាព ។ ដោយមើលឃើញពីគុណសម្បត្តិរបស់វិស័យហិរញ្ញវត្ថុខាងលើនេះហើយ ទើបបានជាប្រទេសដែលអភិវឌ្ឍន៍ និង ប្រទេសដែលកំពុងអភិវឌ្ឍន៍បាននឹងកំពុងមានការយកចិត្តទុកដាក់យ៉ាងខ្លាំង នៅក្នុងការផ្តល់ហិរញ្ញប្បទានច្រើនបែបទៅដល់វិនិយោគិន ដែលក្នុងនោះមានហិរញ្ញប្បទានតាមរយៈធនាគារ ហិរញ្ញប្បទានតាមរយៈធានារ៉ាប់រង និង ហិរញ្ញប្បទានតាមរយៈទីផ្សារមូលបត្រ ។

ចំណែកឯប្រទេសកម្ពុជា ដែលជាប្រទេសដែលពុងអភិវឌ្ឍន៍ក៏បានកំពុងយ៉ាងសស្រាក់សស្រាំផងដែរ នៅក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ តាមរយៈការផ្តល់ហិរញ្ញប្បទាន ដែលមានដូចជាវិស័យធនាគារ វិស័យធានារ៉ាប់រង និង វិស័យដែលរាជរដ្ឋាភិបាលផ្តល់ជាអាទិភាពទៅលើការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុនោះ គឺវិស័យមូលបត្រនេះឯង ក៏ប៉ុន្តែដោយសារតែវិស័យមូលបត្រនេះវា គឺជាវិស័យមួយដែលថ្មីនៅក្នុងការយកមកអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជាកង្វល់មួយផងដែលសម្រាប់រាជរដ្ឋាភិបាលខ្លាចក្រែងមានហានិភ័យកើតឡើង ។ កត្តាទាំងនេះហើយ តម្រូវឲ្យរាជរដ្ឋាភិបាលបានគិតគូពិចារណាយ៉ាងយកចិត្តទុកដាក់ និង មានការទទួលខុសត្រូវខ្ពស់ជាទីបំផុត ដោយបានធ្វើការសិក្សា និង ដកស្រង់បទពិសោធន៍ពីបណ្តាលប្រទេសដែលទទួលបានភាពជោគជ័យលើវិស័យមូលបត្រ នេះទើបធ្វើអោយរាជរដ្ឋាភិបាលសម្រេចចិត្តបង្កើតច្បាប់ និង បទដ្ឋាគតិយុត្ត ព្រមទាំងអាជ្ញាធរគ្រប់គ្រងលើវិស័យនេះជាមុន ដើម្បីធ្វើការអនុវត្តអោយមានប្រសិទ្ធិភាពជាមុនសិន ទើបដាក់ឲ្យដំណើរការទីផ្សារមូលបត្រតាមក្រោយ ។

នៅក្នុងនោះដែរ ក៏មានចម្ងល់មួយបានលើកឡើងថា តើគណៈកម្មការមូលបត្រកម្ពុជា **(គ.ម.ក)** ក្នុងនាមជាអាជ្ញាធរគ្រប់គ្រងនឹងត្រួតពិនិត្យលើវិស័យមូលបត្រនៅកម្ពុជាមានរចនាសម្ព័ន្ធ និងតួនាទីអ្វីខ្លះ ក្នុងការធ្វើឲ្យមានប្រសិទ្ធិភាព និងមានដំណើរការបានល្អចំពោះវិស័យមូលបត្រនេះ ?

ដើម្បីឆ្លើយតបទៅនឹងចម្លើយដែលមានសុក្រឹត្យភាពមួយបាននោះ យើងគួរគប្បីសិក្សាស្វែងយល់អំពីគណៈកម្មការមូលបត្រកម្ពុជាឲ្យបានច្បាស់លាស់ ដោយផ្តោតសំខាន់ទៅលើៈ

១.ជំពូកទី១ ប្រវត្តិនៃការបង្កើត និង រចនាសម្ព័ន្ធរបស់គណៈកម្មការមូលបត្រកម្ពុជា

២.ជំពូកទី ២ តួនាទី និងភារកិច្ចរបស់គណៈកម្មការមូលបត្រកម្ពុជា

៣.ជំពូកទី ៣ មន្ត្រី និងធនធាន ព្រមទាំងការអភិវឌ្ឍរបស់គណៈកម្មការមូលបត្រកម្ពុជា

# ជំពូកទី ១
# ប្រវត្តិនៃការបង្កើត និងរចនាសម្ព័ន្ធរបស់គណៈកម្មការមូលបត្រកម្ពុជា

នៅក្នុងបណ្តាប្រទេសនៅលើពិភពលោក ប្រព័ន្ធវិស័យហិរញ្ញវត្ថុជាវិស័យមួយដែលដើរតួយ៉ាងសំខាន់នៅក្នុងការជម្រុញសេដ្ឋកិច្ចប្រទេសអោយមានការីកចំរើន ដែលនៅក្នុងនោះផងដែរប្រព័ន្ធវិស័យហិរញ្ញវត្ថុ វាបានផ្សារភ្ជាប់ទៅនឹងវិស័យហិរញ្ញប្បទាន ដែលមិនអាចខ្វះបាន ដោយត្រូវមានការចូលរួមយ៉ាងសកម្មរវាងក្រុមហ៊ុនវិនិយោគឯកជន ដើម្បីស្វែងរកនូវប្រភពហិរញ្ញប្បទានតាមរយៈមធ្យោបាយផ្សេងៗ ដែលរដ្ឋនៅក្នុងប្រទេសនោះបានផ្តល់អោយ ដោយមើលឃើញពីភាពចាំបាច់ និងតម្រូវការហិរញ្ញប្បទានយ៉ាងច្រើននេះហើយ ទើបធ្វើអោយប្រទេសមួយចំនួនមានការបង្កើត និងបង្កើននូវប្រភពហិរញ្ញប្បទានសម្រាប់ផ្តល់ភាពងាយស្រួលដល់ក្រុមហ៊ុនវិនិយោគឯកជន ដើម្បីធ្វើការវិនិយោគនៅក្នុងប្រទេស ដោយមុនដំបូងប្រភេទការផ្តល់ហិរញ្ញប្បទាន គឺមានតែតាមរយៈប្រព័ន្ធធនាគារតែប៉ុណ្ណោះ ដែលការផ្តល់នេះវាមានលក្ខណៈមិនគ្រប់គ្រាន់ ទៅដល់តំរូវការរបស់អ្នកវិនិយោគ ហើយការផ្តល់ហិរញ្ញប្បទានតាមរយៈប្រព័ន្ធធនាគារនេះ វាមានរយៈពេលខ្លីចំពោះអ្នកវិនិយោគិន ដែលនេះគឺជាបញ្ហាមួយ បន្ទាប់មកទៀត ប្រភេទហិរញ្ញប្បទានមួយទៀតត្រូវបានបង្កើតឡើងផងដែល គឺហិរញ្ញប្បទានតាមរយៈធានារ៉ាប់រង ប៉ុន្តែការផ្តល់វិស័យហិរញ្ញប្បទានទាំងពីរនេះ នៅតែមិនអាចបំពេញតាមតំរូវការរបស់អ្នកវិនិយោគិនបានទៀត ទើបបណ្តាលឲ្យប្រទេសមួយចំនួនបានងាកមករកនូវការផ្តល់ហិរញ្ញប្បទានមួយប្រភេទទៀត គឺតាមរយៈទីផ្សារមូលបត្រ និងបន្ទាប់មកទៀត ទើបបានបង្កើតអាជ្ញាធរបន្ថែមទៀត ដើម្បីធ្វើការគ្រប់គ្រងទៅលើវិស័យទីផ្សារមូលបត្រនេះ ។ ចំណែកឯប្រទេសកម្ពុជាវិញ ដែលជាប្រទេសកំពុងអភិវឌ្ឍន៍ និងមានភាពក្មេងខ្ចីនៅឡើយ ចំពោះវិស័យមូលបត្រនេះដោយប្រព័ន្ធហិរញ្ញប្បទានក៏នៅមានកម្រិត ហើយចំណែកឯធនធានមនុស្សដែលមានចំណេះដឹងលើវិស័យនេះក៏នៅមានកំរិត ទើបធ្វើអោយប្រទេសកម្ពុជាមិនអាចធ្វើការបង្កើតទីផ្សារមុននឹងការបង្កើតបទដ្ឋានគតិយុត្ត ព្រមទាំងអាជ្ញាធរនៅក្នុងការគ្រប់គ្រងលើវិស័យមូលបត្រនេះបាននៅឡើយ ។

ករណីខាងលើ មានសំនួរបានចោទសួរថា តើការកកើតគណៈកម្មការមូលបត្រកម្ពុជាត្រូវបានបង្កើតនៅពេលណា? ដែលសំនួរខាងក្រោមនេះ នឹងត្រូវបានបកស្រាយនៅក្នុងផ្នែកទី ១ ដែលនិយាយអំពីប្រវត្តិនៃការបង្កើត (**គ.ម.ក**) និង ផ្នែកទី ២ ធ្វើការបកស្រាយអំពីរចនាសម្ព័ន្ធថ្នាក់ដឹកនាំរបស់(**គ.ម.ក**) និង ផ្នែកទី ៣ បកស្រាយអំពីរចនាសម្ព័ន្ធបច្ចេកទេសរបស់(**គ.ម.ក**) ។

## ផ្នែកទី ១ ប្រវត្តិនៃការកកើតឡើងរបស់គណៈកម្មការមូលបត្រនៅកម្ពុជា

ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ មិនមែនជាគោលដៅចុងក្រោយនោះទេ ។ ប៉ុន្តែ គឺជាទិដ្ឋភាពមួយដែលទ្រទ្រង់ការអភិវឌ្ឍសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។ ដូច្នេះ ដើម្បីធ្វើឲ្យកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ វិស័យហិរញ្ញវត្ថុត្រូវតែធ្វើការពង្រីក និង ត្រូវបានប្រើប្រាស់ចំពោះសហគ្រាសធុនតូច និង មធ្យម និង មីក្រូសហគ្រាស ក៏ដូចជាចំពោះសហគ្រាសធំៗ និងសហគ្រាសបរទេសផងដែរ។ កំណែទម្រង់ និង ការកែប្រែមានសារៈសំខាន់ណាស់សម្រាប់កំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ ។ ទន្ទឹមនោះផងដែរ ការពង្រីកវិស័យហិរញ្ញវត្ថុនាំមកនូវហានិភ័យដូច្នេះ ត្រូវមានការពិចារណាយ៉ាងល្អិតល្អន់ទៅលើបទដ្ឋាននៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ដោយត្រូវផ្តោតទៅលើការប្រុងប្រយ័ត្ន ការកាត់បន្ថយហានិភ័យ តម្លាភាពនូវច្បាប់ និងបទប្បញ្ញត្តិ ។ ប៉ុន្តែដោយសារតែបានក្រឡេកមើលទៅលើឆាកអន្តរជាតិវិញឃើញថា ការពង្រីកវិស័យហិរញ្ញវត្ថុតាមរយៈទីផ្សារភាគហ៊ុន ឬ ទីផ្សារមូលបត្រនេះទទួលបាននូវភាពជោគជ័យ និងបានចូលរួមអភិវឌ្ឍន៍យ៉ាងច្រើនទៅដល់សេដ្ឋកិច្ចជាតិ ទើបវាបានជះឥទ្ធិពលមកលើប្រទេសកម្ពុជា ក្នុងការចាប់យកវិស័យនេះមកធ្វើការអនុវត្តនៅក្នុងសេដ្ឋកិច្ចរបស់ខ្លួន ។

### កថាខណ្ឌទី ១ ការកកើតដំបូងរបស់គណៈកម្មការមូលបត្រ

ទីផ្សារភាគហ៊ុន ឬ ទីផ្សារមូលបត្រមានប្រវត្តិតាំងពីយូរណាស់មកហើយ ដែលវាកើតឡើងពីសកម្មភាពនៃការដោះដូរលើកដំបូងទៅលើផលិតផលកសិកម្ម និងផលិផលផ្សេងៗទៀត។ ទីផ្សារភាគហ៊ុនកើតឡើងមុនដំបូងមានឈ្មោះថា ទីផ្សារភាគហ៊ុនអាំស្ទែដាំ ដែលត្រូវបានបង្កើតឡើងដោយក្រុមហ៊ុនមួយឈ្មោះថា The Dutch East India Company នៅភាគខាងជើងនៃប្រទេសឥណ្ឌានៅក្នុងឆ្នាំ ១៦០៨ ហើយឧបករណ៍ហិរញ្ញវត្ថុដែលធ្វើការជួញដូរនៅក្នុងទីផ្សារភាគហ៊ុនអាំស្ទែដាំនេះលើកដំបូង គឺមានតែប័ណ្ណភាគហ៊ុន (share) ដោយអាស្រ័យទៅនឹងភាគហ៊ុន ឬ ភាគរយនៃផលចំណេញរបស់ក្រុមហ៊ុន The Dutch East India Company[៩] ។ បន្ទាប់មកទៀត នៅឆ្នាំ ១៧៩២ ទីផ្សារភាគហ៊ុននៅក្នុងទីក្រុងញូយ៉កក៏បានបង្កើត គឺនៅពេលដែលពាណិជ្ជករ និងអន្តរការីជើងសារចំនួន ២៤នាក់ បានសម្រេចចិត្តយកកំរៃជើងសារ នៅពេលដែលដើរតួជាភ្នាក់ងារសម្រាប់មនុស្សផ្សេងៗទៀតក្នុងការធ្វើជំនួញ ហើយដើម្បីផ្តល់នូវការពេញចិត្តទៅឲ្យគ្នាទៅវិញទៅមកក្នុងការចរចាររបស់ពួកគេ ។ ម្យ៉ាងទៀត ដោយសារលក្ខណៈនៃការបង្កើតទីផ្សារមូលបត្ររបស់ប្រទេសនីមួយៗនៅលើពិភពលោក មានភាពខុសប្លែកពីគ្នា ដូច្នេះការបង្កើតនូវច្បាប់ និងគណៈកម្មការមូលបត្រ ឬ អាជ្ញាធរមូលបត្រ ក៏មានលក្ខណៈខុសគ្នាផងដែរ ។ ចំណែកឯ គណៈកម្មការមូលបត្រអាមេរិក ត្រូវបានបង្កើតឡើងនៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ១៩៣៤ ដើម្បីគ្រប់គ្រងពាណិជ្ជកម្មភាគហ៊ុនមូលបត្រ

[៩] https://en.wikipedia.org/wiki/Stock_exchange

បំណុល និងមូលបត្រផ្សេងទៀត គណៈកម្មការមូលបត្រនេះត្រូវបានបង្កើតឡើង ដើម្បីការពារអ្នកវិនិយោគ ទប់ស្កាត់ការលួចបន្លំមូលបត្រ និងការធ្វើអាជីវកម្មមូលបត្រខុសច្បាប់ ព្រមទាំងធានាបាននូវការយកទុកចិត្តពីអ្នកវិនិយោគ វាក៏បានធានាថា ប្រតិបត្តិការមូលបត្រទាំងអស់ ដែលត្រូវបានដាក់ក្នុងរបៀបយុត្តិធម៌ និងសណ្តាប់ធ្នាប់មួយ[២] ។

**កថាខណ្ឌទី ២ លំហូរចូលនៃការកកើតរបស់គណៈកម្មការមូលបត្រនៅកម្ពុជា**

ភាពរីកចម្រើននៃវិស័យមូលបត្រនៅលើសកលលោក វាបានធ្វើឲ្យជះឥទ្ធិពលយ៉ាងខ្លាំងទៅលើប្រទេសដែលកំពុងអភិវឌ្ឍន៍ រួមទាំងប្រទេសកម្ពុជាផង ដែលជាហេតុធ្វើអោយរាជរដ្ឋាភិបាលកម្ពុជាមានការចាប់អាម្មណ៍ទៅលើវិស័យនេះ ទើបនៅក្នុងឆ្នាំ ១៩៩៥ រាជរដ្ឋាភិបាលកម្ពុជាមានគម្រោងនៅក្នុងការបង្កើតទីផ្សារមូលបត្រ ដើម្បីធ្វើការអភិវឌ្ឍវិស័យហិរញ្ញប្បទាននៅកម្ពុជា ក្រៅពីហិរញ្ញប្បទានតាមរយៈធនាគារ និងតាមរយៈធានារ៉ាប់រង ក៏ប៉ុន្តែគម្រោងនេះត្រូវបានផ្អាកទៅវិញ ដោយសារតែនៅពេលនោះប្រព័ន្ធធនាគារនៅក្នុងប្រទេសរបស់យើងមិនទាន់មានការីកចម្រើននៅឡើយ ដែលជាបញ្ហាមួយនៅក្នុងការធ្វើឲ្យគម្រោងនៃការអភិវឌ្ឍវិស័យមូលបត្រនៅកម្ពុជាមានភាពជាប់គាំង ។ ប៉ុន្តែបញ្ហាទាំងនេះមិនបានធ្វើឲ្យរាជរដ្ឋាភិបាលបោះបង់ចោលនោះទេ គឺនៅតែចាត់ទុកថាវាជាគម្រោងនៃការអភិវឌ្ឍវិស័យមូលបត្រនេះជាវិស័យអាទិភាពទៀតផង[៣] ។ ក្រោយមកទៀត ដោយសារតែប្រទេសកម្ពុជាពឹងផ្អែកប្រកាន់យក និងអនុវត្តនូវប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរីនោះ[៤] ជាចលករធ្វើអោយរាជរដ្ឋាភិបាលបានដាក់ចេញនូវផែនការ និងចក្ខុវិស័យអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០១-២០១០ ដែលធ្វើឲ្យប្រព័ន្ធហិរញ្ញវត្ថុនៅក្នុងប្រទេសមានការរីកចម្រើន ជាពិសេស គឺវិស័យធនាគារមានការកើនឡើងយ៉ាងឆាប់រហ័ស ។ បន្ទាប់មកទៀត រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមួយដ៏រឹងមាំ ដោយផ្អែកលើយន្តការទីផ្សារ ដើម្បីទ្រទ្រង់ការកេណ្ឌប្រមូលធនធាន និង កំណើនសេដ្ឋកិច្ចទូលំទូលាយប្រកបដោយចីរភាព ដោយរាជរដ្ឋាភិបាលបានធ្វើបច្ចុប្បន្នកម្មចក្ខុវិស័យអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០១-២០១០ ទៅជាយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០៦-២០១៥[៥] ។ ដោយផ្អែកលើយុទ្ធសាស្ត្រនេះ ដើម្បីគៀងគរនូវមូលនិធិដែលមិនបានប្រើប្រាស់ពីសាធារណជន ស្ថាប័នធនាគារ និងហិរញ្ញវត្ថុជាច្រើនត្រូវបានបង្កើតឡើង ដើម្បីសម្រួលដល់ប្រតិបត្តិការនេះ ដូចជា ធនាគារ ក្រុមហ៊ុនធានារ៉ាប់រង និង មីក្រូហិរញ្ញវត្ថុជាដើម ។

[២] https://en.wikipedia.org/wiki/U.S._Securities_and_Exchange_Commission

[៣] ប្រសាសសន៍របស់ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា ។

[៤] មាត្រា ៥៦ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

[៥] យុត្តិសាស្ត្រចតុកោណ ដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាល ។

ដើម្បីអូសទាញនូវអ្នកវិនិយោគ និងដោយសារតែប្រតិបត្តិការហិរញ្ញវត្ថុទាំងអស់នេះមិនទាន់បំពេញបាននូវតំរូវការសាច់ប្រាក់ រាជរដ្ឋាភិបាលកម្ពុជាសហការរួមជាមួយនឹងប្រទេសកូរ៉េ មានគម្រោងនឹងបង្កើតទីផ្សារមូលបត្រនៅចុងឆ្នាំ ២០០៩ ប៉ុន្តែដោយសារតែនៅក្នុងឆ្នាំ ២០០៨ សេដ្ឋកិច្ចនៅលើពិភពលោកបានជួបវិបត្តិ ដែលជាពេលមួយដ៏ល្អផងដែរសម្រាប់ប្រទេសកម្ពុជា នៅក្នុងការសិក្សាពីបទពិសោធន៍នៃវិបត្តិនេះ ទើបត្រូវធ្វើឲ្យគម្រោងនេះត្រូវបានពន្យារពេលជាបណ្តោះអាសន្ន ។ ដើម្បីឲ្យទីផ្សារនេះប្រព្រឹត្តទៅដោយរលូន ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗត្រូវបានបង្កើតឡើងក្នុងការផ្តល់ទំនុកចិត្តដល់អ្នកវិនិយោគដូចជា ច្បាប់ស្តីពីធនាគារ និងហិរញ្ញវត្ថុ ឆ្នាំ ១៩៩៧ , ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម , ក្រមរដ្ឋប្បវេណី ច្បាប់ស្តីពី (មូលបត្ររដ្ឋ) ត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស / រកម/ ០១០៧/ ០០១/ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៧ ដែលច្បាប់នេះអនុញ្ញាតអោយរាជរដ្ឋាភិបាលដែលជាតំណាងឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចធ្វើការបោះផ្សាយលក់មូលបត្ររដ្ឋជាសាធារណៈទៅតាមនីតិវិធីច្បាប់ ដើម្បីគៀងគរមូលធនសម្រាប់យកទៅធ្វើហិរញ្ញប្បទានគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានា ឬ ក្នុងវិស័យគន្លឹះណាមួយ ដែលគម្រោងទាំងនេះផ្តល់មកវិញនូវផលចំនូលដោយផ្ទាល់ ឬ ដោយប្រយោលដល់សេដ្ឋកិច្ចជាតិ និងសង្គម ។ ច្បាប់នេះផ្តល់នូវមូលដ្ឋានសម្រាប់ការអភិវឌ្ឍមូលបត្ររដ្ឋរយៈពេលខ្លី ប៉ុន្តែនឹងទាមទារឲ្យមានវិធានការសំខាន់ៗ ដែលត្រូវអនុវត្តមុនពេលមូលបត្រនេះអាចត្រូវបានបោះផ្សាយប្រកបដោយជោគជ័យ ។ ម្យ៉ាងវិញទៀត ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលត្រូវបានអនុម័ត និងប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស /រកម / ១០០៧ / ០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ ២០០៧ ដែលច្បាប់នេះ មានគោលដៅគ្រប់គ្រងប្រតិបត្តករទីផ្សារមូលបត្រ ប្រតិបត្តិករផាត់ទាត់ និង ទូទាត់ ប្រតិបត្តិកររក្សាទុកមូលបត្រ និងប្រតិបត្តិករដ៏ទៃទៀតនៅក្នុងទីផ្សារមូលបត្រ ដែលធ្វើការជួញដូរ ឬ ផ្តល់សេវាកម្មមូលបត្រ ព្រមទាំងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកំរិត ឬ នីតិបុគ្គលប្រតិស្រុត ដែលបោះផ្សាយលក់មូលបត្រ ។ ម្យ៉ាងទៀត នៅក្នុងច្បាប់នេះផងដែរក៏បានបង្កើតនូវអាជ្ញាធរមួយសម្រាប់ធ្វើការគ្រប់គ្រង និងត្រួតពិនិត្យនូវដំណើរការវិវត្តនានានៃវិស័យមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ[៦] ។ លើសពីនេះទៅទៀត ច្បាប់នេះរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គមតាមរយៈការគៀងគរមូលនិធិពីសាធារណជន ឬវិនិយោគិនមូលបត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់ការវិ-និយោគ ។ ក្នុងទិសដៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុអោយកាន់តែស៊ីជម្រៅ ជាពិសេសសំដៅដល់ការ

[៦] មាត្រា ៥ ច្បាប់ស្តីពីការបោះផ្សាយ និង ជួញដូរមូលបត្រមហាជន

ផ្តល់នូវទំនុកចិត្តពីសំណាក់វិនិយោគជាតិ និងអន្តរជាតិឲ្យមកធ្វើការវិនិយោគនៅក្នុងប្រទេសកម្ពុជាកាន់តែច្រើនឡើង នោះការគាំពារនឹងការផ្តល់នូវការលើកទឹកចិត្ត គឺត្រូវតែផ្តល់ទៅដល់អ្នកវិនិយោគពីព្រោះថា គោលដៅចំបងសម្រាប់អ្នកវិនិយោគ គឺការទទួលបាននូវផលចំណេញមកវិញពីការវិនិយោគ ។ ដូច្នេះហើយ ការគាំពារ និងផ្តល់អត្ថប្រយោជន៍សម្រាប់អ្នកវិនិយោគត្រូវតែមានកំណត់នៅក្នុងបទប្បញ្ញត្តិ ហើយអាជ្ញាធរជាអ្នកអនុវត្ត និងជាអ្នកដើរតួយ៉ាងសំខាន់ ។ ម្យ៉ាងទៀត ដើម្បីឲ្យបណ្តាវិនិយោគជាតិ និងអន្តរជាតិ ព្រមទាំងសាធារណជនមានការយល់ដឹងអំពីដំណើរការរបស់អាជ្ញាធរ ដែលជាអ្នកការពារនូវផលប្រយោជន៍ចំពោះអ្នកវិនិយោគឲ្យកាត់តែជ្រួតជ្រាបនោះ រាជរដ្ឋាភិបាលក៏បានចេញអនុក្រឹត្យមួយទៀតបន្ថែមពីច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលបានបង្កើតគណៈកម្មការមូលបត្រនេះឡើង ដោយអនុក្រឹត្យនោះស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា ដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលនៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៨ ហើយបន្ទាប់មកទៀត គណៈកម្មការមូលបត្រកម្ពុជានេះក៏ត្រូវបានដាក់សម្ពោធជាផ្លូវការ ក្រោមអធិបតីភាពរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជានៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៩[៧] ។

## ផ្នែកទី ២ រចនាសម្ព័ន្ធថ្នាក់ដឹកនាំគណៈកម្មការមូលបត្រកម្ពុជា

### កថាខណ្ឌទី ១ សមាសភាពរបស់គណៈកម្មការមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជា ហៅកាត់ថា **គ.ម.ក** ជានីតិបុគ្គលដែលបង្កើតឡើងដោយច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យលើប្រតិបត្តិការពាក់ព័ន្ធវិស័យមូលបត្រ ។ ដែលនៅក្នុងការដឹកនាំនោះ គណៈកម្មការមូលបត្រកម្ពុជាមានប្រធាន ០១ រូប គឺជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមានសមាជិកចំនួន ០៨ រូបទៀត ដែលត្រូវតែងតាំងដោយអនុក្រឹត្យ ហើយសមាជិកទាំង ០៨ រូបនោះ មានអាណត្តិចំនួន ០៥ ឆ្នាំ នៅក្នុងរយៈពេលនៃការបំពេញមុខងាររបស់ខ្លួន សមាជិកទាំងអស់អាចត្រូវបានដកហូត ឬ ផ្លាស់ប្តូរភារកិច្ចរបស់ខ្លួនបានទៅតាមការសម្រេចរបស់ប្រធានគណៈកម្មការមូលបត្រកម្ពុជា ហើយសមាជិក **គ.ម.ក** ត្រូវបានតែងតាំងសារជាថ្មីទៀតបាន តាមសំណើរបស់ប្រធាន **គ.ម.ក** នៅពេលផុតអាណត្តិ[៨] ។ ដែលសមាជិកទាំង ០៨ រូបនោះមានសមាសភាពដូចជា[៩]៖

[៧] http://www.secc.gov.kh/khmer/

[៨] មាត្រា ៥ នៃច្បាប់ស្តីពីការបោះផ្សាយ និង ជួញដូរមូលបត្រមហាជន

[៩] មាត្រា៦ នៃច្បាប់ស្តីពីការបោះផ្សាយ និង ជួញដូរមូលបត្រមហាជន

១- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១ (មួយ) រូប

២-តំណាងធនាគារជាតិនៃកម្ពុជា ០១ (មួយ) រូប

៣-តំណាងក្រសួងពាណិជ្ជកម្ម ០១ (មួយ) រូប

៤-តំណាងក្រសួងយុត្តិធម៌ ០១ (មួយ) រូប

៥-តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ០១ (មួយ) រូប

៦-អគ្គនាយក **គ.ម.ក** ០១ (មួយ) រូប

៧-អ្នកជំនាញដែលមានបទពិសោធន៍វិស័យមូលបត្រ ០២ (ពីរ) រូប ដែលមានស្ថានភាពអព្យាក្រឹត្យ ព្រមទាំងជ្រើសរើស និងស្នើឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ សមាជិកនៃ **គ.ម.ក** ដែលជាអ្នកជំនាញ ត្រូវមានសញ្ញាបត្រថ្នាក់ក្រោយឧត្តមសិក្សា មានសមត្ថភាព និងលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងសមស្របក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ព្រមទាំងមានបទពិសោធន៍មួយ ឬ ច្រើនផ្នែក ដូចជាពាណិជ្ជកម្មគ្រប់គ្រងក្រុមហ៊ុនទីផ្សារមូលបត្រ ច្បាប់ សេដ្ឋកិច្ច គណនេយ្យ និងផ្នែកផ្សេងទៀតតាមតម្រូវការជាក់ស្តែង ។ ម្យ៉ាងវិញទៀត ចាប់តាំពីការបង្កើតគណៈកម្មការមូលបត្រកម្ពុជារហូតមកដល់ពេលបច្ចុប្បន្ននេះ គឺសមាសភាពប្រធាន និងសមាជិកមាន ០២ អាណត្តិរួចមកហើយ ។

***<u>អាណត្តិទី ១</u>*** ចាប់ពីឆ្នាំ ២០០៩ ដល់ ឆ្នាំ ២០១៣ គណៈកម្មការមូលបត្រកម្ពុជា ដែលមានឯកឧត្តមឧបកនាយករដ្ឋមន្ត្រី **គាត់ ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាប្រធាន និងមានសមាជិកចំនួន ០៨ រូប ដែលមានអាណត្តិរយៈពេល ០៥ឆ្នាំ ដែលក្នុងនោះសមាជិកតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមួយរូប ដែលតំណាងដោយឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងធនាគារជាតិនៃកម្ពុជាមួយរូប ដែលតំណាងដោយលោកជំទាវ **នាវ ច័ន្ទថាណា** ទេសាភិបាលរងនៃធនាគារជាតិកម្ពុជា តំណាងក្រសួងពាណិជ្ជកម្មមួយរូប ដែលតំណាងដោយឯកឧត្តម **កាន ច័ន្ទមេត្តា** អនុរដ្ឋលេខាធិការនៃក្រសួងពាណិជ្ជកម្ម តំណាងក្រសួងយុត្តិធម៌មួយរូប តំណាងដោយឯកឧត្តម **កើត រិទ្ធ** អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ តំណាងទីស្តីការគណៈរដ្ឋមន្ត្រីមួយរូប ដែលតំណាងដោយឯកឧត្តម **គឹម រ័ត្នវិសិដ្ឋ** ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អគ្គនាយកនៃ **គ.ម.ក** ឯកឧត្តម **ម៉ិញ បានកុសល** និងអ្នកជំនាញមកពីវិស័យឯកជនដែលមានបទពិសោធន៍វិស័យមូលបត្រ និងមានអព្យាក្រឹត្យភាពពីរូប ដែលតំណាងដោយលោកបណ្ឌិតសាស្ត្រាចារ្យ **សំ យង្វី** និងលោកសាស្ត្រាចារ្យបណ្ឌិត **សំ សុខុម** ។

***<u>អាណត្តិទី ២</u>*** ចាប់ពីឆ្នាំ ២០១៣ ដល់ ឆ្នាំ ២០១៨ គណៈកម្មការមូលបត្រកម្ពុជាដែលមាន ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាប្រធាន សមាជិកចំនួន ០៨ រូប ដែលមានអាណត្តិរយៈពេល ០៥ឆ្នាំ ដែលក្នុងនោះសមាជិកតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មួយរូប ដែលតំណាងដោយលោកជំទាវ **ងួន សុខា** ជារដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តំណាងធនាគារជាតិនៃកម្ពុជាមួយរូប ដែលតំណាងដោយលោកជំទាវ **នាវ ច័ន្ទថាណា** អគ្គទេសាភិបាលរង នៃធនាគារជាតិកម្ពុជា តំណាងក្រសួងពាណិជ្ជកម្មមួយរូប ដែលតំណាងដោយ លោកជំទាវ **តឹករ៉េត កំរង** រដ្ឋលេខាធិការនៃក្រសួងពាណិជ្ជកម្ម តំណាងក្រសួងយុត្តិធម៌មួយរូប តំណាង ដោយឯកឧត្តម **កើត រិទ្ធ** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី មួយរូបដែលតំណាងដោយឯកឧត្តម **កឹម រ័ត្នវិសិដ្ឋ** ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជារដ្ឋ-មន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អគ្គនាយកនៃ **គ.ម.ក** ឯកឧត្តម **ស៊ូ សុជាតិ** និងអ្នកជំនាញ មកពីវិស័យឯកជនដែលមានបទពិសោធន៍វិស័យមូលបត្រ និងមានអព្យាក្រឹតភាពពីររូប ដែលតំណាង ដោយលោកបណ្ឌិតសាស្ត្រាចារ្យ **សំ យដ្ឋី** និងលោកសាស្ត្រាចារ្យបណ្ឌិត **សំ សុខុម**[១០] (ឧបសម្ព័ន្ធ) ។

**កថាខណ្ឌទី ២ អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា**

ក្រៅពីមានរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាប្រធាននៃគណៈកម្មការមូល-បត្រកម្ពុជា ស្ថាប័មួយនេះនៅមានសមាជិកចំនួន ០៨ រូបទៀត ក្នុងការផ្តល់យោបល់ ត្រួតពិនិត្យ និងរៀបចំ ដើម្បីឲ្យការអនុវត្តឲ្យមានប្រសិទ្ធភាព នៅក្នុងការសម្រេចឲ្យបានជោគជ័យចំពោះវិស័យ មូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូច្នេះហើយបានជានៅក្នុងច្បាប់ស្តីពីការបោះផ្សាយ និងជួញ ដូរមូលបត្រមហាជន បានកំណត់ និងតម្រូវឲ្យមានអគ្គនាយកនៃ **គ.ម.ក** ដែលជាសមាជិកនោះ ដោយបេក្ខភាពរបស់អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ត្រូវធ្វើការជ្រើសរើស និងស្នើឡើង ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជូនប្រមុខរាជរដ្ឋាភិបាល[១១]។ អគ្គនាយកនៃ **គ.ម.ក** មាន ឋានៈ និងបុព្វសិទ្ធិស្មើរដ្ឋលេខាធិការ ។ ហើយចំពោះនៅក្នុងអាណត្តិទី ០១ សមាសភាពជាអគ្គ នាយក នៃ **គ.ម.ក** គឺ ឯកឧត្តម **ម៉ិញ បានកុសល** និងនៅអាណត្តិទី ០២(ពីរ) សមាសភាពជាអគ្គ នាយកនៃ **គ.ម.ក** គឺ ឯកឧត្តមបណ្ឌិត **ស៊ូ សុជាតិ** ។ អគ្គនាយកនៃ **គ.ម.ក** មានអគ្គនាយករងនៃ **គ.ម.ក** មួយចំនួនជាជំនួយការតាមការចាំបាច់ ដែលមានឋានៈ និងបុព្វសិទ្ធិស្មើអនុរដ្ឋលេខាធិការ ។ អគ្គនាយករងនៃ **គ.ម.ក** មានសិទ្ធិអំណាច និងបំពេញភារកិច្ចទាំងឡាយដែលអគ្គនាយកនៃ **គ.ម.ក** ប្រគល់

[១០] http://www.secc.gov.kh/khmer/

[១១] មាត្រា៦ នៃច្បាប់ស្តីពីការបោះផ្សាយ និង ជួញដូរមូលបត្រមហាជន

ឲ្យ[១២] ។ ដែលសមាសភាពរបស់អគ្គនាយករងនៅអាណត្តិទី ០១ មានឯកឧត្តម **ស៊ូ សុជាតិ** ទទួលបន្ទុកចំពោះនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និងនាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ ឯកឧត្តម **កៅ ថាច** ទទួលបន្ទុកចំពោះនាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ និងនាយកដ្ឋានកិច្ចការគតិយុត្ត ឯកឧត្តម **ហួត ពុំ** ទទួលបន្ទុកចំពោះនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាលអភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ និងនាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ ។ ចំណែកសមាសភាពរបស់អគ្គនាយករងនៃ **គ.ម.ក** នៅអាណត្តិទី ២ (ពីរ) មានឯកឧត្តម **សុខ ដារ៉ា** ទទួលបន្ទុកចំពោះនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាលអភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ និងនាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ ឯកឧត្តម **ឈុន សម្បត្តិ** អគ្គនាយករងនៃ **គ.ម.ក** ទទួលបន្ទុកចំពោះនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងនាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ ឯកឧត្តម **សៀង ធីរិទ្ធិ** អគ្គនាយករងនៃ **គ.ម.ក** ទទួលបន្ទុកចំពោះនាយកដ្ឋានកិច្ចការគតិយុត្ត និងនាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ[១៣] (ឧបសម្ព័ន្ធ) ។

### កថាខណ្ឌទី ៣ ដំណើរការរបស់គណៈកម្មការមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជា មានកិច្ចប្រជុំសាមញ្ញ និងកិច្ចប្រជុំវិសាមញ្ញ ដែលការប្រជុំសាមញ្ញត្រូវធ្វើឡើងយ៉ាងតិច ០១ (មួយ) ខែម្តង ទៅតាមការអញ្ជើញរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក** ក្នុងករណីចាំបាច់ និងជាបន្ទាន់ **គ.ម.ក** អាចបើកកិច្ចប្រជុំសាមញ្ញបានគ្រប់ពេលវេលា ដើម្បីជាប្រយោជន៍ដល់វិស័យមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក** ឬ តាមសំណើរបស់អគ្គនាយកនៃ **គ.ម.ក** ឬ តាមសំណើរបស់សមាជិកនៃ **គ.ម.ក** ដែលមានចំនួនយ៉ាងតិច ១ ភាគ ៣ នៃសមាជិកទាំងអស់ ។ ក្នុងករណីពិសេស ប្រសិនបើរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក** មានធុរៈ ឬ អវត្តមាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក** ត្រូវផ្ទេរសិទ្ធិទៅឲ្យសមាជិកណាម្នាក់ក្នុងចំណោមសមាជិកវត្តមាន ដើម្បីដឹកនាំការប្រជុំ ។ របៀបវារៈ និងឯកសារនានាសម្រាប់កិច្ចប្រជុំសាមញ្ញត្រូវផ្ញើជូនគ្រប់សមាជិកនៃ **គ.ម.ក** យ៉ាងតិច ០៧ (ប្រាំពីរ) ថ្ងៃមុនថ្ងៃប្រជុំ[១៤] ។ ចំពោះកិច្ចដំណើរការកិច្ចប្រជុំរបស់ **គ.ម.ក** អាចប្រព្រឹត្តិទៅបានលុះត្រាតែមានវត្តមានសមាជិកលើសពី ៥០ (ហាសិប) ភាគរយនៃសមាជិកទាំងអស់ ។ ហើយ

[១២] មាត្រា ៣ នៃអនុក្រឹត្យស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈកម្មការមូលបត្រកម្ពុជា
[១៣] http://www.secc.gov.kh/khmer/
[១៤] មាត្រា ១៧ អនុក្រឹត្យស្តីពី ការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈកម្មការមូលបត្រកម្ពុជា

សមាជិកអវត្តមាន គ្មានសិទ្ធបញ្ជូនអ្នកតំណាងឲ្យមកប្រជុំជំនួសខ្លួនបានឡើយ។ ក្នុងករណីមិនគ្រប់កូរ៉ុម កិច្ចប្រជុំលើកទី ២ មិនតម្រូវអោយមានកូរ៉ុមឡើយ ។ ហើយនៅពេលចាប់ផ្តើមប្រជុំ អង្គប្រជុំត្រូវអនុម័តលើរបៀបវារៈនៃកិច្ចប្រជុំជាមុនសិន មុននឹងដំណើរការកិច្ចប្រជុំ ប្រសិនបើសមាជិកនីមួយៗមានបំណងចង់បន្ថែម របៀបវារៈនៃកិច្ចប្រជុំ សមាជិកនោះអាចធ្វើការស្នើសុំបន្ថែមនូវរបៀបវារៈនោះដើម្បីដាក់ជូនអង្គប្រជុំ ពិនិត្យ និងសម្រេច ។ បន្ទាប់មកប្រធាននៃអង្គប្រជុំ ត្រូវលើកឡើងនូវរបៀបវារៈនីមួយៗ ដែលបានអនុម័តរួចជូនអង្គប្រជុំពិនិត្យ និងពិភាក្សា ដែលនៅក្នុងការពិភាក្សានោះវាគ្មិនម្នាក់ៗអាចលើកឡើងនូវមតិយោបល់របស់ខ្លួន តែមិនឲ្យប្រាកចាកពីរបៀបវារៈដែលបានអនុម័តនោះទេ ប្រសិនបើសមាជិកណាម្នាក់បញ្ចេញមតិយោបល់ប្រាក់ចាកទៅនឹងខ្លឹមសារនៃរបៀបវារៈ ប្រធាននៃអង្គប្រជុំមានសិទ្ធិបញ្ឈប់ការបញ្ចេញមតិយោបល់របស់សមាជិកនោះបាន[១៥]។ សេចក្តីសម្រេចរបស់ **គ.ម.ក** អាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសម្លេងភាគច្រើននៃសមាជិកវត្តមាន ។ ក្នុងករណីមានសម្លេងស្មើគ្នា សម្លេងរបស់ប្រធាននៃកិច្ចប្រជុំមានឧត្តមានុភាព[១៦] ។

ហើយនៅក្នុងអំឡុងពេលនៃកិច្ចប្រជុំ អគ្គនាយកនៃ **គ.ម.ក** ត្រូវចាត់តាំងលេខាធិការកត់ត្រាកិច្ចប្រជុំរបស់ **គ.ម.ក** ។ សេចក្តីសម្រេចរបស់ **គ.ម.ក** ត្រូវកត់ត្រាក្នុងកំណត់ហេតុដែលត្រូវចុះហត្ថលេខា ដោយប្រធាននៃកិច្ចប្រជុំ និងលេខាធិការកត់ត្រា ។ កំណត់ហេតុនេះត្រូវផ្ញើរជូនប្រធាន និងសមាជិកទាំងអស់ នៃ **គ.ម.ក** ក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់) ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំ[១៧] ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក** ត្រូវរាយការណ៍ជាប្រចាំអំពីការអភិវឌ្ឍគោលនយោបាយ និងយុទ្ធសាស្ត្រ ព្រមទាំងបញ្ហាប្រឈមនានាក្នុងវិស័យមូលបត្រជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីជ្រាបសុំការណែនាំ ឬ សុំការសម្រេច [១៨]។ សមាជិកនៃ **គ.ម.ក** ទាំងអស់ត្រូវប្រកាន់ខ្ជាប់នូវកាតព្វកិច្ចរក្សាការសម្ងាត់នៅពេលបំពេញភារកិច្ច និងទោះបីជាក្រោយពេលបញ្ចប់ភារកិច្ចរបស់ខ្លួននៅ **គ.ម.ក** ក៏ដោយ ។ រាល់ការសំដែងចេញ ឬ ការផ្សព្វផ្សាយព័ត៌មានទាំងឡាយណាដែលជាប់ទាក់ទិនទៅនឹងការសម្រេចរបស់ **គ.ម.ក** ឬ ដែលពាក់ព័ន្ធដល់បញ្ហាផ្សេងៗជាសមត្ថកិច្ចរបស់ **គ.ម.ក** ត្រូវមានគោលការណ៍អនុញ្ញាតជាមុនពីប្រធាននៃ **គ.ម.ក** ហើយក្នុងករណីប្រព្រឹត្តល្មើសនឹង

[១៥] ប្រការ ៨ នៃប្រកាសស្តីពីការដាក់ឲ្យអនុវត្តបទបញ្ជាផ្ទៃក្នុងសម្រាប់សមាជិកនៃគណៈកម្មការមូលបត្រកម្ពុជា
[១៦] មាត្រា ១៨ អនុក្រឹត្យស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈកម្មការមូលបត្រកម្ពុជា
[១៧] មាត្រា ១៩ អនុក្រឹត្យស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈកម្មការមូលបត្រកម្ពុជា
[១៨] មាត្រា ២០អនុក្រឹត្យស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈកម្មការមូលបត្រកម្ពុជា

ត្រូវផ្តន្ទាទោសតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន[១៩] ។ តួយ៉ាងចាប់តាំពីការបង្កើត **គ.ម.ក** រហូតមកដល់ពេលបច្ចុប្បន្ននេះ **គ.ម.ក** បានធ្វើកិច្ចប្រជុំចំនួន ៣៧ លើករួចមកហើយ ដែលនៅក្នុងកិច្ចប្រជុំនីមួយៗនោះអង្គប្រជុំបានសម្រេច លទ្ធផលគួរឲ្យមានការកត់សម្គាល់ផងដែរ [២០]។

## ផ្នែកទី ៣ រចនាសម្ព័ន្ធកម្រិតបច្ចេកទេស និងអង្គភាពនៃគណៈកម្មការមូលបត្រកម្ពុជា

### កថាខណ្ឌទី ១ នាយកដ្ឋានជំនាញ

ក្រៅពីមានរចនាសម្ព័ន្ធថ្នាក់ដឹកនាំ ដើម្បីធ្វើការគ្រប់គ្រង និងត្រួតពិនិត្យលើដំណើរការរបស់ស្ថាប័នមួយនេះហើយនោះ **គ.ម.ក** ក៏នៅមានរចនាសម្ព័ន្ធនាយកដ្ឋានជំនាញចំនួន ០៦ ទៀតផង ដែលចំណុះឲ្យ **គ.ម.ក** ដែលត្រូវបានគ្រប់គ្រងដោយអគ្គនាយកនៃ **គ.ម.ក** ។ ម្យ៉ាងទៀត អគ្គនាយក **គ.ម.ក** ត្រូវចាត់អគ្គនាយករង ដែលជាជំនួយការក្នុងការគ្រប់គ្រង ត្រួតពិនិត្យ និងរាយការណ៍អំពីព័ត៌មានផ្សេងៗ ជូនអគ្គនាយកនៃ **គ.ម.ក** អំពីកិច្ចការនានារបស់នាយកដ្ឋានទាំង ០៦។ នាយកដ្ឋាននីមួយៗត្រូវដឹកនាំដោយប្រធាន ០១ (មួយ) រូប ដែលមានឋានៈ និងបុព្វសិទ្ធិស្មើប្រធាននាយកដ្ឋាន និងមានអនុប្រធានមួយចំនួនជាជំនួយការ និងមានការិយាល័យចំណុះមួយចំនួនទៅតាមតម្រូវចាំបាច់ ដែលរៀបចំឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក** ។ ប្រធាននាយកដ្ឋានត្រូវតែងតាំង ឬ ផ្លាស់ប្តូរភារកិច្ចដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល តាមសំណើរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក** ។ ការតែងតាំង ឬ ផ្លាស់ប្តូរភារកិច្ចចាប់ពីថ្នាក់ក្រោមប្រធាននាយកដ្ឋានចុះ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់អគ្គនាយកនៃ **គ.ម.ក** [២១] ។

#### ក.នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

ចំពោះនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃ **គ.ម.ក** ត្រូវដឹកនាំដោយប្រធាននាយកដ្ឋាន ០១ (មួយ)រូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់[២២] ។ ក្រៅពីនេះផងដែរ នាយក-ដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មានការិយាល័យចំណុះចំនួន ០៣ (បី) ដូចខាងក្រោម[២៣]៖

១.ការិយាល័យរដ្ឋបាល និងបុគ្គលិក

---

[១៩] មាត្រា ៥៥ ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

[២០] http://www.secc.gov.kh/khmer/

[២១] មាត្រា ៥ អនុក្រឹត្យស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈកម្មការមូលបត្រកម្ពុជា

[២២] ប្រការ ២ នៃប្រកាស ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃនាយកដ្ឋានរដ្ឋាល និងហិរញ្ញវត្ថុ នៃ គ.ម.ក

[២៣] ប្រការ ៣ នៃប្រកាស ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃនាយកដ្ឋានរដ្ឋាល និងហិរញ្ញវត្ថុ នៃ គ.ម.ក

២.ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ

៣.ការិយាល័យគ្រប់គ្រងព័ត៌មានវិទ្យា

ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធាន ០១ (មួយ) រូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ (ឧបសម្ព័ន្ធ) ។

**ខ.នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ**

ចំពោះនាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រនៃ **គ.ម.ក** ត្រូវដឹកនាំដោយប្រធាននាយកដ្ឋាន ០១ (មួយ) រូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់[២៤] ។ ក្រៅពីនេះផងដែរ នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ មានការិយាល័យចំណុះចំនួន ៣ (បី) ដូចខាងក្រោមៈ

១.ការិយាល័យបោះផ្សាយមូលបត្រ និងឯកសារផ្តល់ព័ត៌មាន

២.ការិយាល័យអភិបាលកិច្ចសាជីវកម្ម

៣.ការិយាល័យត្រួតពិនិត្យកិច្ចការគណនេយ្យ

ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធាន ០១ (មួយ) រូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ (ឧបសម្ព័ន្ធ) ។

**គ.នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ**

ចំពោះនាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រនៃ **គ.ម.ក** ត្រូវដឹកនាំដោយប្រធាននាយកដ្ឋាន ០១ (មួយ) រូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់[២៥] ។ ក្រៅពីនេះផងដែរ នាយកដ្ឋានគ្រប់ត្រួតពិនិត្យទីផ្សារមូលបត្រ មានការិយាល័យចំណុះចំនួន ០៣(បី) ដូចខាងក្រោម[២៦]

១.ការិយាល័យត្រួតពិនិត្យប្រតិបត្តិការទីផ្សារមូលបត្រ

២.ការិយាល័យត្រួតពិនិត្យប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ

៣.ការិយាល័យត្រួតពិនិត្យសេវារក្សាទុកមូលបត្រ

ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធាន ០១ (មួយ) រូប និង មានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ (ឧបសម្ព័ន្ធ) ។

**ឃ.នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ**

[២៤] ប្រការ ២ នៃប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ នៃ គ.ម.ក

[២៥] ប្រការ ២ នៃប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានត្រួតពិនិត្យទីផ្សាមូលបត្រនៃ គ.ម.ក

[២៦] ប្រការ ៣ នៃប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានត្រួតពិនិត្យទីផ្សាមូលបត្រនៃ គ.ម.ក

ចំពោះនាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ ដឹកនាំដោយប្រធាននាយកដ្ឋាន ០១ (មួយ) រូប នឹងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់[២៧] ។ ក្រៅពីនេះផងដែរ នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ មានការិយាល័យចំណុះចំនួន ០៣ (បី) ដូចខាងក្រោម[២៨]៖

១.ការិយាល័យសម្របសម្រួល និងអាជ្ញាប័ណ្ណ

២.ការិយាល័យត្រួតពិនិត្យលើឯកសារ

៣.ការិយាល័យត្រួតពិនិត្យដល់ទីកន្លែង

ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធាន ០១ (មួយ) រូប និង មានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ (ឧបសម្ព័ន្ធ) ។

**ខ.នាយកដ្ឋានកិច្ចការគតិយុត្ត**

ចំពោះនាយកដ្ឋានកិច្ចការគតិយុត្តនៃ **គ.ម.ក** ត្រូវដឹកនាំដោយប្រធាននាយកដ្ឋាន០១ (មួយ) រូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់[២៩] ។ ក្រៅពីនេះផងដែរ នាយកដ្ឋានកិច្ចការគតិយុត្ត មានការិយាល័យចំណុះចំនួន ០៣ (បី) ដូចខាងក្រោម[៣០]

១.ការិយាល័យពង្រឹងការអនុវត្តច្បាប់ និងនីតិកម្ម

២.ការិយាល័យទទួលពាក្យបណ្តឹង និងដោះស្រាយវិវាទ

៣.ការិយាល័យស៊ើបអង្កេត

ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធាន ០១ (មួយ) រូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ (ឧបសម្ព័ន្ធ) ។

**គ.នាយកដ្ឋានស្រាវជ្រាវបណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ**

ចំពោះនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាលអភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិនៃ **គ.ម.ក** ត្រូវដឹកនាំដោយប្រធាននាយកដ្ឋាន ០១ (មួយ) រូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់[៣១] ។ ក្រៅពីនេះផងដែរ នាយកដ្ឋានស្រាវជ្រាវបណ្តុះបណ្តាលអភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ មានការិយាល័យចំណុះចំនួន ០៣ (បី) ដូចខាងក្រោម៖

[២៧] ប្រការ ២ នៃប្រកាសស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃនាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រនៃ គ.ម.ក

[២៨] ប្រការ ៣ នៃប្រកាសស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃនាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រនៃ គ.ម.ក

[២៩] ប្រការ ២ នៃប្រកាសស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃនាយកដ្ឋានកិច្ចការគតិយុត្តនៃ គ.ម.ក

[៣០] ប្រការ ៣ នៃប្រកាសស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃនាយកដ្ឋានកិច្ចការគតិយុត្តនៃ គ.ម.ក

១.ការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍន៍ទីផ្សារមូលបត្រ

២.ការិយាល័យបណ្តុះបណ្តាល និងផ្សព្វផ្សាយ

៣.ការិយាល័យទំនាក់ទំនងអន្តរជាតិ

ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធាន ០១ (មួយ) រូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ (ឧបសម្ព័ន្ធ) ។

**កថាខណ្ឌទី ២ អង្គភាពសវនកម្មផ្ទៃក្នុង នៃគណៈកម្មការមូលបត្រកម្ពុជា**

**គ.ម.ក** មានអង្គភាពសវនកម្មផ្ទៃក្នុង ដែលស្ថិតក្រោមការដឹកនាំ និងគ្រប់គ្រងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក**។ អង្គភាពសនវកម្មផ្ទៃក្នុងត្រូវដឹកនាំដោយប្រធាន ០១ (មួយ) រូប ដែលមានឋានៈ និងបុព្វសិទ្ធិស្មើប្រធាននាយកដ្ឋាន និងមានអនុប្រធានមួយចំនួនជាជំនួយការ និងមានការិយាល័យចំណុះមួយចំនួនទៅតាមតម្រូវការចាំបាច់ ដែលរៀបចំឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក** ។ ប្រធានអង្គភាពសវនកម្មផ្ទៃក្នុងត្រូវតែងតាំង ឬផ្លាស់ប្តូរភារកិច្ចដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាលតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក**[៣២]។ អង្គភាពសវនកម្មផ្ទៃក្នុងត្រូវដឹកនាំដោយប្រធាន ០១ (មួយ) រូប និង មានអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់[៣៣] ។ ក្រៅពីនេះផងដែរ អង្គភាពសវនកម្មផ្ទៃក្នុងមានការិយាល័យចំណុះចំនួន ០២ (ពីរ) ដូចខាងក្រោម[៣៤]៖

១. ការិយាល័យសនវកម្មទី ១

២. ការិយាល័យសនវកម្មទី ២

ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធាន ០១ (មួយ) រូប និង មានអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ (ឧបសម្ព័ន្ធ) ។

សរុបមក វត្តមាននៃគណៈកម្មការមូលបត្រកម្ពុជា ដែលបានកើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងនេះ មិនមែនជាភាពចៃដន្យនោះឡើយ គឺដោយសារតែមានការជះឥទ្ធិពលពីបណ្តាសកលលោកនានា ដែលបានទទួលភាពជោគជ័យក្នុងនាមជាអាជ្ញាធរគ្រប់គ្រងលើវិស័យមូលបត្រនេះ ។ ម្យ៉ាង

[៣១] ប្រការ ២ នៃប្រកាសស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាលអភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទាំនាក់ទំនងអន្តរជាតិនៃ គ.ម.ក

[៣២] មាត្រា ១២ អនុក្រឹត្យស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា

[៣៣] ប្រការ ៣ នៃប្រកាសស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុងនៃ គ.ម.ក

[៣៤] ប្រការ ៤ នៃប្រកាស ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុងនៃ គ.ម.ក

ទៀត ក្រោយពីបានបង្កើតឡើងនៃគណៈកម្មការមូលបត្រកម្ពុជានេះឡើងហើយនោះ ស្ថាប័ននេះបានធ្វើការរៀបចំនូវរចនាសម្ព័ន្ធដាច់ដោយឡែកពីគ្នា ដើម្បីធ្វើឲ្យដំណើរការរបស់ស្ថាប័នមានភាពរលូន ដោយបានធ្វើការបែងចែកជារចនាសម្ព័ន្ធរបស់ថ្នាក់ដឹកនាំ និងរចនាសម្ព័ន្ធកម្រិតបច្ចេកទេសរបស់គណៈកម្មការមូលបត្រកម្ពុជា ។ មានចម្ងល់បានសួរថា តើរចនាសម្ព័ន្ធថ្នាក់ដឹកនាំ និងរចនាសម្ព័ន្ធកម្រិតបច្ចេកទេសទាំងពីខាងលើ របស់គណៈកម្មការមូបត្រកម្ពុជា មានតួនាទី និងភារកិច្ចខុសគ្នាដូចម្តេចខ្លះ? ដែលចម្ងល់នេះនឹងត្រូវបានធ្វើការបកស្រាយនូវក្នុងជំពូកទី ២ បន្ទាប់នេះ ។

# ជំពូកទី ២

# តួនាទី និង ភារកិច្ចរបស់គណៈកម្មការមូលបត្រកម្ពុជា

តួនាទី និងភារកិច្ចរបស់គណៈកម្មការមូលបត្រកម្ពុជា ត្រូវបានធ្វើការបែងចែកជាពីរផ្នែកចំបងៗ ដើម្បីអនុវត្តតួនាទីរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ទៅតាមច្បាប់ដែលបានកំណត់ ពីព្រោះថា នៅក្នុងច្បាប់បានកំណត់ថា តួនាទីរបស់ថ្នាក់ដឹកនាំ មានតួនាទីដើរតួជាដូចជាក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនពាណិជ្ជកម្ម និង តួនាទីរបស់ថ្នាក់ដឹកនាំ មានតួនាទីដូចជា CEO របស់ក្រុមហ៊ុនពាណិជ្ជកម្ម។ ម្យ៉ាងទៀត ច្បាប់ក៏បានកំណត់អំពីតួនាទី និងភារកិច្ចកម្រិតបច្ចេកទេសនៅក្នុងស្ថាប័ននេះផងដែរ។ ថាតើ តួនាទីរបស់ថ្នាក់ដឹកនាំរបស់(**គ.ម.ក**) មានភារកិច្ចធ្វើអ្វីខ្លះ? ហើយតួនាទីរបស់កម្រិតបច្ចេកទេសរបស់ (**គ.ម.ក**) មានភារកិច្ចធ្វើអ្វីខ្លះ? ដែលចម្លល់ទាំងនេះនឹងត្រូវធ្វើការបកស្រាយនៅក្នុងផ្នែកទី ១ នឹង ផ្នែកទី ២ ខាងក្រោមនេះ។

## ផ្នែកទី ១ តួនាទី និង ភារកិច្ចជាក្រុមប្រឹក្សាលើវិស័យមូលបត្រ

គណៈកម្មការមូលបត្រកម្ពុជា គឺជាស្ថាប័នមួយ ដែលត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីការបោះផ្សាយ និងការជួយដូរមូលបត្រមហាជន[៣៧]។ ហើយតួនាទីរបស់ស្ថាប័ននេះក៏បានចែងនៅក្នុងច្បាប់នេះផងដែរ ។ តួយ៉ាង នៅក្នុងតួនាទីរបស់ **គ.ម.ក** ជាក្រុមប្រឹក្សា គឺជាតួនាទីដែលច្បាប់បានកំណត់នៅក្នុងការធ្វើសេចក្តីសម្រេច និងចេញគោលការណ៍ផ្សេងៗ ដើម្បីធ្វើឲ្យមានការអភិវឌ្ឍចំពោះវិស័យមូលបត្រនៅកម្ពុជា។

### កថាខណ្ឌទី ១ តួនាទី និង ភារកិច្ចជារួម

ការបង្កើត **គ.ម.ក** គឺជាកត្តាលីករមួយយ៉ាងសំខាន់ក្នុងការទាក់ទាញទំនុកចិត្តពីអ្នកវិនិយោគឲ្យមកវិនិយោគវិស័យមូលបត្រនៅកម្ពុជា និងធានាពីការដាក់ឲ្យដំណើរការទីផ្សារមូលបត្រនៅកម្ពុជាឲ្យឆាប់ចេញជារូបរាងឡើងស្របតាមការគ្រោងទុករបស់រាជរដ្ឋាភិបាល ។ ដោយសារតែដំណើរការបង្កើតទីផ្សារមូលបត្រនៅកម្ពុជាមានលក្ខណៈថ្មីថ្មោង បើប្រៀបធៀបទៅនឹងទីផ្សារមូលបត្រនៅតាមបណ្តាប្រទេសដទៃទៀត ដែលទាមទារឲ្យមានអាជ្ញាធរនៅក្នុងការគ្រប់គ្រងជាមុន ។ ដូច្នេះហើយតួនាទី និងភារកិច្ចរបស់ **គ.ម.ក** ដែលជាអាជ្ញាធរមានទំហំធំដែលស្របទៅតាមបញ្ញត្តិរបស់ច្បាប់ និង

[៣៧] មាត្រា ៥ នៃច្បាប់ស្តីពីការបោះផ្សាយ និង ជួញដូរមូលបត្រមហាជន

ស្ថានភាពជាក់ស្តែងរបស់ប្រទេសកម្ពុជាលើវិស័យមូលបត្រ ដើម្បីបង្កើត និង រក្សាឲ្យមានទំនុកចិត្តពីអ្នកវិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការការពារសិទ្ធិស្របច្បាប់របស់អ្នកវិនិយោគ និងធានាឲ្យមានការបោះផ្សាយ និងការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវលើកកម្ពស់ការគ្រប់គ្រងទីផ្សារមូលបត្រឲ្យមានប្រសិទ្ធិភាព និងជំរុញការអភិវឌ្ឍទីផ្សារនេះឲ្យមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយជំរុញឲ្យមានភាពសម្បូរបែបនៃឧបករណ៍សញ្ញ័យតាមរយៈការទិញ លក់មូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត និងជំរុញឲ្យមានការវិនិយោគទុនពីបរទេស និងការចូលរួមក្នុងទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ក. អាណាព្យាបាលលើវិស័យមូលបត្រ**

តួនាទីរបស់ **គ.ម.ក** ក្នុងនាមជាស្ថាប័នអាណាព្យាបាលលើវិស័យមូលបត្រ គឺមានន័យថា **គ.ម.ក** មានតួនាទីគ្រប់គ្រងលើស្ថាប័នទាំងឡាយ ដែលទាក់ទងនឹងវិស័យមូលបត្រ និងគ្រប់គ្រងទីផ្សារមូលបត្រ និងក្រុមហ៊ុនមូលបត្រទាំងមូល នៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងទីផ្សារមូលបត្ររដ្ឋ ។ ដែលសរុបជារួម ឲ្យតែរាល់ការធ្វើសកម្មភាពដែលទាក់ទងទៅនឹងវិស័យមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជាគឺ **គ.ម.ក** ជាអ្នកមានសិទ្ធអំណាចយ៉ាងពេញលេញដែលច្បាប់បានផ្តល់ជូននៅក្នុងការចាត់វិធានការ និងតាមដានរាល់ដំណើរការរបស់ស្ថាប័ននានាដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ និងបុគ្គលដែលចូលរួមនៅក្នុងទីផ្សារមូលបត្រ ។ ម្យ៉ាងទៀត ជាអាណាព្យាបាលនៅក្នុងវិស័យមូលបត្រ **គ.ម.ក** ដើរតួជាអ្នកផ្តល់ការអនុញ្ញាត ចំពោះបុគ្គលទាំងឡាយណាដែលមានបំណងចង់បោះផ្សាយ និងលក់មូលបត្រ ដូចមានចែងនៅក្នុងមាត្រ ១២ នៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន គ្មានបុគ្គលណាមួយបោះផ្សាយ និងលក់មូលបត្រជាសាធារណៈបានទេ លើកលែងតែបុគ្គលនោះទទួលបានការអនុញ្ញាតពី **គ.ម.ក** និងផ្តល់កាអនុញ្ញាតដល់បុគ្គលឲ្យធ្វើជាប្រតិបត្តិការទីផ្សាមូលបត្រ ប្រព័ន្ធជាត់ទាត់ និងទូទាត់ ឬ សេវារកាទុកមូលបត្រ ដូចមាន ចែងនៅក្នុងមាត្រា ២៣ នៃច្បាប់ដដែលបញ្ជាក់ថា គ្មានបុគ្គលណាមួយអាចធ្វើជាប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់ និងទូទាត់ ឬ សេវារក្សាទុកមូលបត្របានឡើយ លើកលែងតែបុគ្គលនោះទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក** ដែលបុគ្គលទាំងនោះត្រូវដាក់ពាក្យស្នើសុំ និងត្រូវទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក** ក្រោយពីទទួលបានការសម្រេចពីការប្រជុំពេញអង្គរបស់ **គ.ម.ក** ដោយបានពិនិត្យត្រឹមត្រូវទៅតាមនីតិវិធីដែលមានចែងនៅក្នុងបទប្បញ្ញត្តិរួចហើយនោះ ប្រសិនបើប្រតិ-បត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់ ឬ ប្រតិបត្តិកររក្សាទុកមូលបត្រទទួលបានការអនុញ្ញាតរួចហើយ តែបែរជាបានបំពានលក្ខខណ្ឌនៃការអនុញ្ញាត អគ្គនាយកនៃ **គ.ម.ក** អាចធ្វើ

ការដឹកនាំកែតម្រង់បុគ្គល ដែលទទួលបានការអនុញ្ញាតឲ្យអនុវត្តលក្ខខណ្ឌតម្រូវ និងដាក់លក្ខខណ្ឌ ឬ កំហិតបន្ថែមលើការអនុញ្ញាត ហើយបើសិននៅតែបំពានទៀត អគ្គនាយកនៃ **គ.ម.ក** និងព្យួរការអនុញ្ញាតរហូតដល់អ្នកទទួលការអនុញ្ញាតនោះអនុវត្តតាមលក្ខខណ្ឌ និងអាចឈានដល់ការដកហូតការអនុញ្ញាតនោះមកវិញទៀតផង ។ លើសពីនេះទៅទៀត **គ.ម.ក** ជាអាណាព្យាបាលនៅក្នុងការផ្តល់អាជ្ញាប័ណ្ណចំពោះក្រុមហ៊ុនមូលបត្រ ដែលមានបំណងចង់ធ្វើអាជីវកម្មចំពោះវិស័យមូលបត្រ ដែលក្នុងនោះត្រង់មាត្រា ៣១ នៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជនបានកំណត់ថា គ្មានបុគ្គលណាមួយអាចធ្វើអាជីវកម្មមូលបត្រ ឬតាំងខ្លួនជាអ្នកធ្វើអាជីវកម្មមូលបត្រក្នុងទម្រង់ជាក្រុមហ៊ុនមូលបត្របានទេ លើកលែងតែបុគ្គលនោះទទួលអាជ្ញាប័ណ្ណពីអគ្គនាយក នៃ **គ.ម.ក** ឬ ពាណិជ្ជករមូលបត្រអញ្ញត្រកម្ម ឬពាណិជ្ជករពាក់ព័ន្ធនឹងប្រតិបត្តិការមូលបត្រអញ្ញត្រកម្ម ។ ហើយក៏គ្មានជនណាមួយអាចធ្វើជាភ្នាក់ងារ ឬ តាំងខ្លួនជាភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រប្រតិស្រុត ដើម្បីធ្វើអាជីវកម្មមូលបត្របានទេ លុះត្រាតែជននោះត្រូវបានផ្តល់អាជ្ញាប័ណ្ណដោយអគ្គនាយកនៃ **គ.ម.ក** ។ បុគ្គលដែលមានបំណងធ្វើអាជីវកម្មក្រុមហ៊ុនមូលបត្រ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណនៅ **គ.ម.ក** ដោយបុគ្គលដែលដាក់ពាក្យស្នើសុំធ្វើអាជីវកម្មមូលបត្រនោះ ត្រូវតែជាក្រុមហ៊ុនមូលធន ឬ ក្រុមហ៊ុនសហកម្មសិទ្ធិ ដែលត្រូវបានបង្កើតឡើងដោយអនុលោមតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងត្រូវតែជាសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ ឬ ត្រូវមានគុណវុឌ្ឍិគ្រប់គ្រាន់ ព្រមទាំងត្រូវមានមូលធនសុទ្ធអប្បរមា និងរចនាសម្ព័ន្ធមូលធនដែលត្រូវកំណត់ដោយ **គ.ម.ក** អំពីប្រភេទអាជីវកម្មមូលបត្រ និងលក្ខខណ្ឌបន្ថែមទៀត ដែលកំណត់ដោយអនុក្រឹត្យ និងប្រកាសរបស់ **គ.ម.ក** ។ ចំណែកឯការផ្តល់អាជ្ញាប័ណ្ណទៅដល់បុគ្គល ដើម្បីធ្វើសកម្មភាពអាជីវកម្មជាភ្នាក់ងារក្រុមហ៊ុនមូលបត្រ គឺបុគ្គលទាំងនោះត្រូវដាក់ពាក្យស្នើសុំនោះមក **គ.ម.ក** បន្ទាប់ពីទទួលបានពាក្យស្នើសុំហើយ អគ្គនាយកនៃ **គ.ម.ក** ត្រូវពិនិត្យអំពីលក្ខណសម្បត្តិ និងអត្តចរិតរបស់បុគ្គលនោះ និងពិនិត្យទៅលើគុណវុឌ្ឍិគ្រប់គ្រាន់ មុននឹងចេញអាជ្ញាប័ណ្ណឲ្យ។ ទន្ទឹមនឹងនេះដែរ **គ.ម.ក** ក៏មានតួនាទីត្រួតពិនិត្យ និងផ្តល់ការអនុញ្ញាតលើវិធានចុះបញ្ជីរបស់ទីផ្សារមូលបត្រ ដែលជាកិច្ចសន្យារវាងប្រតិបត្តិករទីផ្សារមូលបត្រ និងក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុតដែលបានចុះបញ្ជីលក់មូលបត្រនៅលើទីផ្សារមូលបត្រ ។ លើសពីនេះទៅទៀត ក្នុងនាមជាអាណាព្យាបាលលើវិស័យមូល-បត្រ **គ.ម.ក** ក៏មានភារកិច្ចនៅក្នុងការផ្សះផ្សាវិវាទ ដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ ដោយតម្រូវឲ្យភាគីជម្លោះនាំយកវិវាទទាំងនោះជូនទៅ **គ.ម.ក** ដើម្បីធ្វើការផ្សះផ្សាមុននឹងប្តឹងទៅតុលាការ លើក

លែងតែរឿងព្រហ្មទណ្ឌ[៣៦]។ បន្ទាប់មក ក្រោយពីបានទទួលពាក្យប្តឹងហើយ **គ.ម.ក** ត្រូវសាកសួរភាគីទាំងសងខាងឲ្យដឹងអំពីកម្មវត្ថុនៃវិវាទ រួចសាកល្បងធ្វើការផ្សះផ្សារភាគីដោយយកច្បាប់ និងបទប្បញ្ញត្តិផ្សេងៗជាមូលដ្ឋាន ។ ហើយនៅពេលផ្សះផ្សារនោះ គ.ម.ក ត្រូវចុះកំណត់ហេតុបញ្ជាក់អំពីការយល់ព្រម ឬមិនយល់ព្រមផ្សះផ្សានៃគូភាគី ។ ក្នុងករណីដែលគ្មានសះជានឹងគ្នា សាមីភាគីអាចស្នើសុំកំណត់ហេតុមិនសះជាទៅវេទិកាមជ្ឈត្តកម្មមានសមត្ថកិច្ច ឬប្តឹងទៅតុលាការមានសមត្ថកិច្ច ។ អាជ្ញាយុកាលប្តឹងទៅវេទិកាមជ្ឈត្តកម្មមានសមត្ថកិច្ច ឬប្តឹងទៅតុលាការមានសមត្ថកិច្ច មានរយៈពេល ៩០ (កៅសិបថ្ងៃ) ពុំនោះទេ សិទ្ធិប្តឹងនេះនឹងត្រូវបាត់បង់[៣៧] ។

**ខ. និយ័តករលើវិស័យមូលបត្រ**

តួនាទីរបស់ **គ.ម.ក** ក្នុងនាមជានិយ័តករលើវិស័យមូលបត្រ គឺមានន័យថា **គ.ម.ក** ជាអ្នករៀបចំ និងដាក់ឲ្យអនុវត្តគោលនយោបាយ ដែលពាក់ព័ន្ធនឹងទីផ្សារមូលបត្រ ក្នុងការកំណត់លក្ខខណ្ឌលម្អិតបន្ថែម ដើម្បីផ្តល់ការអនុញ្ញាតជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ឬ ប្រតិបត្តិកររក្សាទុកមូលបត្រ ព្រមទាំងធ្វើការកំណត់លក្ខខណ្ឌបន្ថែមលើលក្ខ-ខណ្ឌដែលច្បាប់ និងអនុក្រឹត្យបានកំណត់ ដើម្បីផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ ។ម្យ៉ាងវិញទៀត **គ.ម.ក** ជាអ្នកលើកកម្ពស់ និងជំរុញដល់ការគោរពច្បាប់មូលបត្ររបស់អ្នកចូលរួមក្នុងទីផ្សារមូលបត្រ និងចេញជាគោលការណែនាំចំពោះនីតិវិធីនៅក្នុងការបោះផ្សាយលក់មូលបត្រ ការស្នាបស្ទង់នូវតំលៃនៃការបោះផ្សាយ និងការធ្វើបរិវិសកម្មមូលបត្រ ព្រមទាំងធ្វើការផ្តល់លេខអត្តសញ្ញាណចំពោះអ្នកវិនិយោគ ថែមទាំងដាក់ឲ្យអនុវត្តនូវការកែប្រែថ្លៃសេវាផ្សេងៗនៅក្នុងវិធានទីផ្សារមូលបត្រ ។ លើសពីនេះ ដើរតួជាស្ថាប័នពិនិត្យ និងដោះស្រាយលើការតវ៉ា ចំពោះសេចក្តីសម្រេចរបស់នីតិបុគ្គលមានអាជ្ញាប័ណ្ណ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សមាជិកអ្នកចូលរួម ឬ អ្នកវិនិយោគ ព្រមទាំងការពិគ្រោះយោបល់ជាមួយបុគ្គលដែលមានលក្ខណសម្បត្តិសមស្រប ដើម្បីបង្កើតគោលនយោបាយមួយសម្រាប់ការអភិវឌ្ឍទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា បន្ថែមលើនេះទៀត **គ.ម.ក** ជាអ្នកត្រួតពិនិត្យការអនុវត្តច្បាប់របស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុតដែលបោះផ្សាយលក់មូលបត្រជូនអ្នកវិនិ-យោគសាធារណៈ ដោយគោរពតាមលក្ខខណ្ឌទាំងឡាយ ដែលច្បាប់តម្រូវ និងចាត់វិធានការសមស្រប។ ដោយឡែកទាក់ទងនឹងក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ **គ.ម.ក** មាន

[៣៦] មាត្រា ៨៣ ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

[៣៧] មាត្រា ៨៤ ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

តួនាទីធ្វើការស៊ើបអង្កេតករណីសង្ស័យចំពោះអំពើល្មើស និងលក្ខខណ្ឌនៃអាជ្ញាប័ណ្ណ ឬ នៃការអនុញ្ញាត ឬ អំពើល្មើសនឹងលក្ខខណ្ឌ នៃច្បាប់នេះរបស់អ្នកកាន់អាជ្ញាប័ណ្ណ និងចាត់វិធានការអនុវត្តសមស្របណាមួយដូចជាព្យួរ ឬ ដកហូតអាជ្ញាប័ណ្ណ ឬ ការអនុញ្ញាត និងចាត់រាល់វិធានការសមស្របដែលច្បាប់នេះបានអនុញ្ញាត ដើម្បីអង្កេតស្វែងរក និងបង្ក្រាបអាជីវកម្មខុសច្បាប់ផ្ទុយ និងក្រមសីលធម៌ និងអំពើមិនសមស្របដែលពាក់ព័ន្ធ និងអាជីវកម្មមូលបត្រ ។

**គ. ការទទួលបានតួនាទីជាមន្ត្រីនគបាលយុត្តិធម៌ក្នុងវិស័យមូលបត្រ**

មន្ត្រី **គ.ម.ក** ត្រូវបានច្បាប់ប្រគល់មុខងារជាមន្ត្រីនគរបាលយុត្តិធម៌ក្នុងការបង្ការ និង ស៊ើបអង្កេតពីបទល្មើសពាក់ព័ន្ធ និងវិស័យមូលបត្រនៅកម្ពុជាទៅតាមការកំណត់រួមមួយក្នុងប្រកាសរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។ មន្ត្រីរបស់ **គ.ម.ក** ទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌មានមុខងារដូចចែងក្នុងនីតិវិធីព្រហ្មទណ្ឌស្តីពីមុខងាររបស់នគរបាលយុត្តិធម៌[៣៨] ។ នគរបាលយុត្តិធម៌ គឺជាជំនួយការរបស់តុលាការស្តីពីមុខងាររបស់នគរបាលយុត្តិធម៌[៣៩]។ នគរបាលយុត្តិធម៌ គឺជាជំនួយការរបស់តុលាការហើយនគរបាលយុត្តិធម៌ក្នុងវិស័យមូលបត្រមានភារកិច្ចត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និង បទលហុកំណត់អត្តសញ្ញាណ និងចាប់ជនល្មើសព្រមទាំងប្រមូលភស្តុតាង និងបញ្ជូនទៅតុលាការ[៤០]។ ពោលជារួមខុសគ្នាទៅលើថា មន្ត្រីនគរបាលយុត្តិធម៌នៃ **គ.ម.ក** មានតួនាទីអនុវត្តតែទៅលើច្បាប់មូលបត្រ ហើយដែនសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌នេះ មានតែក្នុងវិស័យមូលបត្រតែប៉ុណ្ណោះ គឺពុំមានសិទ្ធិ និង សមត្ថកិច្ចអនុវត្តច្បាប់ផ្សេងៗទៀតបានឡើយក្រៅពីច្បាប់ ដែលទាក់ទង នឹង មូលបត្រ ។ មានន័យថា មន្ត្រីនគរបាលយុត្តិធម៌នៃ **គ.ម.ក** មានតួនាទីអនុវត្តការងារ និងសមត្ថកិច្ចរបស់ខ្លួនទៅលើបុគ្គល សហគ្រាស ក្រុមហ៊ុនទាំងឡាយណាដែលប្រព្រឹត្តល្មើសពាក់ព័ន្ធ និងច្បាប់មូលបត្រ មន្ត្រីក្នុងគណៈកម្មការមូលបត្រ ដែលមានតួនាទីជាមន្ត្រីនគរបាលយុត្តិធម៌ មានសិទ្ធិរៀបចំពាក្យបណ្តឹង ឬ ធ្វើរបាយការណ៍កំណត់ហេតុបញ្ជូនទៅព្រះរាជអាជ្ញា ដើម្បីចោទប្រកាន់។ ជាងនេះទៅទៀត មន្ត្រីនគរបាលយុត្តិធម៌នៃ **គ.ម.ក** មានកាតព្វកិច្ចទទួលពាក្យបណ្តឹងតវ៉ាទាំងឡាយចំពោះអំពើទាំងឡាយណាដែរត្រូវសន្មតថាផ្ទុយទៅនឹងច្បាប់ពាក់ព័ន្ធ និងវិស័យមូលបត្រ ពិនិត្យកត់ត្រានូវរាល់បទល្មើស និងប្រមូលផ្តុំភស្តុតាងនៃបទល្មើសទាំងអស់នោះ ដើម្បីបញ្ជូនទៅតុលាការ និងចាត់វិធានការចាំបាច់ផ្សេងៗ

[៣៨] មាត្រា ១៦ អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ម.ក
[៣៩] មាត្រា ១៦ អនុក្រឹត្យស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃ គ.ម.ក
[៤០] មាត្រា ៥៦ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសទាំងនោះ ។ មិនតែប៉ុណ្ណោះ មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិឃាត់ខ្លួន និងឃុំខ្លួនជនទាំងឡាយណាដែលប្រព្រឹត្តិល្មើសនឹងច្បាប់មូលបត្រ ។

**កថាខណ្ឌទី ២ តួនាទីជាប្រធាន និងគ្រប់គ្រងការងាររបស់ គ.ម.ក**

**ក.អគ្គនាយក**

អគ្គនាយកនៃ **គ.ម.ក** គឺមានតួនាទីយ៉ាងសកម្មបំផុតនៅក្នុងការត្រួតពិនិត្យនូវដំណើរការទាំងមូលនៃ **គ.ម.ក** ក្នុងការធ្វើអោយស្ថាប័ននេះមានភាពរីកចំរើន ដើម្បីសម្រេចអោយបាននូវគោលដៅអភិវឌ្ឍន៍ទីផ្សារមូលបត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ។ ដែលភាពចាំបាច់នៅក្នុងការអនុវត្តតួនាទីរបស់ខ្លួននេះហើយ ទើបនៅក្នុងច្បាប់បានកំណត់នូវតួនាទី និងភារកិច្ចនៅក្នុងការគ្រប់គ្រងបុគ្គលិក និងមន្ត្រីជំនាញដែលទទួលបន្ទុកសម្របសម្រួលកិច្ចការរដ្ឋបាលរបស់ **គ.ម.ក** ក្នុងការគ្រប់គ្រងការអភិវឌ្ឍន៍ និងត្រួតពិនិត្យទីផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា និងរាយការណ៍ ផ្តល់អនុសាសន៍ជូនប្រធាន និងសមាជិកទាំងអស់នៃ **គ.ម.ក** នូវរាល់បញ្ហាទាំងអស់ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងការអភិវឌ្ឍន៍ និងការត្រួតពិនិត្យទីផ្សារមូលបត្រនៅកម្ពុជា ព្រមទាំងធ្វើការលើកសំណើសុំធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ។ ម្យ៉ាងទៀត អគ្គនាយកនៃ **គ.ម.ក** ធ្វើការត្រួតពិនិត្យសំណុំឯកសារដែលស្នើសុំធ្វើសំណើលក់មូលបត្រជាសាធារណៈ ថាតើសំណុំឯកសារដែលបានដាក់ស្នើសុំទាំងនោះគោរពទៅតាមលក្ខខណ្ឌច្បាប់ និងបទប្បញ្ញត្តិផ្សេងៗដែលកំណត់ដោយ **គ.ម.ក** ហើយឬនៅ មុននឹងធ្វើការអនុញ្ញាតលើពាក្យស្នើសុំទាំងនោះ បន្ទាប់មកទៀត អគ្គនាយកនៃ **គ.ម.ក** ធ្វើការពិនិត្យទៅលើឯកសារផ្តល់ព័ត៌មានប្រចាំថ្ងៃ ដែលផ្តល់ជូនដោយទីផ្សារមូលបត្រនូវព័ត៌មានស្តីពីហិរញ្ញវត្ថុ និងព័ត៌មានដែលមិនមែនជាហិរញ្ញ-វត្ថុ និងព័ត៌មានផ្សេងៗទៀតរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងនីតិបុគ្គលប្រតិស្រុតដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈ ព្រមទាំងធ្វើការតាមដាននូវការអនុវត្តច្បាប់របស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងនីតិបុគ្គលប្រតិស្រុត ដែលបានទទួលការអនុញ្ញាត្តធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈពី **គ.ម.ក** ។ ចំណែកឯ ទាក់ទងទៅនឹងក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ អគ្គនាយកនៃ **គ.ម.ក** ត្រូវធ្វើការត្រួតពិនិត្យទៅលើពាក្យស្នើសុំអាជ្ញាប័ណ្ណ និងផ្តល់អាជ្ញាប័ណ្ណ ប្រសិនបើអ្នកស្នើសុំអាជ្ញាប័ណ្ណនោះ បានបំពេញលក្ខខណ្ឌច្បាប់ និងលក្ខខណ្ឌផ្សេងៗទៀត ដែលកំណត់ដោយ **គ.ម.ក** ព្រមទាំងធ្វើការត្រួតពិនិត្យនៅសកម្មភាពរបស់អ្នកកាន់អាជ្ញាប័ណ្ណ ដើម្បីធានាឲ្យបានចំពោះអ្នកកាន់អាជ្ញាប័ណ្ណគោរពទៅតាមលក្ខខណ្ឌ អាជ្ញាប័ណ្ណដែលផ្តល់ដោយ **គ.ម.ក** នោះ ។ បន្ថែមពីនេះ ទាក់ទងទៅនឹងទីផ្សារមូលបត្រប្រព័ន្ធផាត់ទាត់ ឬ ទូទាត់ និងរក្សាទុកមូលបត្រ អគ្គនាយកនៃ **គ.ម.ក** ត្រូវធ្វើការពិនិត្យឡើងវិញទាក់ទងទៅនឹងពាក្យស្នើសុំ

អាជ្ញាប័ណ្ណ និង ពាក្យស្នើសុំធ្វើជាប្រតិបត្តិកររបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់ ឬ ទូទាត់ និងរក្សាទុកមូលបត្រនូវការគោរពលក្ខខណ្ឌនៃច្បាប់ និងលក្ខខណ្ឌតម្រូវផ្សេងៗទៀត ដែលបានកំណត់ដោយ **គ.ម.ក** មុននឹងធ្វើការអនុញ្ញាត្ត ។ បន្ទាប់ពីផ្តល់ការអនុញ្ញាតចំពោះប្រតិបត្តិករទីផ្សារមូលបត្ររួចមក អគ្គនាយកនៃ **គ.ម.ក** ធ្វើការត្រួតពិនិត្យទៅលើសកម្មភាពរបស់ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ ឬ ទូទាត់ និងរក្សាទុកមូលបត្របន្ថែមទៀត ក្នុងការធានាឲ្យបានថា នៅពេលប្រតិបត្តិករទីផ្សារមូលបត្រក្រោយពីបានទទួលការអនុញ្ញាតហើយ តើប្រតិបត្តិករទីផ្សារមូលបត្រទាំងនោះ គោរពទៅតាមលក្ខខណ្ឌច្បាប់ និងបទប្បញ្ញត្តិផ្សេងៗដែលកំណត់ដោយ **គ.ម.ក** បានត្រឹមត្រូវដែរឬទេ ។ ប្រសិនបើធ្វើការស៊ើបអង្កេត និងពិនិត្យទៅឃើញថា ក្រុមហ៊ុនមូលបត្រ និង ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ព្រមទាំងប្រតិបត្តិករទីផ្សារមូលបត្រទាំងនោះមិនបានគោរពទៅនឹងលក្ខខណ្ឌនៃច្បាប់ និងបទប្បញ្ញត្តិរបស់ **គ.ម.ក** កំណត់ទេនោះ អគ្គនាយកនៃ **គ.ម.ក** អាចចាត់វិធានការសមស្របចំពោះអ្នកកាន់អាជ្ញាប័ណ្ណ និងបុគ្គលដែលទទួលការអនុញ្ញាតពី **គ.ម.ក** ដោយធ្វើការណែនាំទៅដល់អ្នកកាន់អាជ្ញាប័ណ្ណ និងបុគ្គលដែលទទួលការអនុញ្ញាត ឲ្យធ្វើការគោរពទៅនឹងលក្ខខណ្ឌនៃច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទៀតដែលកំណត់ដោយ **គ.ម.ក** ។ ប៉ុន្តែ ប្រសិនធ្វើការណែនាំរួចហើយ អ្នកកាន់អាជ្ញាប័ណ្ណ និងបុគ្គលដែលទទួលការអនុញ្ញាត្តនោះនៅតែមិនអនុវត្តតាមការណែនាំទៀត ដំណាក់កាលបន្ទាប់ អគ្គនាយកនៃ **គ.ម.ក** អាចចាត់វិធានការដោយធ្វើការព្យួរ ឬ ធ្វើការដកហូតអាជ្ញាប័ណ្ណ ឬ ដកហូតការអនុញ្ញាតពីក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ ព្រមទាំងប្រតិបត្តករទីផ្សារមូលបត្រនោះវិញ មិនឲ្យធ្វើសកម្មភាពចំពោះវិស័យមូលបត្របន្តទៀតឡើយ ។ ប៉ុន្តែមុននឹងធ្វើការដកហូតអាជ្ញាប័ណ្ណពីក្រុមហ៊ុនមូលបត្រ ឬ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ព្រមទាំងការដកហូតការអនុញ្ញាតពីប្រតិបត្តិករទីផ្សារមូលបត្រទាំងនោះ អគ្គនាយកនៃ **គ.ម.ក** ត្រូវសុំការអនុញ្ញាតពិគ្រោះយោបល់ និងប្រជុំពេញអង្គរបស់ **គ.ម.ក** ជាមុនសិន[១] ។

ម្យ៉ាងទៀត អគ្គនាយកនៃ **គ.ម.ក** មានសិទ្ធិពេញលេញ ដើម្បីគ្រប់គ្រង និងអនុវត្តការងារដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ ដោយអគ្គនាយកនៃ **គ.ម.ក** មានមុខងារ និង ភារកិច្ចបន្ថែម ដូចជា[២]៖

-គ្រប់គ្រងការងារប្រចាំថ្ងៃរបស់ **គ.ម.ក.**

---

[១] មាត្រា ៨ អនុក្រឹត្យស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា

[២] មាត្រា ២ អនុក្រឹត្យស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា

-រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្រជូនប្រធាន និងសមាជិកនៃ **គ.ម.ក** ដើម្បីពិនិត្យ និងសម្រេច

-ចុះកិច្ចសន្យា និងអនុសញ្ញាផ្សេងៗក្នុងនាម **គ.ម.ក** ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក**

-ជាតំណាងរបស់ **គ.ម.ក** ក្នុងទំនាក់ទំនងជាមួយតតីយជន ដូចជាស្ថាប័នជាតិ និងអន្តរជាតិ ព្រមទាំងវិស័យឯកជននានា ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យមូលបត្រ

-ជាតំណាងឲ្យ **គ.ម.ក** នៅចំពោះមុខតុលាការ

-រៀបចំកិច្ចប្រជុំរបស់ **គ.ម.ក**

-គ្រប់គ្រងចំណូល និងចំណាយរបស់ **គ.ម.ក**

-ធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំជូនប្រធាន និង សមាជិកនៃ **គ.ម.ក** ដើម្បីពិនិត្យ និងសម្រេច

-អនុវត្តការងារផ្សេងៗទៀត ទៅតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក.**។

**ខ.សិទ្ធិអំណាចរបស់អគ្គនាយក នៃ គ.ម.ក**

ក្នុងគោលបំណងអនុវត្តតាមមុខងារ ដែលមានចែងក្នុងច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន ឲ្យមានប្រសិទ្ធិភាពទទួលបាននូវលទ្ធផលជាវិជ្ជមាននោះ នៅក្នុងច្បាប់ដដែលនេះផងដែ ក៏បានផ្តល់សិទ្ធិអំណាចទៅដល់អគ្គនាយកនៃ **គ.ម.ក.** មានសិទ្ធិអំណាចនៅក្នុងការគ្រប់គ្រងរាល់សកម្មភាពរបស់បុគ្គលដែលទទួលបានទទួលបានអាជ្ញាប័ណ្ណ ឬ ទទួលការអនុញ្ញាតពី **គ.ម.ក** ដើម្បីធ្វើសកម្មភាពនៅក្នុងវិស័យមូលបត្រ និង សិទ្ធិអំណាចនៅក្នុងការចាត់ចែង និង គ្រប់គ្រង **គ.ម.ក** ។ នៅក្នុងករណីដែលមានបទល្មើសកើតឡើងដែលផ្ទុយទៅនឹងច្បាប់ អគ្គនាយក នៃ **គ.ម.ក** អាចមានសិទ្ធិក្នុងការផ្តល់សិទ្ធិអំណាចចំពោះបុគ្គលិករបស់ **គ.ម.ក** និងបុគ្គលផ្សេងទៀតធ្វើការចុះស៊ើបអង្កេតទៅលើបុគ្គលដែលទទួលបានអាជ្ញាប័ណ្ណ ដើម្បីធ្វើជាក្រុមហ៊ុនមូលបត្រ ឬ បុគ្គលដែលទទួលបានការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ព្រមទាំងក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុត ដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈ ឬ ដាក់តម្លៃនៅក្នុងទីផ្សារមូលបត្រ ដោយធ្វើការប្រមូលភស្តុតាងពីបុគ្គលដែលនៅក្រោមការស៊ើបអង្កេត ហើយបន្ទាប់មកត្រូវរាយការណ៍ជាបន្ទាន់អំពីលទ្ធផលដែលខ្លួនបានស៊ើបអង្កេតជូនប្រធាន និងសមាជិកទាំងអស់នៃ **គ.ម.ក** ដោយភ្ជាប់មកជាមួយនូវអនុសាសន៍ ដើម្បីធ្វើការចាត់ចែងបន្ត ហើយបញ្ជូនសំណុំរឿង

ដែលបានស៊ើបអង្កេតថាមានបទល្មើសនោះ ទៅព្រះរាជអាជ្ញា ដើម្បីធ្វើការចោទប្រកាន់ និងធ្វើការផ្សព្វផ្សាយពីឈ្មោះ និងសកម្មភាពរបស់បុគ្គលដែលរកឃើញមានពិរុទ្ធភាពពីបទល្មើស ដែលមានចែងក្នុងច្បាប់ ព្រមទាំងដាក់ទណ្ឌកម្មខាងវិន័យដែលកំណត់ដោយ **គ.ម.ក**[៣] ។

ដើម្បីបន្ថែមទៅលើវិធានការដែលកំណត់ដោយ **គ.ម.ក.** ដាក់អនុវត្តនៅក្រមបទប្បញ្ញត្តិនៃច្បាប់នេះអគ្គនាយកនៃ **គ.ម.ក** មានសិទ្ធិអំណាចបន្ថែមទៀតនៅក្នុងការអនុវត្តមុខងារនៅក្នុងករណីដែលពិនិត្យឃើញថាមានបទល្មើស និងពិនិត្យឃើញថា នីតិបុគ្គលមានអាជ្ញាប័ណ្ណ ឬនីតិបុគ្គលប្រតិស្រុតអាចជាអសាធនីយ ឬ មានបញ្ហាផ្នែកហិរញ្ញវត្ថុ ដូចជា[៤]៖

-ចេញលិខិតព្រមានទៅបុគ្គលដែលពិនិត្យឃើញថា បានប្រព្រឹត្តល្មើសនឹងច្បាប់ ឬ ច្បាប់ដែលពាក់ព័ន្ធផ្សេងទៀត

-ចេញបទបញ្ជាឲ្យបុគ្គលដែលពិនិត្យឃើញថា បានប្រព្រឹត្តល្មើសនឹងច្បាប់នេះ ឬ ច្បាប់ដែលពាក់ព័ន្ធផ្សេងទៀតធ្វើការជួសជុលសំណងព្យសនកម្ម ស្របតាមច្បាប់នេះ និងច្បាប់ដទៃទៀតទៅតាមអំពើល្មើសដែលបុគ្គលនោះ បានប្រព្រឹត្តនៅកាលបរិច្ឆេទជាក់លាក់មួយ

-ស្នើសុំទៅតុលាការមានសមត្ថកិច្ច ដើម្បីចេញដីកាតម្រូវឲ្យបុគ្គលដែលពិនិត្យ ឃើញថាបានប្រព្រឹត្តិល្មើសនឹងច្បាប់នេះ ឬ ច្បាប់ពាក់ព័ន្ធផ្សេងទៀតឲ្យអនុវត្តតាមច្បាប់ និងឲ្យជួសជុលសំណងព្យសនកម្មតាមការកំណត់របស់តុលាការដែលមានអំណាចឆន្ទានុសិទ្ធិសម្រេច

-ចាត់វិធានការផាកពិន័យអន្តរការណ៍ ឬ ដាក់ទណ្ឌកម្មរដ្ឋបាលលើបុគ្គល ដែលពិនិត្យឃើញថាបានប្រព្រឹត្តិល្មើសនឹងលក្ខខណ្ឌនៃច្បាប់ ។ ដាក់ទណ្ឌកម្មរដ្ឋបាលត្រូវកំណត់ដោយ **គ.ម.ក.**

-ព្យួរជាបណ្ដោះអាសន្ន ឬ បញ្ឈប់ការងាររបស់អគ្គនាយក នាយក សមាជិក គ្រប់គ្រង ឬ បុគ្គលិកជាន់ខ្ពស់របស់នីតិបុគ្គលមានអាជ្ញាប័ណ្ណ ឬ នីតិបុគ្គលប្រតិស្រុត

-ជ្រើសរើស និង ផ្ដល់អំណាចដល់បុគ្គលដែលមានសមត្ថភាពសមស្រប ដើម្បីពិនិត្យមើលសកម្មភាពអាជីវកម្ម ឬ សកម្មភាពពាក់ព័ន្ធផ្សេងទៀតរបស់នីតិបុគ្គលមានអាជ្ញាប័ណ្ណ ឬ នីតិបុគ្គលប្រតិស្រុត ។ បុគ្គលនោះត្រូវធ្វើការរាយការណ៍ទៅឲ្យអគ្គនាយក **គ.ម.ក.** តាមលក្ខខណ្ឌដែលមានក្នុងកិច្ចសន្យាជាមួយអគ្គនាយកនៃ **គ.ម.ក.** និង

-ដាក់កំហិត ឬ បញ្ឈប់សកម្មភាពជាក់លាក់ ឬ ទូទៅដែលធ្វើឡើងដោយនីតិបុគ្គលមាន

[៣] មាត្រា ៩ ច្បាប់ស្ដីពីការបោះផ្សាយ និង ការជួញដូរមូលបត្រមហាជន

[៤] មាត្រា ៩៥ ច្បាប់ស្ដីពីការបោះផ្សាយ និង ការជួញដូរមូលបត្រមហាជន

អាជ្ញាប័ណ្ណ ឬ នីតិបុគ្គលប្រតិស្រុត ទោះបីជាសកម្មភាពនោះ ត្រូវបានធ្វើឡើងស្រប ឬ មិនស្រប តាមលក្ខខណ្ឌនៃអាជ្ញាប័ណ្ណ ឬ នៃការអនុញ្ញាតដែលអគ្គនាយកនៃ**គ.ម.ក.** ផ្តល់ឲ្យក៏ដោយ។

-ក្នុងករណីដែល **គ.ម.ក.** ពិនិត្យឃើញថា នីតិបុគ្គលមានអាជ្ញាប័ណ្ណ ឬ នីតិបុគ្គលប្រតិស្រុត អាចជាអសាធនីយ ឬមានបញ្ហាផ្នែកហិរញ្ញវត្ថុ អគ្គនាយកនៃ **គ.ម.ក.** អាចប្រើប្រាស់អំណាចរបស់ខ្លួន ដើម្បីតែងតាំង ឬស្នើសុំទៅតុលាការ ដើម្បីតែងតាំងបុគ្គលដែលមានសមត្ថភាពសមស្របឲ្យធ្វើជាអភិបាលបណ្តោះអាសន្ន ដើម្បីគ្រប់គ្រង និង រៀបចំឡើងវិញ ឬ ជម្រះបញ្ជីនីតិបុគ្គលនោះស្របតាមច្បាប់ស្តីពីក្ស័យធននៃព្រះរាជាណាចក្រកម្ពុជា ឬបទប្បញ្ញត្តិផ្សេងៗទៀត ដែលមានចែងក្នុងអនុក្រឹត្យ ដោយអនុលោមតាមច្បាប់នេះ។ ក្នុងករណីដែលមានទំនាស់រវាងបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិក្ស័យធន ត្រូវយកបទប្បញ្ញត្តិនៃច្បាប់នេះមកអនុវត្ត។

## ផ្នែកទី ២ តួនាទី និង ភារកិច្ចកម្រិតជំនាញរបស់គណៈកម្មការមូលបត្រកម្ពុជា

នៅក្នុងដំណើរការប្រព្រឹត្តទៅរបស់ **គ.ម.ក** ក្រៅពីមានតួនាទី និងភារកិច្ចរបស់ថ្នាក់ដឹកនាំរួចមកហើយនោះ គឺ **គ.ម.ក** នៅមាននាយកដ្ឋានបច្ចេកទេស និង អង្គភាពបន្ថែមទៀត ដែលនាយកដ្ឋាន និងអង្គភាពនេះចំណុះអោយ **គ.ម.ក** ដោយនាយកដ្ឋាន និងអង្គភាពទាំងនេះមានតួនាទីភារកិច្ចរៀងៗខ្លួន ដើម្បីធ្វើឲ្យ **គ.ម.ក** អាចដំណើរការទៅបានដោយរលូន ដែលនាយកដ្ឋានបច្ចេកទេស និងអង្គភាពទាំងអស់នេះមានដូចជា៖

### កថាខណ្ឌទី ១ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

យោងទៅតាមមាត្រា ៦ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មការមូលបត្រកម្ពុជា បានកំណត់អំពីមុខងារ និងភារកិច្ចរបស់នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ដូចខាងក្រោម៖

-រៀបចំផែនការ និងថវិការរបស់ **គ.ម.ក**

-គ្រប់គ្រងកិច្ចការរដ្ឋបាល

-ផ្គត់ផ្គង់ និងជួសជុលសម្ភារៈបរិក្ខាការិយាល័យ

-ចាត់ចែងការងារពិធីការ

-ធ្វើទំនាក់ទំនងជាមួយស្ថាប័នរដ្ឋ ឬឯកជននានា

-រៀបចំគោនយោបាយ គ្រប់គ្រង និងជ្រើសរើសបុគ្គលិក

-រៀបចំតារាងប្រាក់បៀវត្សន៍ និងប្រាក់ឧបត្ថម្ភនានាដល់មន្ត្រីនៃ **គ.ម.ក**

-គ្រប់គ្រង និងផ្តល់សេវាកម្មបច្ចេកវិទ្យាពត៌មាន

-អនុវត្តការងារផ្សេងៗ ទៀតតាមការប្រគល់ជូនរបស់អគ្គនាយកនៃ **គ.ម.ក** ។ ហើយម្យ៉ាងទៀត នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មានការិយាល័យ ចំណុះចំនួន ០៣ ទៀត ដើម្បីជួយសម្រួលដល់កិច្ចការរបស់នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ។ ដែលការិយាល័យទាំង ០៣ នោះដូចជាការិយាល័យរដ្ឋបាល និងបុគ្គលិក ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ និងការិយាល័យគ្រប់គ្រងពត៌មានវិទ្យា។

ដូច្នេះ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ គឺបានចូលរួមយ៉ាងសកម្ម នៅក្នុងការធ្វើឲ្យដំណើរការរបស់ស្ថាប័ន **គ.ម.ក** ដើម្បីធ្វើលិខិតរដ្ឋបាលផ្សេងៗទាក់ទងទៅនឹងស្ថាប័នរដ្ឋ ឬ ឯកជននានា ទាក់ទងទៅនឹងវិស័យមូលបត្រ និង រៀបចំផែនការថវិកាប្រើប្រាស់សម្រាប់ **គ.ម.ក** ដាក់ជូនទៅអគ្គនាយកនៃ **គ.ម.ក** ដើម្បីសម្រេច ព្រមទាំងគ្រប់គ្រងបរិក្ខារសម្ភារៈការិយាល័យនៅក្នុងស្ថាប័ន ។

### កថាខណ្ឌទី ២ នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និង ទំនាក់ទំនងអន្តរជាតិ

យោងទៅតាមមាត្រា៧ នៃនៃអនុក្រឹត្យស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈកម្មការមូលបត្រកម្ពុជា បានកំណត់អំពីមុខងារ និងភារកិច្ចរបស់នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវពីយុទ្ធសាស្ត្រនានា ដើម្បីអភិវឌ្ឍន៍វិស័យមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា
- សិក្សាស្រាវជ្រាវលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធច្បាប់ និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍវិស័យមូលបត្រ
- រៀបចំយុទ្ធសាស្ត្រ ដើម្បីជំរុញឲ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- សិក្សាវាយតម្លៃ និងផ្តល់យោបល់លើការបង្កើតឧបករណ៍ហិរញ្ញវត្ថុថ្មី មុននឹងអនុញ្ញាតឲ្យបោះផ្សាយនៅលើទីផ្សារ
- រៀបចំកម្មវិធីបណ្តុះបណ្តាលដល់សាធារណជន និងអ្នកចូលរួមនានាក្នុងវិស័យមូលបត្រ
- ធ្វើទំនាក់ទំនងជាមួយនិយ័តករមូលបត្រនៃបណ្តាប្រទេសក្នុងតំបន់ និងនៅក្នុងពិភពលោក
- ចូលរួមក្នុងវេទិកាជាតិ និងអន្តរជាតិពាក់ព័ន្ធនានា
- អនុវត្តការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយកនៃ **គ.ម.ក ។** ហើយ

ម្យ៉ាងទៀត នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ មានការិយាល័យ ចំណុះចំនួន ០៣ ទៀត ដើម្បីជួយសម្រួលដល់កិច្ចការរបស់នាយកដ្ឋាននេះ ។ ដែលការិយាល័យទាំង ០៣ នោះមានដូចជា៖ ការិយាល័យស្រាវជ្រាវ និង អភិវឌ្ឍន៍ទីផ្សារមូលបត្រ ការិយាល័យបណ្តុះបណ្តាល និង ផ្សព្វផ្សាយ និង ការិយាល័យទំនាក់ទំនងអន្តរជាតិ ។

ដូច្នេះ នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ គឺពិតជាបានចូលរួមនៅក្នុងការធ្វើឲ្យ **គ.ម.ក** មានការរីកចម្រើន ដោយធ្វើការស្វែងរកយុទ្ធសាស្ត្រនានា ដើម្បីធ្វើឲ្យវិស័យមូលបត្រមានការអភិវឌ្ឍ និងចូលរួមបង្កើតបទដ្ឋានដែលពាក់ព័ន្ធវិស័យមូលបត្រ ហើយធ្វើការអប់រំនឹងផ្សព្វផ្សាយនូវបទដ្ឋាននានាទៅដល់សាធារណជនឲ្យយល់ដឹងអំពីវិស័យនេះ ព្រមទាំងធ្វើការបញ្ជូនអ្នកជំនាញដែលពាក់ព័ន្ធ ដើម្បីទៅចូលរួមក្នុងវេទិកាជាតិ និងអន្តរជាតិ គោលបំណងក្នុងការទទួលបាននូវចំណេះដឹងបន្ថែម និងបទពិសោធន៍ថ្មីៗ ដើម្បីជាទឡ្ហីករណ៍ក្នុងការធ្វើឲ្យវិស័យមូលបត្រនៅកម្ពុជា មានការអភិឌ្ឍន៍នាពេលអនាគតដ៏ខ្លីនាពេលខាងមុខ។

**កថាខណ្ឌទី៣ នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ**

យោងទៅតាមមាត្រា៨ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មការមូលបត្រកម្ពុជា បានកំណត់អំពីមុខងារ និងភារកិច្ចរបស់នាយកដ្ឋានគ្រប់គ្រងការបោះផ្សារយលក់មូលបត្រដូចខាងក្រោម៖

- រៀបចំលក្ខខណ្ឌតម្រូវនានា សម្រាប់ផ្តល់ការអនុញ្ញាតឲ្យក្រុមហ៊ុននានាបោះផ្សាយលក់មូលបត្រជាសាធារណៈ
- រៀបចំលក្ខខណ្ឌតម្រូវនានា ទាក់ទងនឹងអភិបាលកិច្ច និង ការគ្រប់គ្រងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ត្រួតពិនិត្យការអនុវត្តលក្ខខណ្ឌតម្រូវនានា ទាក់ទងនឹងអភិបាលកិច្ច និង ការគ្រប់គ្រងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈជាប្រចាំ
- ត្រួតពិនិត្យការអនុវត្តតាមស្តង់ដារគណនេយ្យ និង សនវកម្មនៃព្រះរាជាណាចក្រកម្ពុជារបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ត្រួតពិនិត្យ និងផ្តល់យោបល់លើការស្នើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ពិនិត្យ និងផ្តល់យោបល់លើការស្នើសុំចុះបញ្ជី ឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានបន្ថែម ឯកសារផ្តល់ព័ត៌មានជំនួស និង សេចក្តីថ្លែងនានា ដែលពាក់ព័ន្ធនឹងធុរកិច្ចមូលបត្រ

- ចុះបញ្ជីឯកសារព័ត៌មានឯកសារផ្តល់ព័ត៌មានបន្ថែម ឯកសារផ្តល់ព័ត៌មានជំនួស និង សេចក្តីថ្លែងនានារបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ពិនិត្យ និង ផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានបន្ថែមឯកសារ ផ្តល់ព័ត៌មានជំនួស និងសេចក្តីថ្លែងនានាដែលពាក់ព័ន្ធនឹងធុរកិច្ចមូលបត្រតាមប្រព័ន្ធ អេឡិចត្រូនិច ឬ/និងតាមប្រព័ន្ធផ្សព្វផ្សាយសាធារណៈ
- ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ ឬ/និង របាយការណ៍អាជីវកម្មរបស់ក្រុមហ៊ុនបោះ ផ្សាយលក់មូលបត្រជាសាធារណៈ
- ត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែង របស់ក្រុមហ៊ុនស្នើសុំបោះផ្សាយលក់មូលបត្រជា សាធារណៈ ប្រសិនបើមានការចាំបាច់ក្នុងក្របខ័ណ្ឌការងារ
- គ្រប់គ្រងយន្តការបោះផ្សាយលក់មូលបត្រជាសាធារណៈ
- បញ្ជូនសំណុំរឿងសង្ស័យថាមានការប្រព្រឹត្តិល្មើសនឹងច្បាប់ និង បទប្បញ្ញត្តិពាក់ព័ន្ធ នឹងការបោះផ្សាយលក់មូលបត្រជាសាធារណៈ ទៅនាយកដ្ឋានកិច្ចការគតិយុត្ត ដើម្បី ស៊ើបអង្កេតបន្ត
- អនុវត្តការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយកនៃ **គ.ម.ក** ។

ហើយម្យ៉ាងទៀត នាយកដ្ឋានគ្រប់គ្រងបោះផ្សាយលក់មូលបត្រ មានការិយាល័យចំណុះចំនួន ០៣ ទៀត ដើម្បីជួយសម្រួលដល់កិច្ចការរបស់នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ ។ ដែលការិយាល័យ ទាំង ០៣ នោះដូចជា ការិយាល័យបោះផ្សាយមូលបត្រ និង ឯកសារផ្តល់ព័ត៌មាន ការិយាល័យអភិបាលកិច្ចសាជីវកម្ម និង ការិយាល័យត្រួតពិនិត្យកិច្ចការគណនេយ្យ ។

ដូច្នេះ នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ ដើរតួនៅក្នុងការរៀបចំលក្ខខណ្ឌតម្រូវផ្សេងៗ និង ចូលរួមនៅក្នុងការត្រួតពិនិត្យចំពោះក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ថាតើបានគោរពនូវលក្ខខណ្ឌរបស់ **គ.ម.ក** ដែលបានតម្រូវហើយឬនៅ ហើយធ្វើការបញ្ជូនសំណុំរឿងដែលសង្ស័យបានប្រព្រឹត្តផ្ទុយនឹងច្បាប់ ព្រមទាំងបទប្បញ្ញត្តិ ដើម្បីធ្វើការបញ្ជូនករណីសង្ស័យនោះ ទៅអោយនាយកដ្ឋានកិច្ចការគតិយុត្ត ក្នុងការចាត់នីតិវិធីស៊ើបអង្កេតបន្ត ។

**កថាខណ្ឌទី ៤ នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ**

យោងទៅតាមមាត្រា៩ នៃអនុក្រឹត្យស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈកម្មការមូលបត្រកម្ពុជា បានកំណត់អំពីមុខងារ និង ភារកិច្ចរបស់នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រដូចខាងក្រោម៖

- រៀបចំបទប្បញ្ញត្តិ ឬ លក្ខខណ្ឌនានា សម្រាប់ផ្តល់ការអនុញ្ញាតឲ្យធ្វើប្រតិបត្តិការជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីដាក់សុំការពិនិត្យ និង សម្រេចពីអគ្គនាយកនៃ **គ.ម.ក**
- ពិនិត្យ និងផ្តល់យោបល់លើពាក្យស្នើសុំការអនុញ្ញាត ដើម្បីធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- ត្រួតពិនិត្យនឹងតាមដានលើការផ្គត់ផ្គង់ប្រព័ន្ធជួញដូរមូលបត្រ និងប្រតិបត្តិការផ្សេងៗទៀតរបស់ប្រតិបត្តិករទីផ្សារមូលបត្រ
- ត្រួតពិនិត្យ និងតាមដានលើប្រតិបត្តិការរបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់
- ត្រួតពិនិត្យ និង តាមដានលើប្រតិបត្តិការរបស់ប្រតិបត្តិកររក្សាទុកមូលបត្រ
- ត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែងតាមការចាំបាច់ ចំពោះប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បញ្ជូនសំណុំរឿងសង្ស័យថាមានការប្រព្រឹត្តិល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ទៅនាយកដ្ឋានកិច្ចការគតិយុត្ត ដើម្បីធ្វើការស៊ើបអង្កេតបន្ត
- អនុវត្តការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយកនៃ **គ.ម.ក** ។

ហើយម្យ៉ាងទៀត នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ មានការិយាល័យចំណុះចំនួន ០៣ ទៀតដើម្បីជួយសម្រួលដល់កិច្ចការរបស់នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ។ ដែលការិយាល័យទាំង ០៣ នោះមានដូចជា ការិយាល័យត្រួតពិនិត្យប្រតិបត្តិការទីផ្សារមូលបត្រ ការិយាល័យត្រួតពិនិត្យប្រព័ន្ធផាត់ទាត់ និង ទូទាត់មូលបត្រ និង ការិយាល័យត្រួតពិនិត្យសេវារក្សាទុកមូលបត្រ ។

ដូច្នេះ នាយកដ្ឋាត្រួតពិនិត្យទីផ្សារមូលបត្រ គឺជាអ្នករៀបចំបទប្បញ្ញត្តិ និងលក្ខខណ្ឌនានាទាក់ទងនៅនឹងការផ្តល់យោបល់ ឬ ការអនុញ្ញាត្តឲ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ ឬ ទូទាត់ និងរក្សាទុកមូលបត្រ ដើម្បីដាក់ពាក្យស្នើសុំពិនិត្យ និងសម្រេចពីអគ្គ-នាយកនៃ **គ.ម.ក** ព្រមទាំងធ្វើការត្រួតពិនិត្យទៅលើសកម្មភាពរបស់ប្រតិបត្តករទីផ្សារមូលបត្រ ដោយចុះត្រួតពិនិត្យដល់ទីកន្លែងតាមការចាំបាច់ ហើយប្រសិនបើពិនិត្យឃើញថាមានសង្ស័យក្នុងការប្រព្រឹត្តិបទល្មើសពីច្បាប់ និងបទប្បញ្ញត្តិដែលកំណត់ដោយ **គ.ម.ក** នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រត្រូវបញ្ជូនសំណុំរឿងដែលសង្ស័យនោះទៅនាយកដ្ឋានកិច្ចការគតិយុត្ត ដើម្បីចាត់នីតិវិធីបន្ទាប់ ។

**កថាខណ្ឌទី ៥ នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ**

យោងទៅតាមមាត្រា១០ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មការ-មូលបត្រកម្ពុជា បានកំណត់អំពីមុខងារ និង ភារកិច្ចដូចខាងក្រោម៖

- រៀបចំបទប្បញ្ញត្តិ ឬ លក្ខខណ្ឌតម្រូវនានាសម្រាប់ផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និង អ្នកចូលរួមដទៃទៀតក្នុងទីផ្សារ ដើម្បីដាក់ពាក្យសុំការពិនិត្យ និងសម្រេចពីអគ្គនាយកនៃ **គ.ម.ក.**
- ពិនិត្យ និង ផ្តល់យោបល់លើសំណើសុំអាជ្ញាប័ណ្ណ ដើម្បីធ្វើជាក្រុមហ៊ុនមូលបត្រឈ្មួញ
- ជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និង អ្នកចូលរួមដទៃទៀតក្នុងទីផ្សារ
- ត្រួតពិនិត្យ និង តាមដាននូវប្រតិបត្តិការរបស់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និង អ្នកចូលរួមដទៃទៀតក្នុងទីផ្សារ
- ត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែងតាមការចាំបាច់ នូវប្រតិបត្តិការរបស់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ
- បញ្ជូនសំណុំរឿងសង្ស័យថា មានការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ
- ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និង អ្នកចូលរួមដ៏ទៃទៀតក្នុងទីផ្សារ ទៅនាយកដ្ឋានកិច្ចការគតិយុត្ត ដើម្បីស៊ើបអង្កេត
- អនុវត្តការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយកនៃ **គ.ម.ក** ។

ហើយម្យ៉ាងទៀត នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ មានការិយាល័យចំណុះចំនួន ០៣ ទៀត ដើម្បីជួយសម្រួលដល់កិច្ចការរបស់នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ ។ ដែលការិយាល័យទាំង ០៣ នោះមានដូចជា ការិយាល័យសម្របសម្រួល និង អាជ្ញាប័ណ្ណ ការិយាល័យត្រួតពិនិត្យលើឯកសារ និង ការិយាល័យត្រួតពិនិត្យដល់ទីកន្លែង ។

ដូច្នេះ នាយកដ្ឋានត្រួតពិនិត្យអន្តរការីទីផ្សារមូលបត្រ គឺជាអ្នករៀបចំបទប្បញ្ញត្តិ និងលក្ខខណ្ឌនានាទាក់ទងនៅនឹងការផ្តល់យោបល់ ឬ ការផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ ឬ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ ដើម្បីដាក់ការស្នើសុំពិនិត្យ និងសម្រេចពីអគ្គនាយកនៃ **គ.ម.ក** ព្រមទាំងធ្វើការត្រួតពិនិត្យទៅលើសកម្មភាពរបស់ក្រុមហ៊ុន

មូលបត្រ ឬ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារមូលបត្រ ដោយចុះត្រួតពិនិត្យដល់ទីកន្លែងតាមការចាំបាច់ ហើយប្រសិនបើពិនិត្យឃើញថាមានសង្ស័យក្នុងការប្រព្រឹត្តិបទល្មើសពីច្បាប់នឹងបទប្បញ្ញត្តិដែលកំណត់ដោយ **គ.ម.ក** នាយកដ្ឋានត្រួតពិនិត្យអន្តរការីទីផ្សារមូលបត្រត្រូវបញ្ជូនសំណុំរឿងដែលសង្ស័យនោះ ទៅនាយកដ្ឋានកិច្ចការគតិយុត្ត ដើម្បីចាត់នីតិវិធីបន្ទាប់ ។

**កថាខណ្ឌទី ៦ នាយកដ្ឋានកិច្ចការគតិយុត្ត**

យោងទៅតាមមាត្រា១១ នៃអនុក្រឹត្យស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈកម្មការមូលបត្រកម្ពុជា បានកំណត់អំពីមុខងារ និង ភារកិច្ចដូចខាងក្រោមៈ

- ពិនិត្យ និង ផ្តល់យោបល់លើវិធានប្រតិបត្តិការរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីដាក់សុំការពិនិត្យ និងសម្រេចពីអគ្គនាយកនៃ **គ.ម.ក**
- ពិនិត្យ និងផ្តល់យោបល់លើវិធានប្រតិបត្តិការដែលស្នើដោយស្ថាប័នស្វ័យនិយ័តករ
- រៀបចំបទប្បញ្ញាត្តិចាំបាច់នានា និង លើកសំណើធ្វើវិសោធនកម្មច្បាប់ និង បទប្បញ្ញត្តិផ្សេងៗ ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍វិស័យមូលបត្រ
- ពង្រឹងការអនុវត្តច្បាប់ ឬ បទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រ
- ទទួលពាក្យបណ្តឹង និងធ្វើការស៊ើបអង្កេតពាក់ព័ន្ធនឹងប្រតិបត្តិការបោះផ្សាយ និងជួញដូរមូលបត្រដែលល្មើសច្បាប់ ឬ មិនប្រក្រតី ទាំងនៅក្នុងទីផ្សារដំបូង និងនៅលើទីផ្សារបន្ទាប់
- ពិនិត្យ និងផ្តល់យោបល់ ដើម្បីចាត់វិធានការដាក់ពិន័យនានាពាក់ព័ន្ធនឹងបុគ្គល ប្រព្រឹត្តិល្មើសនឹងច្បាប់ និង បទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ
- សម្រុះសម្រួល ដោះស្រាយវិវាទរវាងអ្នកចូលរួមក្នុងទីផ្សារមូលបត្រ
- ចាត់វិធានការផាកពិន័យអន្តរការណ៍ លើបុគ្គលប្រព្រឹត្តិល្មើសនឹងច្បាប់ និង បទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ
- រៀបចំសំណុំរឿងពាក់ព័ន្ធ ដើម្បីដាក់ពាក្យបណ្តឹងទៅតុលាការ
- អនុវត្តការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយកនៃ **គ.ម.ក** ។ ហើយ

ម្យ៉ាងទៀត នាយកដ្ឋានកិច្ចការគតិយុត្តមានការិយាល័យចំណុះចំនួន ០៣ ទៀត ដើម្បីជួយសម្រួលដល់កិច្ចការរបស់នាយកដ្ឋាននេះ ។ ដែលការិយាល័យទាំង ០៣ នោះមានដូចជា ការិយាល័យពង្រឹងការអនុវត្តច្បាប់ និងនីតិកម្ម ការិយាល័យទទួលពាក្យបណ្តឹង និងដោះស្រាយវិវាទ និង

ការិយាល័យស៊ើបអង្កេត ។

ដូច្នេះ នាយកដ្ឋានកិច្ចការគតិយុត្ត បានដើរតួយ៉ាងសកម្មនៅក្នុងការរៀបចំបទប្បញ្ញត្តិនានានៅក្នុងការអនុវត្តមុខងាររបស់ **គ.ម.ក** ក្នុងនាមជាអាជ្ញាធរ ដើម្បីធានាឲ្យបាននូវការគោរព និងអនុវត្តច្បាប់ចំពោះស្វ័យនិយ័តករ និងដើរតួជាធ្វើការស៊ើបអង្កេតទៅលើបទល្មើសដែលពាក់ព័ន្ធនឹងប្រតិបត្តការបោះផ្សាយ និងជួញដូរមូលបត្រណាដែលល្មើសនឹងច្បាប់ ថែមទាំងទទួលពាក្យបណ្ដឹងដែលបានដាក់មកដោយបុគ្គលដែលចូលរួមក្នុងទីផ្សារមូលបត្រ ធ្វើការសម្រុះសម្រួលដោះស្រាយវិវាទ ដែលកើតឡើងរវាងអ្នកចូលរួមក្នុងទីផ្សារមូលបត្រ ព្រមទាំងចាត់វិធានការនៅក្នុងការផាកពិន័យជាអន្តរការណ៍លើបុគ្គលដែលល្មើសនឹងច្បាប់នៅក្នុងវិស័យមូលបត្រ ។

## ផ្នែកទី ៣ អង្គភាពសវនកម្មផ្ទៃក្នុងរបស់ គ.ម.ក

ក្រៅពីនាយកដ្ឋានទាំង ៦ ដែលចំណុះអោយ **គ.ម.ក** ស្ថាប័នមួយនេះនៅមានអង្គភាពចំណុះចំនួនមួយទៀត គឺអង្គភាពសវនកម្មផ្ទៃក្នុង។ អង្គភាពសវនកម្មផ្ទៃក្នុង នៃគណៈកម្មការមូលបត្រកម្ពុជា ត្រូវទទួលខុសត្រូវអនុវត្តមុខងារឯករាជ្យស្របតាមស្តង់ដារ និងក្រមសីលធម៌វិជ្ជាជីវៈនៃសនវកម្មផ្ទៃក្នុង ដើម្បីពិនិត្យ វិភាគ និង វាយតម្លៃលើសកម្មភាពនៃនាយកដ្ឋានរបស់ **គ.ម.ក** ដោយផ្តល់នូវអនុសាសន៍ និងមតិយោបល់កែលំអ សំដៅជួយឲ្យគ្រប់បណ្តានាយកដ្ឋានទាំងនោះ បំពេញភារកិច្ចប្រកបដោយប្រសិទ្ធិភាពខ្ពស់។ ដើម្បីសម្រេចគោលដៅនេះ មន្ត្រីរបស់អង្គភាពសវនកម្មផ្ទៃក្នុងត្រូវមានសិទ្ធិសេរីភាពពេញលេញក្នុងការត្រួតពិនិត្យលើគ្រប់សកម្មភាព គ្រប់ផ្នែករាល់បញ្ជិកាកត់ត្រាទ្រព្យសម្បត្តិ និងបុគ្គលិក[៤៥] ។ ដែលអង្គភាពនេះដឹកនាំដោយផ្ទាល់របស់ ប្រធាន **គ.ម.ក** គឺរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយអង្គភាពសវនកម្មផ្ទៃក្នុងរបស់ **គ.ម.ក** មានមុខងារ និងភារកិច្ចដូចជា[៤៦]៖

- ពិនិត្យលើមុខងារ សកម្មភាព កម្មវិធី និង ប្រតិបត្តិការនានារបស់ **គ.ម.ក** ក្នុងការបរិច្ឆេទសមស្រប ដើម្បីកំណត់ការអនុវត្តឲ្យបានសមស្របតាមការរៀបចំផែនការ ការចេញបទបញ្ជា និង បទប្បញ្ញត្តិផ្សេងៗ ការចាត់តាំងការងារ និង ការត្រួតពិនិត្យដោយផ្អែកតាមគោលនយោបាយ ការណែនាំរបស់ថ្នាក់ដឹកនាំ និង នីតិវិធីជាធរមាន និង ស្របតាមគោលដៅរបស់ **គ.ម.ក**

[៤៥] ប្រការ ២ នៃប្រកាសស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុងនៃ គ.ម.ក
[៤៦] មាត្រា ១២ អនុក្រឹត្យស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា

- កំណត់ភាពសមស្រប និងប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងផ្នែកគណនេយ្យរដ្ឋបាល និងប្រតិបត្តិការនានារបស់ **គ.ម.ក**
- ពិនិត្យលើភាពដែលអាចជឿជាក់បាន និង ភាពពេញលេញនៃព័ត៌មាន ទិន្នន័យ និងវិធីសាស្ត្រ នៃការរៀបចំរបាយការណ៍ អំពីពត៌មាន និង ទិន្នន័យទាំងនេះក្នុងកាលបរិច្ឆេទសមស្រប
- ពិនិត្យលើប្រព័ន្ធដែលបានបង្កើតរួច ដើម្បីធានាភាពត្រឹមត្រូវតាមគោលនយោបាយ
- ពិនិត្យលើប្រព័ន្ធដែលបានបង្កើតរួច ដើម្បីធានាភាពត្រឹមត្រូវតាមគោលនយោបាយ ផែនការ នីតិវិធីច្បាប់ និង បទប្បញ្ញត្តិនានា ហើយលើកសំណើកែតម្រូវ និង កែលំអប្រសិនបើមានកំហុស
- ពិនិត្យលើមធ្យោបាយ ក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់ **គ.ម.ក**
- វាយតម្លៃភាពសន្សំសំចៃ និងប្រសិទ្ធភាពសេដ្ឋកិច្ចនៃការប្រើប្រាស់ធនធានរបស់ **គ.ម.ក** ហើយលើកសំណើដោះស្រាយ និងកែលំអការអនុវត្តប្រតិបត្តិការ
- ធ្វើសវនកម្មលើកិច្ចប្រតិបត្តិការចំណូលចំណាយថវិការបស់ **គ.ម.ក** ដើម្បីបញ្ជាក់ភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍សវនកម្មជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក** អំពីការប្រព្រឹត្តិទៅរបស់នាយកដ្ឋាន ឬ អង្គភាពដែលបានធ្វើសនវកម្មរួចហើយ
- ធ្វើរបាយការណ៍ អំពីសកម្មភាពការងាររបស់ខ្លួន ប្រចាំត្រីមាស និង ប្រចាំឆ្នាំ ដើម្បីផ្ញើរជូនប្រធាន និងសមាជិកនៃ **គ.ម.ក** ពិនិត្យ និង ផ្តល់ការណែនាំ
- ធ្វើសវនកម្មផ្ទៃក្នុង នៅពេលដែលមានការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ជាប្រធាននៃ **គ.ម.ក**
- រៀបចំផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ដើម្បីដាក់ជូនប្រធាន និង សមាជិកនៃ **គ.ម.ក** ពិនិត្យ និង សម្រេច
- សម្របសម្រួលការងារសនវកម្មផ្ទៃក្នុង ជាមួយអាជ្ញាធរសវនកម្មជាតិ ដើម្បីធានាដំណើរការឲ្យបានគ្រប់គ្រាន់ និង សមស្រប ជាពិសេសកាត់បន្ថយការងារស្ទួនគ្នា
- អនុវត្តការងារផ្សេងៗទៀត តាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ជាប្រធាននៃ **គ.ម.ក ។** មិនតែប៉ុណ្ណោះ អង្គភាពសវនកម្មផ្ទៃក្នុង នៃ

គណៈកម្មការមូលបត្រកម្ពុជា ត្រូវទទួលខុសត្រូវអនុវត្តមុខងារឯករាជ្យស្របតាមស្តង់ដារ និងក្រមសីលធម៌វិជ្ជាជីវៈនៃសវនកម្មផ្ទៃក្នុង ដើម្បីពិនិត្យ វិភាគ និងវាយតម្លៃលើសកម្មភាពនៃនាយកដ្ឋានរបស់ **គ.ម.ក** ដោយផ្តល់នូវអនុសាសន៍ដោយប្រសិទ្ធិភាពខ្ពស់។ ដើម្បីសម្រេចតាមគោលដៅនេះ មន្ត្រីរបស់អង្គភាពនៃសវនកម្មផ្ទៃក្នុងត្រូវមានសិទ្ធិសេរីភាពពេញលេញក្នុងការត្រួតនិត្យ លើគ្រប់សកម្មភាពគ្រប់ផ្នែក រាល់បញ្ជិកាកត់ត្រា ទ្រព្យសម្បត្តិ និងបុគ្គលិក ។ លើសពីនេះទៅទៀត ដើម្បីជួយសម្រួលដល់កិច្ចការនានារបស់អង្គភាពសវនកម្មផ្ទៃក្នុង នៅមានការិយាល័យចំណុះចំនួន ០២ ទៀតគឺ ទី ១ ការិយាល័យសនវកម្មទី ១ និងការិយាល័យសវនកម្មទី ២ ។

**កថាខណ្ឌទី ១ ការិយាល័យសវនកម្មទី ១**

ការិយាល័យសវនកម្មទី ០១ ត្រូវបានដឹកនាំដោយប្រធាន ១ រូប និង មានអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់ ហើយការិយាល័យនេះត្រូវទទួសខុសត្រូវកិច្ចការរដ្ឋបាល និងធ្វើសនវកម្មលើនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នាយកដ្ឋានកិច្ចការគតិយុត្ត និងនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ ។ ម្យ៉ាងទៀតការិយាល័យសវនកម្មទី ០១ មានតួនាទី និងភារកិច្ច ដូចជា[៧]៖

- ពិនិត្យឡើងវិញលើមុខងារ សកម្មភាព កម្មវិធី និងប្រតិបត្តការនានារបស់ **គ.ម.ក** ក្នុងការបរិច្ឆេទសមស្រប ដើម្បីកំណត់ការអនុវត្តឲ្យបានសមស្របតាមការរៀបចំផែនការ ការចេញបទបញ្ជា និងបទប្បញ្ញត្តិផ្សេងៗការចាត់តាំងការងារ និង ការត្រួតពិនិត្យ ដោយផ្អែក និងស្របតាមគោលដៅរបស់ **គ.ម.ក**
- កំណត់ភាពសមស្រប ភាពគ្រប់គ្រាន់ និង ប្រសិទ្ធិភាពនៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងផ្នែកគណនេយ្យរដ្ឋបាល និង ប្រតិបត្តិការរបស់ **គ.ម.ក**
- ពិនិត្យឡើងវិញលើភាពដែលអាចជឿជាក់បាន ភាពច្បាស់លាស់ ភាពទាន់ពេលវេលា និងភាពពេញលេញនៃព័ត៌មានហិរញ្ញវត្ថុ និងប្រតិបត្តិការ ព្រមទាំងវិធីសាស្ត្រដែលប្រើប្រាស់ក្នុងការកំណត់អត្តសញ្ញាណ ការវាស់វែង ចំណាត់ថ្នាក់ និងការរៀបចំរបាយការណ៍អំពីព័ត៌មានទាំងនោះ
- ពិនិត្យឡើងវិញលើប្រព័ន្ធដែលបានបង្កើតរួច ដើម្បីធានាភាពត្រឹមត្រូវតាមគោលនយោបាយ

[៧] ប្រការ ៨ នៃប្រកាសស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុងនៃ គ.ម.ក

- ផែនការ នីតិវិធីច្បាប់ និង បទប្បញ្ញត្តិនានាដែលលមានឥទ្ធិពលសំខាន់លើកិច្ចប្រតិបត្តិការ និង របាយកាណ៍ ហើយលើកសំណើកែលំអ ឬ កែតម្រូវប្រសិនបើមានកំហុស
- ពិនិត្យឡើងវិញលើការគ្រប់គ្រង ថែទាំការងារ និង ផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិរបស់ **គ.ម.ក**
- វាយតម្លៃភាពសន្សំសំចៃ និងប្រសិទ្ធិភាពសេដ្ឋកិច្ចនៃការប្រើប្រាស់ធនធានរបស់ **គ.ម.ក** ហើយលើកសំណើដោះស្រាយ និងកែលំអ
- ធ្វើសវនកម្មលើប្រតិបត្តិការចំណូល និងចំណាយ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃការអនុវត្តថវិការបស់ **គ.ម.ក** រួមទាំងភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ
- ធ្វើសវនកម្មលើការអនុវត្តកម្មវិធី និងគម្រោងចំណាយ ដោយធ្វើការប្រៀបធៀបលទ្ធផលជាមួយគោលដៅ និង គោលបំណងដែលបានដាក់ចេញ
- ចូលរួមបង្កើតផែនការ ការអភិវឌ្ឍន៍ និងធ្វើសវនកម្មលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីប្រព័ន្ធទាំងនោះឆ្លើយតបតាមគោលបំណង និងគោលដៅដែលបានគ្រោងទុក ហើយទទួលបានលទ្ធផលមានសុវត្ថិភាព និង ប្រសិទ្ធិភាពខ្ពស់
- ធ្វើសវនកម្មលើនីតិវិធី និងការអនុវត្តនីតិវិធី ដើម្បីធានាថា វិធានការដែលបានដាក់ចេញគឺក្នុងគោលបំណងការពារមិនឲ្យមានការកេងបន្លំ
- រៀបចំផែនការសវនកម្មប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ **គ.ម.ក** ពិនិត្យ និង សម្រេច
- ធ្វើសវនកម្មលើភាពសមស្របនៃការគ្រប់គ្រងធនធានមនុស្សរចនាសម្ព័ន្ធ ចំនួនមន្ត្រីជំនាញវិជ្ជាជីវៈឋានៈ តួនាទី និង ការលើកទឹកចិត្ត
- ធ្វើសវនកម្មលើភាពត្រឹមត្រូវ ភាពទាន់ពេល ភាពពេញលេញ នៃប្រព័ន្ធត្រួតពិនិត្យ ប្រព័ន្ធកត់ត្រាព័ត៌មាន និង កិច្ចបញ្ជិកាគណនេយ្យ
- ធ្វើសវនកម្មលើការអនុវត្តបទបញ្ជាផ្ទៃក្នុង ស្តីពីការគ្រប់គ្រងមន្ត្រីជំនាញគ្រប់ជាន់ថ្នាក់របស់ **គ.ម.ក** និង លើការអនុវត្តលក្ខន្តិកៈនៃមន្ត្រីរបស់ **គ.ម.ក**
- ធ្វើរបាយការណ៍សវនកម្មជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក** អំពីការប្រព្រឹត្តទៅរបស់នាយកដ្ឋានដែលបានធ្វើសវនកម្មរួច
- ផ្តល់សេចក្តីសន្និដ្ឋាន និង អនុសាសន៍ជូនប្រធាននាយកដ្ឋានដែលទទួលការធ្វើសវនកម្ម ដើម្បីធ្វើការកែលំអ ហើយរបាយការណ៍សវនកម្មពេញលេញត្រូវផ្តល់ជូនថ្នាក់ដឹកនាំ **គ.ម.ក** ពិនិត្យ និង ផ្តល់ការណែនាំ
- រក្សារបាយកាណ៍សវនកម្មឲ្យបានល្អសម្រាប់ជាមូលដ្ឋានតាមដាន ផ្ទៀងផ្ទាត់លើវឌ្ឍនភាព

នៃការអនុវត្តអនុសាសន៍កែលំអ

- ប្រមូល និង តាមដានជាប្រចាំនូវឯកសារគតិយុត្ត និង សកម្មភាពកែទម្រង់ផ្សេងៗរបស់នាយកដ្ឋាននីមួយៗ
- សហការជាមួយនាយកដ្ឋាននានា សំដៅកសាងមូលដ្ឋានព័ត៌មានឲ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីវាយតម្លៃឲ្យបានសុក្រឹត្យ
- ផ្តល់របាយការណ៍ប្រចាំឆ្នាំស្តីពីសវនកម្មការងារជូនថ្នាក់ដឹកនាំ **គ.ម.ក** ដើម្បីពិនិត្យ និងផ្តល់ការណែនាំ
- សម្របសម្រួលការងារសនវកម្មផ្ទៃក្នុងជាមួយនឹងអាជ្ញាធរសវនកម្មជាតិ ដើម្បីធានាដំណើរការសវនកម្មអោយបានគ្រប់គ្រាន់ និង សមស្រប ជាពិសេសកាត់បន្ថយការងារស្ទួនគ្នា
- រៀបចំរបាយការណ៍ជាប្រចាំពាក់ព័ន្ធនឹងការអនុវត្តការងាររបស់ការិយាល័យ។
- អនុវត្តការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធានអង្គភាព ។ ហើយក្រៅពីតួនាទី និង ភារកិច្ចដែលបានរៀបរាប់ខាងលើ ការិយាល័យទី១ ទទួលភារកិច្ចរដ្ឋបាលបន្ថែមរបស់អង្គភាពដូចជា៖

- សហការរៀបចំផែនការសកម្មភាពសវនកម្មប្រចាំឆ្នាំរបស់អង្គភាព និង រៀបចំរបាយការណ៍សរុប
- គ្រប់គ្រងលិខិតស្នាមរដ្ឋបាល និង គតិយុត្តិ ឯកសារបច្ចេកទេស និង ឯកសារសិក្សាស្រាវជ្រាវផ្សេងៗ
- គ្រប់គ្រងធនធានមនុស្ស ស្ថិតិមន្ត្រី ការផ្លាស់ប្តូរ ការរៀបចំតួនាទី ការងារសង្គមកិច្ច និង ការងារបណ្តុះបណ្តាល
- ធានាប្រក្រតីភាពកិច្ចការរដ្ឋបាលរបស់អង្គភាព ការគោរពវិន័យ សណ្តាប់ធ្នាប់ និង រក្សាសុវត្ថិភាពក្នុងអង្គភាព
- លើកគម្រោងចំណាយថវិកាប្រចាំឆ្នាំរបស់អង្គភាព និង តាមដានការអនុវត្ត
- លើកសំណើអំពីតម្រូវការចំណាយសម្រាប់ដំណើរការរបស់អង្គភាព
- គ្រប់គ្រងទ្រព្យសម្បត្តិ និង ការរៀបចំបញ្ជីសារពើភ័ណ្ឌរបស់អង្គភាពដែល **គ.ម.ក** ប្រគល់ឲ្យ
- ទំនាក់ទំនងសាធារណៈ ដើម្បីជំរុញការអភិវឌ្ឍនជំនាញសវនកម្មតាមការហ្វឹកហ្វឺនក្នុង និង ក្រៅប្រទេស ការផ្លាស់ប្តូរបទពិសោធន៍ជាមួយបុគ្គលពាក់ព័ន្ធ និង ការស្រាវជ្រាវ។

**កថាខណ្ឌទី ២ ការិយាល័យសវនកម្មទី ២**

ការិយាល័យសវនកម្មទី ២ ត្រូវបានដឹកនាំដោយប្រធាន ១ រូប និង អនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។ ហើយការិយាល័យសវនកម្មទី ២ ត្រូវមានការទទួលខុសត្រូវធ្វើសនវកម្មលើនាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ និងនាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ។ម្យ៉ាងទៀតការិយាល័យសវនកម្មទី២មានតួនាទី និងភារកិច្ចដូជាៈ

- ពិនិត្យឡើងវិញលើមុខងារ សកម្មភាព កម្មវិធី និង ប្រតិបត្តការនានារបស់ **គ.ម.ក** ក្នុងការបរិច្ឆេទសមស្រប ដើម្បីកំណត់ការអនុវត្តឲ្យបានសមស្របតាមការរៀបចំផែនការ ការចេញបទបញ្ជា និងបទប្បញ្ញត្តិផ្សេងៗការចាត់តាំងការងារ និង ការត្រួតពិនិត្យ ដោយផ្អែក និង ស្របតាមគោលដៅរបស់ **គ.ម.ក**
- កំណត់ភាពសមស្រប ភាពគ្រប់គ្រាន់ និង ប្រសិទ្ធិភាពនៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងផ្នែកគណនេយ្យរដ្ឋបាល និង ប្រតិបត្តិការរបស់ **គ.ម.ក**
- ពិនិត្យឡើងវិញលើភាពដែលអាចជឿជាក់បាន ភាពច្បាស់លាស់ ភាពទាន់ពេលវេលា និងភាពពេញលេញនៃព័ត៌មានហិរញ្ញវត្ថុ និង ប្រតិបត្តិការ ព្រមទាំងវិធីសាស្ត្រដែលប្រើប្រាស់ក្នុងការកំណត់អត្តសញ្ញាណ ការវាស់វែង ចំណាត់ថ្នាក់ និង ការរៀបចំរបាយការណ៍អំពីព័ត៌មានទាំងនោះ
- ពិនិត្យឡើងវិញលើប្រព័ន្ធដែលបានបង្កើតរួច ដើម្បីធានាភាពត្រឹមត្រូវតាមគោលនយោបាយផែនការ នីតិវិធីច្បាប់ និង បទប្បញ្ញត្តិនានា ដែលលមានឥទ្ធិពលសំខាន់លើកិច្ចប្រតិបត្តិការ និង របាយកាណ៍ ហើយលើកសំណើកែលំអ ឬ កែតម្រូវប្រសិនបើមានកំហុស
- ពិនិត្យឡើងវិញលើការគ្រប់គ្រង ថែទាំការងារ និង ផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិរបស់ **គ.ម.ក**
- វាយតម្លៃភាពសន្សំសំចៃ និង ប្រសិទ្ធភាពសេដ្ឋកិច្ចនៃការប្រើប្រាស់ធនធានរបស់ **គ.ម.ក** ហើយលើកសំណើដោះស្រាយ និង កែលំអ
- ធ្វើសវនកម្មលើប្រតិបត្តិការចំណូល និង ចំណាយ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃការអនុវត្តថវិការបស់ **គ.ម.ក** រួមទាំងភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ
- ធ្វើសវនកម្មលើការអនុវត្តកម្មវិធី និង គម្រោងចំណាយ ដោយធ្វើការប្រៀបធៀបលទ្ធផលជាមួយគោលដៅ និង គោលបំណងដែលបានដាក់ចេញ
- ចូលរួមបង្កើតផែនការ ការអភិវឌ្ឍន៍ និង ធ្វើសវនកម្មលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីប្រព័ន្ធទាំងនោះឆ្លើយតបតាមគោលបំណង និងគោលដៅដែលបានគ្រោងទុក ហើយទទួលបាន

លទ្ធផលមានសុវត្ថិភាព និង ប្រសិទ្ធិភាពខ្ពស់

- ធ្វើសវនកម្មលើនីតិវិធី និង ការអនុវត្តនីតិវិធី ដើម្បីធានាថា វិធានការដែលបានដាក់ចេញគឺក្នុងគោលបំណងការពារមិនឲ្យមានការកេងបន្លំ
- រៀបចំផែនការសវនកម្មប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ **គ.ម.ក** ពិនិត្យ និង សម្រេច
- ធ្វើសវនកម្មលើភាពសមស្របនៃការគ្រប់គ្រងធនធានមនុស្សរចនាសម្ព័ន្ធ ចំនួនមន្ត្រីជំនាញវិជ្ជាជីវៈ
- ឋានៈ តួនាទី និង ការលើកទឹកចិត្ត
- ធ្វើសវនកម្មលើភាពត្រឹមត្រូវ ភាពទាន់ពេល ភាពពេញលេញ នៃប្រព័ន្ធត្រួតពិនិត្យ ប្រព័ន្ធ
- កត់ត្រាព័ត៌មាន និង កិច្ចបញ្ជិកាគណនេយ្យ
- ធ្វើសវនកម្មលើការអនុវត្តបទបញ្ជាផ្ទៃក្នុង ស្តីពីការគ្រប់គ្រងមន្ត្រីជំនាញគ្រប់ជាន់ថ្នាក់របស់ **គ.ម.ក** និង ការលើការអនុវត្តលក្ខន្តិកៈនៃមន្ត្រីរបស់ **គ.ម.ក**
- ធ្វើរបាយការណ៍សវនកម្មជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធាននៃ **គ.ម.ក** អំពីការប្រព្រឹត្តិទៅរបស់នាយកដ្ឋានដែលបានធ្វើសវនកម្មរួច
- ផ្តល់សេចក្តីសន្និដ្ឋាន និង អនុសាសន៍ជូនប្រធាននាយកដ្ឋានដែលទទួលការធ្វើសវនកម្ម ដើម្បីធ្វើការកែលំអ ហើយរបាយការណ៍សវនកម្មពេញលេញត្រូវផ្តល់ជូនថ្នាក់ដឹកនាំ **គ.ម.ក** ពិនិត្យ និង ផ្តល់ការណែនាំ
- រក្សារបាយកាណ៍សវនកម្មឲ្យបានល្អសម្រាប់ជាមូលដ្ឋានតាមដាន ផ្ទៀងផ្ទាត់លើវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍កែលំអ
- ប្រមូល និងតាមដានជាប្រចាំនូវឯកសារគតិយុត្តិ និងសកម្មភាពកែទម្រង់ផ្សេងៗរបស់នាយកដ្ឋាននីមួយៗ
- សហការជាមួយនាយកដ្ឋាននានា សំដៅកសាងមូលដ្ឋានព័ត៌មានឲ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីវាយតម្លៃឲ្យបានសុក្រឹត្យ
- ផ្តល់របាយការណ៍ប្រចាំឆ្នាំស្តីពីសវនកម្មការងារជូនថ្នាក់ដឹកនាំ **គ.ម.ក** ដើម្បីពិនិត្យ និងផ្តល់ការណែនាំ
- សម្របសម្រួលការងារសនវកម្មផ្ទៃក្នុងជាមួយនឹងអាជ្ញាធរសវនកម្មជាតិ ដើម្បីធានាដំណើរការសវនកម្មអោយបានគ្រប់គ្រាន់ និងសមស្រប ជាពិសេសកាត់បន្ថយការងារស្ទួនគ្នា
- រៀបចំរបាយការណ៍ជាប្រចាំពាក់ព័ន្ធនឹងការអនុវត្តការងាររបស់ការិយាល័យ។

ដូច្នេះ អង្គភាពសវនកម្មផ្ទៃក្នុងនៃ **គ.ម.ក** គឺបានដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការត្រួតពិនិត្យ នូវ

ដំណើរការរៀបចំនឹងការប្រព្រឹត្តិទៅរបស់ **គ.ម.ក** ដើម្បីធ្វើការវាយតម្លៃទៅលើផែនការដែលបានកំណត់ ព្រមទាំងធ្វើសវនកម្មលើប្រព័ន្ធចំណូល ចំណាយរបស់ **គ.ម.ក** និងរាយការណ៍អំពីលទ្ធផលការងារប្រចាំត្រីមាស ប្រចាំឆ្នាំ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាប្រធាននៃ **គ.ម.ក** ធ្វើការត្រួតពិនិត្យ ។

សរុបមក ឃើញថាតួនាទី និងភារកិច្ចរបស់របស់ថ្នាក់ដឹកនាំ និងថ្នាក់កម្រិតបច្ចេកទេសរបស់ (**គ.ម.ក**) គឺត្រូវបានបែងចែកដាច់ពីគ្នា ចំពោះតួនាទី និងភារកិច្ចរបស់ថ្នាក់ដឹកនាំគឺត្រូវធ្វើការតាមដាន គ្រប់គ្រង និង ត្រួតពិនិត្យអំពីដំណើរការវិស័យមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងតួអង្គដែល ពាក់ព័ន្ធនៅក្នុងវិស័យមូលបត្រ ដោយធ្វើការសម្រេចនៅក្នុងការផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ ឬ ផ្តល់ការអនុញ្ញាតដល់ប្រតិបត្តិករទីផ្សារមូលបត្រ ឬ ធ្វើការដកហូតអាជ្ញាប័ណ្ណ ដកហូតការ អនុញ្ញត្តិ ពីក្រុមហ៊ុនទាំងនោះ ប្រសិនបើមិនបានគោរពទៅតាមគោលការណ៍ និងបទប្បញ្ញត្តិដែលច្បាប់បានកំណត់ ។ ម្យ៉ាងទៀត ធ្វើការចេញគោលការណ៍ណែនាំ នឹងសេចក្តីសម្រេចផ្សេងៗដែលទាក់ទងទៅនឹងវិស័យមូលបត្រ និងចាត់ចែងការងារនៅក្នុង(**គ.ម.ក**) ។ ចំណែកឯ ថ្នាក់កម្រិតបច្ចេកទេសវិញ គឺមានតួនាទី និងភារកិច្ចទៅតាមផ្នែកនាយកដ្ឋាននីមួយៗរបស់ខ្លួន ដែលច្បាប់បានកំណត់ ព្រមទាំងប្រធាននាយកដ្ឋាននីមួយៗ ត្រូវរាយការណ៍អំពីលទ្ធផលការងាររបស់នាយកដ្ឋានរបស់ខ្លួនជូន អគ្គនាយក នៃ (**គ.ម.ក**) ជាប្រចាំ ។

ក្រោយពីបានដឹងអំពីតួនាទី និង ភារកិច្ចរបស់ថ្នាក់ដឹកនាំ និង កម្រិតបច្ចេករបស់ (**គ.ម.ក**) រួចមកហើយនោះ ចម្ងល់បានចោទសួរថា តើចំពោះមន្ត្រីបម្រើការងារនៅក្នុង (**គ.ម.ក**) វិញមានការបែងចែកដែរឬទេ? ហើយថាតើធនធានរបស់ (**គ.ម.ក**) វិញបានមកពីណាសម្រាប់ដំណើរការ ? តើក្រោយពីបានបង្កើត(**គ.ម.ក**)នេះឡើងហើយ ស្ថាប័ននេះបានធ្វើការងារអ្វីខ្លះ និងទទួលបានសមិទ្ធិផលយ៉ាងណាដែរ ? ដែលចម្ងល់ទាំងអស់នេះនឹងត្រូវបានធ្វើការបកស្រាយនៅជំពូកទី ៣ បន្ទាប់នេះ ។

# ជំពូកទី ៣
# មន្ត្រី និងធនធាន ព្រមទាំងការអភិវឌ្ឍរបស់ គ.ម.ក

ជាធម្មតា នៅក្នុងការធ្វើអោយស្ថាប័នមួយអាចដំណើរការទៅបានដោយរលូន និងអាចសម្រេចបាននូវភាពជោគជ័យទៅបាននោះ មានកត្តាចូលរួមជាច្រើន សម្រាប់ជាចលករនៅក្នុងការធ្វើឲ្យស្ថាប័ននោះអាចដំណើរការទៅបាន នៅក្នុងនោះផងដែរមន្ត្រីដែលបម្រើការងារនៅក្នុងស្ថាប័នក៏ជាផ្នែកមួយដ៏សំខាន់ផងដែរ ដើម្បីអាចឲ្យស្ថាប័នមានសកម្មភាពរលូន។ ចំណែកឯស្ថាប័ន **គ.ម.ក** ក៏មិនខុសគ្នាដែរ សម្រាប់ការធ្វើឲ្យស្ថាប័ននេះដំណើរការទៅបាន មន្ត្រីដែលបានបម្រើការងារនៅស្ថាប័ននេះ គឺពិតជាបានចូលរួមចំណែកយ៉ាងសកម្ម ដើម្បីបំពេញមុខតំណែង តួនាទី និងភាកិច្ចទៅតាមជំនាញរៀងៗខ្លួន ។

## ផ្នែកទី ១ មន្ត្រី

សម្រាប់មន្ត្រីដែលកំពុងបម្រើការងារនៅក្នុង **គ.ម.ក** ដែលនៅក្នុងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មការមូលបត្រកម្ពុជា បានធ្វើការបែងចែកមន្ត្រីនៅក្នុង **គ.ម.ក** ជាពីរប្រភេទ ក្នុងនោះប្រភេទទី ១ គឺជាមន្ត្រីមុខងារសាធារណៈ និងប្រភេទទី ២ គឺជាមន្ត្រីលក្ខន្តិកៈ[៥៨] ។

### កថាខណ្ឌទី ១ មន្ត្រីមុខងារសាធារណៈ

មន្ត្រីមុខងារសាធារណៈ គឺជាមន្ត្រីរាជការដែលត្រូវបានធ្វើការជ្រើសរើសឲ្យចូលបម្រើការងារក្នុងក្របខណ្ឌរដ្ឋ ដោយត្រូវគោរពតាមគោលការណ៍រួម នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលទាំងលក្ខខណ្ឌនៃការជ្រើសរើស ការតែងតាំង ។ ក្នុងនោះផងដែរ ការជ្រើសរើសមន្ត្រីរាជការឲ្យចូលទៅក្នុងក្របខ័ណ្ឌរដ្ឋ ត្រូវឆ្លងកាត់នីតិវិធី និងយន្តការច្បាស់លាស់ ។ ម្យ៉ាងទៀតក្នុងការជ្រើសរើសមន្ត្រីមុខងាសាធារណៈនោះ គឺធ្វើឡើងតាម ០២ ជម្រើស ដែលជម្រើសទី ០១ គឺក្រសួង ឬ ស្ថាប័ននីមួយៗដែលជ្រើសរើសមន្ត្រីរាជការ ត្រូវធ្វើសំណើរដ្ឋលេខាធិការដ្ឋានមុខងាសាធារណៈ ដែលពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីដាក់សំណើនេះទៅក្នុងថវិកាឆ្នាំនីមួយៗជូនគណៈរដ្ឋមន្ត្រីពិនិត្យ និងសម្រេច មុននឹងដាក់ជូនរដ្ឋសភាអនុម័ត ។ ក្រោយពីរដ្ឋសភាអនុម័តគម្រោងក្របខណ្ឌនីមួយៗរួចហើយ ទើបស្ថាប័នសាមីដំណើការជ្រើសរើសឲ្យចូលក្របខ័ណ្ឌ ដោយមានការប្រឡងប្រជែងទៅតាមច្បាប់ ។ ចំណែកឯ ជម្រើសទី ០២ គឺជាករណីពិសេស បើមានសេចក្តីត្រូវការបុគ្គលិកក្រៅពីគម្រោងប្រចាំឆ្នាំដូចខាងលើ ក្រសួង ស្ថាប័នត្រូវធ្វើសំណើមករដ្ឋមន្ត្រីលេខាធិការដ្ឋានមុខងារសាធារណៈដែល

[៥៨] មាត្រា ១៤ អនុក្រឹត្យស្តីពីរការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈកម្មការមូលបត្រកម្ពុជា

និងពិចារណា ពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរាយការណ៍ដោយសុំយោបល់ពីគណៈរដ្ឋមន្ត្រី ។ ក្នុងករណីគណៈរដ្ឋមន្ត្រីអនុម័តយល់ព្រម ស្ថាប័នសាមីអាចចាត់ការជ្រើសរើស ដោយមានការប្រឡងប្រជែងឲ្យចូលក្របខណ្ឌបន្ថែមបាន ប៉ុន្តែករណីនេះត្រូវបញ្ចូលទៅក្នុងថវិកាកែប្រែនៃឆ្នាំ។ នៅក្នុងការអនុវត្តជាក់ស្តែង នៃការជ្រើសរើសមន្ត្រីរាជការឲ្យចូលក្របខណ្ឌរដ្ឋភាគច្រើន រាជរដ្ឋាភិបាល ជ្រើសឲ្យចូលក្របខ័ណ្ឌរដ្ឋមិនចាំបាច់មានការយល់ព្រមលើចំនួនពីរដ្ឋសភាជាមុនទេ ។ ការធ្វើនេះក៏មិនខុសពីច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលដែរ ពីព្រោះពុំមានមាត្រាណាមួយដែលចែងថា ការកំណត់ចំនួនមន្ត្រីចូលក្របខណ្ឌរដ្ឋ ត្រូវតែមានការអនុម័តយល់ព្រមពីរដ្ឋសភានោះឡើយ ។ បន្ថែមពីនេះទៀត មាត្រា ១៣ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលចែងថា ជាគោលការណ៍ រាល់ការជ្រើសរើសបេក្ខជនឲ្យចូលក្នុងក្របខណ្ឌរដ្ឋត្រូវធ្វើឡើងតាមកាប្រឡងប្រជែង លើកលែងតែមានការកំណត់ផ្សេងពីនេះរបស់រាជរដ្ឋាភិបាល ។ តាមមាត្រានេះបញ្ជាក់យ៉ាងច្បាស់ថា ជាគោលការណ៍នៃការជ្រើសរើសមន្ត្រីរាជការអាចធ្វើតាមមធ្យោបាយ ០២ យ៉ាង គឺៈ ទី ០១ តាមរយៈការប្រឡងប្រជែង និងទី ០២ តាមរយៈការសម្រេចរបស់រាជរដ្ឋាភិបាល គឺរាជរដ្ឋាភិបាលសម្រេចតែងតាំងឲ្យចូលក្របខណ្ឌរដ្ឋ ដោយមិនបាច់ឆ្លងកាត់ការប្រឡងប្រជែងបាន ។

ចំពោះមន្ត្រីមុខងារសាធារណៈសម្រាប់ **គ. ម. ក** វិញ គឺការជ្រើសរើសមន្ត្រីក្របខណ្ឌរដ្ឋត្រូវបានជ្រើសរើស ដោយការតែងតាំងដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល ដែលក្នុងនោះចំពោះមន្ត្រីមុខងារសាធារណៈបម្រើការងារនៅក្នុង **គ.ម.ក** នៅក្នុងអាណត្តិទី ០១ ត្រូវបានតែងតាំងមន្ត្រីរាជការចំនួន ០៧ រូប នៃគណៈកម្មការមូលបត្រកម្ពុជា ដូចមានរានាមខាងក្រោម[៦៥]៖

| | |
|---|---|
| ១-លោក **ចន ណារិទ្ធ** | ជាប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ |
| ២-លោក **សុខ ដារ៉ា** | ជាប្រធាននាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ |
| ៣-លោក **សៀង ធីរិទ្ធិ** | ជាប្រធាននាយកដ្ឋានកិច្ចការគតិយុត្តិ |
| ៤-លោក **ឈុន សម្បត្តិ** | ជាប្រធាននាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ |
| ៥-លោក **វ៉ា សូរី** | ជាប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និង ទំនាក់ទំនងអន្តរជាតិ |
| ៦-លោក **ឈុំ សេរីវុធ** | ជាប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| ៧-លោក **ឆាយ យុនឡុង** | ជាប្រធានអង្គភាពសវនកម្មផ្ទៃក្នុង ។ |

[៦៥] មាត្រា ១ អនុក្រឹត្យលេខ ៩២៣ អនក្រ .តត ស្តីពីការតែងតាំងមន្ត្រីរាជការ

**កថាខណ្ឌទី ២ មន្ត្រីលក្ខន្តិកៈ**

នៅក្នុងគណៈកម្មការមូលបត្រកម្ពុជា ក្រៅពីមានមន្ត្រីមុខងាសាធារណៈនៅក្នុងការបំពេញមុខងារ ដែលត្រូវបានតែងតាំងដោយអនុក្រឹត្យហើយនោះ ស្ថាប័ននេះនៅមានមន្ត្រីលក្ខន្តិកៈដែលស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មការមូលបត្រកម្ពុជា តាមបទប្បញ្ញត្តិនៃប្រកាសស្តីពីលក្ខន្តិកៈនៃមន្ត្រីរបស់គណៈកម្មការមូលបត្រកម្ពុជា ។ ដែលមន្ត្រីនៃលក្ខន្តិកៈរបស់ **គ.ម.ក** ត្រូវមានឧបនិស្ស័យសម្រាប់បំពេញមុខតំណែង និងការងារផ្សេងៗ ក្នុងក្របខណ្ឌការងាររបស់ **គ.ម.ក** ។ ម្យ៉ាងទៀត មន្ត្រីលក្ខន្តិកៈរបស់ **គ.ម.ក** មាន ០២ ប្រភេទ គឺអនុមន្ត្រី និងមន្ត្រីក្រមការ ដែលអនុមន្ត្រីជាមន្ត្រី ដែលមានឧបនិស្ស័យសម្រាប់កាន់មុខតំណែងជាអនុប្រធាននាយកដ្ឋាន ឬ ថ្នាក់ស្មើដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ **គ.ម.ក** ។ ចំណែកឯ មន្ត្រីក្រមការនៃ **គ.ម.ក** មាន ០៣ ( បី) ថ្នាក់ និងមានឧបនិស្ស័យសម្រាប់កាន់មុខតំណែងដូចជាៈ

-នាយកក្រមការ ជាមន្ត្រីដែលមានឧបនិស្ស័យសម្រាប់កាន់មុខតំណែងជាប្រធានការិយាល័យ ឬ ថ្នាក់ស្មើដែលមានក្នុងអង្គកាលេខនៃរចនាសម្ព័ន្ធរបស់ **គ.ម.ក** ។

-ក្រមការដើមខ្សែ ជាមន្ត្រីដែលមានឧបកនិស្ស័យសម្រាប់កាន់មុខតំណែងជាអនុប្រធានការិយាល័យ ឬថ្នាក់ស្មើដែលមានក្នុងអង្គកាលេខនៃរចនាសម្ព័ន្ធរបស់ **គ.ម.ក** ។

-ក្រមការ ជាមន្ត្រីគ្មានមុខតំណែងណាមួយនៅក្នុងអង្គកាលេខនៃរចនាសម្ព័ន្ធរបស់**គ.ម.ក** ។

តួយ៉ាងនៅក្នុងការជ្រើសរើសមន្ត្រីចូលក្នុងក្របខ័ណ្ឌមន្ត្រីនៃលក្ខន្តិកៈរបស់ **គ.ម.ក** គឺត្រូវធ្វើឡើងតាមរយៈការប្រឡងប្រជែងជាសាធារណៈ លើកលែងតែមានករណីចាំបាច់នៅក្នុងការបំពេញការងារជាបន្ទាន់ ដោយខ្វះមន្ត្រី **គ.ម.ក** អាចធ្វើការជ្រើសរើសបេក្ខភាពអោយចូលបម្រើការងារជាមន្ត្រីលក្ខន្តិកៈរបស់ **គ.ម.ក** ដោយមិនចាំបាច់មានការប្រឡងនោះទេ តែបេក្ខភាពដែលត្រូវបានជ្រើសរើសនោះ ត្រូវមានបុគ្គលិកលក្ខណៈ និងមានសមត្ថភាព ហើយត្រូវមានជំនាញ បទពិសោធន៍ទាក់ទងនឹងវិស័យមូលបត្រ ហើយ **គ.ម.ក** អាចជ្រើរើសបេក្ខភាពនោះបានត្រូវធ្វើឡើងតាមសំណើរបស់អគ្គនាយកនៃ **គ.ម.ក** និងដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាប្រធាននៃ **គ.ម.ក ។** ចំពោះបេក្ខជនត្រូវបានអនុញ្ញាតឲ្យចូលរួមនៅក្នុងការប្រឡងប្រជែង ជាមន្ត្រីលក្ខន្តិកៈ ត្រូវបំពេញលក្ខខណ្ឌដែលកំណត់ដោយ **គ.ម.ក** ដូចខាងក្រោមៈ

- មានសញ្ជាតិជាខ្មែរ
- មានអាយុច្រើនបំផុត ៣០ ឆ្នាំ គិតមកដល់ថ្ងៃប្រឡង
- មានសញ្ញាបត្រទាបបំផុត បរិញ្ញាបត្រ ឬ សញ្ញាបត្រដែលមានតម្លៃស្មើ តាមមុខជំនាញ

ដែល **គ.ម.ក** ត្រូវការចាំបាច់

- មិនប្រាសចាកសិទ្ធិខាងរដ្ឋប្បវេណី សិទ្ធិពលរដ្ឋ សិទ្ធិខាងនយោបាយ
- មិនធ្លាប់មានទោសពីបទមជ្ឈិម ឬ បទឧក្រិដ្ឋ អំពីបទល្មើសដែលប៉ះពាល់ដល់ទំនៀមទំលាប់ កិត្តិយស និងភាពសុចរិត
- ត្រូវមានសុខភាពល្អ និងកាយសម្បទាគ្រប់គ្រាន់ក្នុងការបំពេញការងារ ។ បន្ថែមពីនេះបែបបទលំអិតនៃការប្រឡងជ្រើសរើសមន្ត្រីនៃលក្ខន្តិកៈរបស់ **គ.ម.ក** ត្រូវបានកំណត់ដោយគណៈកម្មការប្រឡងជ្រើសរើសរបស់ **គ.ម.ក** តាមសំណើរបស់នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ។ ហើយបន្ទាប់ពីបេក្ខជនដែលបានប្រឡងជាប់ជាមន្ត្រីនៃលក្ខន្តិកៈដែលធ្វើការប្រកាសលទ្ធផលដោយ **គ.ម.ក** រួចមក មុននឹងទទួលស្គាល់ជាមន្ត្រីនៃលក្ខន្តិកៈរបស់ **គ.ម.ក** បេក្ខជនដែលត្រូវបានជ្រើសរើសតាមប្រការខាងលើនេះ ត្រូវធ្វើកម្មសិក្សាសាកល្បងរយៈពេល ០៦ (ប្រាំមួយ) ខែ នៅក្នុងជំនាញ ឬ ផ្នែកដែលបានប្រឡងជាប់នោះ ដោយមានការអនុញ្ញាតពីអគ្គនាយក និងធ្វើការត្រួតនិត្យ ដោយប្រធាននាយកដ្ឋាននោះ ហើយនៅក្នុងការបំពេញកម្មសិក្សា បេក្ខជនោះមានឋានៈជាមន្ត្រីកម្មសិក្សា ដោយក្នុងពេលបំពេញកម្មសិក្សា មន្ត្រីកម្មសិក្សា និង ទទួលបានប្រាក់បៀវត្សតាមការកំណត់របស់ **គ.ម.ក** ។ ហើយនៅក្នុងករណីចាំបាច់ ប្រសិនបើ **គ.ម.ក** ពិនិត្យឃើញថា មន្ត្រីកម្មសិក្សាមិនទាន់បានបំពេញការងារឲ្យមានលក្ខណៈល្អប្រសើរ នៅក្នុងជំនាញរបស់ខ្លួននោះ **គ.ម.ក** អាចសម្រេចឲ្យមន្ត្រីកម្មសិក្សានោះ បន្តកម្មសិក្សាបន្តរយៈពេលសាកល្បងអតិបរិមាបន្ថែមត្រឹម ០៦ (ប្រាំមួយ) ខែទៀត ។ នៅខណៈពេលបំពេញកម្មសិក្សា មន្ត្រីកម្មសិក្សាណាដែលមិនមានសម្បទាវិជ្ជាវៈមិនគ្រប់គ្រាន់ ឬត្រូវបានពិនិត្យឃើញថារបៀបការងារមានភាពខ្ជីខ្ជា គ្មានការទទួលខុសត្រូវលើការងារ គ្មានកំលាំងនឹងបំពេញមុខងាររបស់ខ្លួនបាន ឬមកបំពេញការងារមិនទៀងទាត់ ដោយអាក់ខានមកធ្វើកម្មសិក្សាសរុបលើសពី ១៥ (ដប់ប្រាំ) ថ្ងៃ ដោយគ្មានមូលហេតុសមរម្យ អាចត្រូវបញ្ឈប់មិនឲ្យធ្វើកម្មសិក្សាបន្ទាប់ពីមានការវាយតម្លៃដោយគណៈកម្មការវាយតម្លៃគុណភាពមន្ត្រី ។ ក្រោយពីមន្ត្រីកម្មសិក្សាបានបញ្ចប់កម្មសិក្សា របស់ខ្លួនប្រកបដោយជោគជ័យហើយ មន្ត្រីកម្មសិក្សានោះនឹងត្រូវបានទទួលស្គាល់ជាមន្ត្រីលក្ខកន្តិកៈ របស់ **គ.ម.ក** ពេញសិទ្ធិ និងត្រូវបានធ្វើការតែងតាំងក្នុងមុខតំណែងដែលទំនេរសមស្របណាមួយ ដោយធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា តាមសំណើរបស់អគ្គនាយកនៃ **គ.ម.ក** ។

បន្ថែមលើសពីនេះទៀត មន្ត្រីលក្ខន្តិកៈរបស់ **គ.ម.ក** ដែលមានសមត្ថភាព និង សកម្មនៅក្នុងការបំពេញមុខតំណែងរបស់ខ្លួនបានល្អនឹងត្រូវបានធ្វើការតំឡើងថ្នាក់ ដែលការតំឡើងថ្នាក់នេះ

ធ្វើឡើងតាមរយៈការប្រឡងផ្ទៃក្នុង ក្នុងចំណោមមន្ត្រីដែលមានអតីតភាពយ៉ាងតិច ០២ (ពីរ) ឆ្នាំ និងដែលមានលក្ខណសម្បត្តិជាមូលដ្ឋានដូចជា៖

- មានឆន្ទៈបម្រើការងារនៅ **គ.ម.ក**
- មានសមត្ថភាព និងសម្រេចបានល្អនូវភារកិច្ចដែលបានប្រគល់ឲ្យ
- មានការទទួលខុសត្រូវចំពោះការងារ
- គោរពវិន័យការងារ
- មានកិរិយាមាយាទ និង សីលធម៌ល្អ ដែលមិនធ្វើឲ្យប៉ះពាល់ដល់កិត្តិយសរបស់ **គ.ម.ក**
- មានសាមគ្គីភាព និង ទំនាក់ទំនងល្អជាមួយមន្ត្រី បុគ្គលិក និង អតិថិជន។ ហើយចំពោះការតំឡើងថ្នាក់នេះ ត្រូវធ្វើឡើងដោយម្តងមួយថ្នាក់ៗ លើកលែងតែមានការសម្រេចផ្សេងពីនេះ ដោយ **គ.ម.ក** តាមសំណើរបស់អគ្គនាយកនៃ **គ.ម.ក**[៥០] ។

## ផ្នែកទី ២ ប្រភពធនធាន និង ថវិការបស់ គ.ម.ក

ពិតប្រាកដណាស់ថវិកា គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់ធ្វើឲ្យដំណើរការស្ថាប័ន ពីព្រោះថាថវិកា គឺជាចលករយ៉ាងសំខាន់ ដើម្បីបំរើផលប្រយោជន៍ទៅដល់ស្ថាប័ន និងបុគ្គលិកដែលបានបម្រើការងារនៅក្នុងស្ថាប័ននេះ ។ ភាពចាំបាច់ទាំងនេះហើយ ទើបស្ថាប័ននីមួយៗខិតខំស្វះស្វែងរកប្រភពធនធានឲ្យបានច្រើន ក្នុងការយកមកធ្វើការអភិវឌ្ឍស្ថាប័នរបស់ខ្លួន ទៅលើប្រភពធនធានដែលបានមកពីថវិការដ្ឋ ដែលផ្តល់អោយដោយការអនុម័តរបស់រដ្ឋសភាក្នុងការកំណត់អំពីការចំណាយប្រចាំឆ្នាំរបស់ស្ថាប័ន ។ តួយ៉ាងសម្រាប់គណៈកម្មការមូលបត្រកម្ពុជា ប្រភពធនធាន និងថវិកាទទួលបានក្នុងប្រើប្រាស់ក្នុងស្ថាប័ន គឺប្រភពធនធាន និង និងថវិការបស់ **គ.ម.ក** រួមមាន៖ ថវិកាជាតិដែលផ្តល់ឲ្យ **គ.ម.ក** និងថវិកាដែល **គ.ម.ក** ទទួលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការបរទេស និងពីប្រភេទផ្សេងទៀត[៥១] ។

### កថាខណ្ឌទី ១ ថវិកាជាតិ

សម្រាប់គណៈកម្មការមូលបត្រកម្ពុជា មានកញ្ចប់ថវិកាដោយដោយឡែក ហើយថវិកាជាតិសម្រាប់ចំណាយនោះត្រូវធ្វើឡើងដោយអគ្គនាយកនៃ **គ.ម.ក** ក្នុងការធ្វើគម្រោងស្នើសុំថវិកាជាតិ

[៥០] ប្រកាសលេខ ០០៣ គ ម ក .ប្រ.ក ស្តីពីលក្ខន្តិកៈនៃមន្ត្រីរបស់គណៈកម្មការមូលបត្រកម្ពុជា
[៥១] មាត្រា ២២ អនុក្រឹត្យស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃ គ.ម.ក

ប្រចាំឆ្នាំសម្រាប់អភិវឌ្ឍន៍ស្ថាប័ន ដោយ **គ.ម.ក** បានបើកគណនីនៅក្នុងរតនាគារជាតិ បន្ទាប់មកដាក់ជូនទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចក្នុងការសម្រេច ។ បន្ទាប់ពីទទួលបានគម្រោងហើយនោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចាត់មន្ត្រីជំនាញនៅក្នុងការវាយតម្លៃនៃការស្នើសុំ ហើយអញ្ជើញមន្ត្រីដែលមកពីគណៈកម្មការមូលបត្រកម្ពុជានោះ ក្នុងការពារនូវគម្រោងស្នើសុំថវិកានោះ។ ក្រោយមកទៀត បន្ទាប់ពីបានពិភាក្សា និងវាយតម្លៃរួចមក ក្រសួងសេដ្ឋកិច្ចនឹងយកគម្រោងថវិកានោះដាក់ជូនរដ្ឋសភា ដើម្បីពិនិត្យ និងអនុម័តច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ ហើយនៅពេលដែលសភាបានអនុម័តថវិកាប្រចាំឆ្នាំរបស់ **គ.ម.ក** រួចហើយនោះ ថវិកានោះនឹងត្រូវបញ្ជូនទៅក្នុងគណនីរបស់ **គ.ម.ក** ដែលបានបើកនៅក្នុងរតនាគារជាតិរួចមកហើយនោះ។ ម្យ៉ាងទៀត ប្រសិនបើ **គ.ម.ក** ត្រូវការថវិកានោះ ដើម្បីយកអភិវឌ្ឍន៍ស្ថាប័ន អគ្គនាយកនៃ **គ.ម.ក** ត្រូវរៀបចំនីតិវិធីក្នុងការស្នើថវិកាទៅ រតនាគារជាតិក្នុងការយកថវិកានោះមកប្រើប្រាស់បាន។ បន្ថែមពីនេះ នៅក្នុងការអនុម័តថវិកាជាតិប្រចាំឆ្នាំគឺត្រូវធ្វើឡើងមុនមួយឆ្នាំ គឺមានន័យថា អនុម័តថវិកាសម្រាប់ឆ្នាំ ២០១៥ គឺត្រូវចាយនៅក្នុងឆ្នាំ២០១៤ ហើយប្រសិនបើយអនុម័តថវិកាឆ្នាំ ២០១៦ គឺត្រូវចាយនៅក្នុងឆ្នាំ ២០១៥ ។ ហើយលើសពីនេះ ប្រសិនបើថវិកាដែលបានអនុម័តដោយរដ្ឋសភាហើយនោះ បន្ទាប់ពីប្រើប្រាស់ហើយនៅសល់នោះ គឺ **គ.ម.ក** ឬ ក្រសួង ស្ថាប័ននានាត្រូវបញ្ជូនថវិកាដែលចាយនៅសល់នោះ ទៅក្នុងគណនីដែលបានបើកនៅរតនាគារជាតិ សម្រាប់ចាយនៅក្នុងឆ្នាំក្រោយទៀត ។

**កថាខណ្ឌទី ២ ថវិកាមកពីប្រភពផ្សេងៗ**

ក្រៅពីថវិកាជាតិដែលផ្តល់ឲ្យ **គ.ម.ក** សម្រាប់យកមកប្រើប្រាស់ប្រចាំឆ្នាំនោះ **គ.ម.ក** ក៏នៅមានប្រភពថវិកាផ្សេងទៀត ដើម្បីយកមកទ្រទ្រង់ស្ថាប័នផងដែរ។ ដែលក្នុងនោះបានមកពីហិរញ្ញប្បទានសហប្រតិបត្តិការបរទេស ជាជំនួយមកពីអង្គការផ្សេងៗ ដែលកន្លងមកនេះ **គ.ម.ក** បានទទួលហិរញ្ញប្បទានបរទេសពីធានាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្នុងការអភិវឌ្ឍវិស័យមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ក្រៅពីប្រភពធនធាន និងថវិកាដែល **គ.ម.ក** ទទួលបាននោះ ស្ថាប័ននេះក៏នៅមានប្រភពធនធានផ្សេងទៀត ដែលបានមកពីថ្លៃសេវានៃការផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ ឬតំណាងក្រុមហ៊ុនមូលបត្រ ឬ អ្នកចូលរួមផ្សេងទៀតក្នុងទីផ្សារមូលបត្រ ថ្លៃសេវានៃការដាក់ពាក្យសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ ថ្លៃសេវានៃប្រតិបត្តិការជួញដូរមូលបត្រក្នុងទីផ្សារមូលបត្រ និងចំណូលពីប្រតិបត្តិការផ្សេងៗទៀត ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ **គ.ម.ក** និងប្រាក់ពិន័យអន្តរការណ៍ លើបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ ។ ហើយកម្រៃសេវា និងប្រាក់ពិន័យទាំងនេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង

ហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក** ។ លើសពីនេះទៀត **គ.ម.ក** ក៏មានសិទ្ធិទទួល និងគ្រប់គ្រងជាកម្មសិទ្ធិករនូវចលនវត្ថុ និងអចលនវត្ថុដែលជាអំណោយ ឬ អច្ច័យទានរបស់ឯកជន និងអំណោយរបស់រដ្ឋ ។

## ផ្នែកទី ៣ សមិទ្ធផលសម្រេចបានរបស់ គ.ម.ក

### កថាខណ្ឌទី ១ ការកសាងហេដ្ឋារចនាសម្ព័ន្ធបទដ្ឋានគតិយុត្ត

វិស័យមូលបត្រ គឺជាវិស័យមួយដ៏ថ្មីស្រឡាងសម្រាប់ប្រទេសកម្ពុជាយើង ។ ហេតុដូច្នេះ ការកសាង និងរៀបចំបទដ្ឋានគតិយុត្ត គឺជាអាទិភាពចំពោះមុខមួយយ៉ាងសំខាន់ ដើម្បីធានាឲ្យដំណើរការទីផ្សារមូលបត្រ អាចប្រព្រឹត្តិទៅប្រកបដោយប្រសិទ្ធភាព ត្រឹមត្រូវ តម្លាភាព និងនៅក្នុងគោលដៅធានាឲ្យមានភាពយុត្តិធម៌ សណ្តាប់ធ្នាប់ ស្ថេរភាព ការអភិវឌ្ឍ និងផ្តល់នូវការការពារយ៉ាងប្រសើរទៅដល់សាធារណជនជាតិ ជាពិសេសអ្នកវិនិយោគសាធារណៈ ។ ម្យ៉ាងទៀត ការបង្កើតឡើងនូវបទប្បញ្ញត្តិ ដែលមានលក្ខណៈពេញលេញ ប្រសិទ្ធភាព និងគោរពតាមស្តង់ដាបទ-ដ្ឋានអន្តជាតិនោះ គឺជាបេសកកម្មមួយយ៉ាងលំបាកសម្រាប់និយ័តករ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយគណៈកម្មការមូលបត្រកម្ពុជា បានខិតខំប្រឹងប្រែង និងអនុវត្តការងាររបស់ខ្លួនយ៉ាងសកម្ម ដោយបានបោះជំហានទៅមុខជាបណ្តើរៗជាមួយនឹងសមិទ្ធផល ដែលសម្រេចបានជាច្រើនគួរឲ្យមានការកត់សម្គាល់ ។ ទន្ទឹមនឹងសមិទ្ធផលនេះ គណៈកម្មការមូលបត្រកម្ពុជា នៅមានសេចក្តីព្រាងបទប្បញ្ញត្តិជាច្រើនទៀត ដែលនឹងត្រូវប្រកាសឲ្យប្រើជាផ្លូវការនាពេលអនាគត ដើម្បីធ្វើឲ្យបទដ្ឋានគតិយុត្តក្នុងវិស័យមូលបត្រកាន់តែមានលក្ខណៈរឹងមាំ នឹងពេញលេញ ។

ច្បាប់ស្តីពីមូលបត្ររដ្ឋ និងច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន គឺជាគ្រឹះសម្រាប់វិស័យមូលបត្រនៃប្រទេសកម្ពុជា និងជាវិធានគោលក្នុងការបង្កើត និងរៀបចំបទដ្ឋាន-គតិយុត្តផ្សេងៗទៀត ។ ដោយផ្តើមចេញពីច្បាប់ទាំពីរខាងលើនេះ គណៈកម្មការមូលបត្រកម្ពុជាបានរៀបចំអនុក្រឹត្យ និងប្រកាសនានាពាក់ព័ន្ធទៅនឹងការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន កាផ្តល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករជាត់ទាត់ និងទូទាត់មូលបត្រ ប្រតិបត្តិកររក្សាទុកមូលបត្រ ការផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ ការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈ មូលបត្របំណុល អភិបាលកិច្ចសាជីវកម្ម ការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ ការស៊ើបអង្កេតបទល្មើស ការដាកពិន័យអន្តរការណ៍ និងទណ្ឌកម្មរដ្ឋបាល ព្រមទាំងបទដ្ឋានគតិយុត្តដែលចាំបាច់ផ្សេងៗទៀត ។ ដើម្បីរៀបចំតាក់តែងបទប្បញ្ញត្តិសំខាន់ៗទាំងអស់ខាងលើនេះ មន្ត្រីជំនាញនៃគណៈកម្មការមូលបត្រកម្ពុជា បានសិក្សាស្រាវជ្រាវប្រមូលនូវ

ព័ត៌មាន និងឯកសារសំខាន់ៗ ពិសេសធ្វើការពិនិត្យ និងវិភាគស៊ីជម្រៅទៅលើបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យមូលបត្រនៃបណ្តាប្រទេសនានា ក្នុងគោលដៅទទួលបាននូវចំណេះដឹងគំនិតចំណុចពិសេសៗ និងធាតុចូលបន្ថែមសម្រាប់តាក់តែងនូវបទប្បញ្ញត្តិឲ្យមានលក្ខណៈគ្រប់គ្រាន់ និងអាចអនុវត្តបានប្រកបដោយប្រសិទ្ធិភាពខ្ពស់ ។ ហើយនៅក្នុងសេចក្តីព្រាងបទប្បញ្ញត្តិ ដែលបានរៀបចំ និងតាក់តែងឡើង ត្រូវបានធ្វើការពិនិត្យពិច័យយ៉ាងល្អិតល្អន់ ដោយបានដាក់ប្រជុំផ្ទៃក្នុងនាយកដ្ឋានបច្ចេកទេសជាច្រើនលើកច្រើនសារ សំដៅធ្វើការកែលំអ និងបំពេញបន្ថែមនូវចំណុចខ្វះចន្លោះ ។

ហើយនៅពេលដែលបទប្បញ្ញត្តិ ដែលត្រូវបានប្រកាសឲ្យប្រើជាផ្លូវការ ត្រូវបានធ្វើការផ្សព្វផ្សាយយ៉ាងទូលំទូលាយតាមរយៈគេហទំព័ររបស់គណៈកម្មការមូលបត្រកម្ពុជា ( www.secc.gov.kh ) ប្រព័ន្ធផ្សព្វផ្សាយនានា រាជកិច្ច និងសិក្ខាសាលា ឬ វគ្គបណ្តុះបណ្តាលផ្សេងៗ ដែលរៀបចំឡើងដោយគណៈកម្មការមូលបត្រកម្ពុជា សំដៅធ្វើយ៉ាងណាឲ្យសាធារណជន ជាពិសេសបុគ្គលពាក់ព័ន្ធបានដឹង និងអាចទទួលបានព័ត៌មានចាំបាច់ទៅប្រើប្រាស់តាមតម្រូវការជាក់ស្តែង ។

### កថាខណ្ឌទី ២ ការផ្តល់អាជ្ញាប័ណ្ណ ការទទួលស្គាល់ និង ការអនុញ្ញាត

ក្រៅពីកសាងហេដ្ឋារចនាសម្ព័ន្ធគតិយុត្ត គណៈកម្មការមូលបត្រកម្ពុជា បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការជ្រើសរើសតួអង្គសំខាន់ៗមានគុណវឌ្ឍិគ្រប់គ្រាន់ ដែលនឹងត្រូវចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា ដើម្បីឆ្លើយតបឲ្យកិច្ចដំណើរការប្រកបដោយចីរភាព នៃទីផ្សារមូលបត្រកម្ពុជា ដោយធ្វើយ៉ាងណាធានាឲ្យបាននូវប្រសិទ្ធិភាព តម្លាភាព យុត្តិធម៌ និងសណ្តាប់ធ្នាប់ក្នុងការជួញដូរមូលបត្រ និងដើម្បីបង្កើតឲ្យមានទំនុកចិត្តរបស់អ្នកវិនិយោគក្នុងវិស័យមូលបត្រនៅកម្ពុជា ។ នៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន គណៈកម្មការមូលបត្រកម្ពុជាបានផ្តល់អាជ្ញាប័ណ្ណ ការទទួលស្គាល់ និងការអនុញ្ញាតដល់ក្រុមហ៊ុនមានដូចខាងក្រោម[៦]៖

- ការផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ និង ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ដោយបានធ្វើការសម្រេចនៅក្នុងកិច្ចប្រជុំពេញអង្គនៃ **គ.ម.ក** លើកទី ១១ បានផ្តល់អាជ្ញាប័ណ្ណដល់កក្រុមហ៊ុនចំនួន១៥ (ដប់ប្រាំ)ដែលនៅក្នុងនោះមានក្រុមហ៊ុនធានាទិញមូលបត្រចំនួន ៧ (ប្រាំពីរ) មានដូចជា:

  ១. ក្រុមហ៊ុនយាន់តា ស៊ីយូ្យរីធី (ខេមបូឌា) ភីអិលស៊ី

  ២. ក្រុមហ៊ុន អ អេច ប៊ី អូ អេស ខេ ឥណ្ឌូឆៃណា ស៊ីយូ្យរីធី លីមីធីត

[៦] គណៈកម្មការមូលបត្រកម្ពុជា-របាយការណ៍សមិទ្ធផលការងារឆ្នាំ ២០០៩-២០១១

៣. ក្រុមហ៊ុន កម្ពុ ស៊ីយូ្យរីធី ភីអិលស៊ី

៤. ក្រុមហ៊ុន កាណា ស៊ីយូ្យរីធី អិលធីឌី

៥. ក្រុមហ៊ុន ខេមបូឌា-វៀតណាម ស៊ីយូ្យរីធី ភីអិលស៊ី

៦. ក្រុមហ៊ុន អេស ប៊ីអាយ រ៉ូយ៉ាល់ ស៊ីយូ្យរីធី

៧.ក្រុមហ៊ុន ភ្នំពេញ ស៊ីយូ្យរីធី ភីអិលស៊ី ។

ក្រុមហ៊ុនពាណិជ្ជករមូលបត្រចំនួន ០២ (ពីរ) មានដូចជា:

១. ក្រុមហ៊ុន ហ្គោលដេន ហ្វ័រឈូន (ខេបូឌា) ស៊ីយូ្យរីធី ភីអិលស៊ី

២. ក្រុមហ៊ុន សាខមប៊ែង ស៊ីយូ្យរីធី(ខេបូឌា) ភីអិលស៊ី (ដកហូតអាជ្ញាប័ណ្ណ)

ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រចំនួន ០៤ (បួន) មានដូចជា:

១. ក្រុមហ៊ុន អេស៊ីលីដា ស៊ីយូ្យរីធី ភីអិលស៊ី

២. ក្រុមហ៊ុន សូណាត្រា ស៊ីយូ្យរីធី ភីអិលស៊ី

៣. ក្រុមហ៊ុន ខេប ស៊ីយូ្យរីធី លីមីធីត

៤. ក្រុមហ៊ុន ខេមបូឌានស៊ីយូ្យរីធី ភីអិលស៊ី (ដកហូតអាជ្ញាប័ណ្ណ)

និង ក្រុមហ៊ុនទីប្រឹក្សាវិនិយោគចំនួន ០២ (ពីរ) មានដូចជា:

១. ក្រុមហ៊ុន អង្គរឃេភីថល អ៊ែតវ៉ាយហ្ស៊ើរ

២. ក្រុមហ៊ុន អេហ្វ យូ ជី អាយ ហ្គោល

- ការទទួលស្គាល់ក្រុមហ៊ុនគណនេយ្យជំនាញ ក្រុមហ៊ុនគណនេយ្យជំនាញ និង សវនករឯករាជ្យផ្តល់សេវានៅក្នុងវិស័យមូលបត្រចំនួន ០៦ និង ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃក្នុងវិស័យមូលបត្រចំនួន០៤ (ឧបកសម្ព័ន្ធ) ។
- ការផ្តល់ការទទួលស្គាល់ដល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ភ្នាក់ងារបញ្ជិកា ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និង ភ្នាក់ងារទូទាត់ ក្រោយពីបានទទួលនូវពាក្យស្នើសុំ និង ពិនិត្យត្រឹមត្រូវតាមលក្ខខណ្ឌដែលតម្រូវដោយ **គ.ម.ក** ហើយនោះ នៅថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១០ គណៈកម្មការមូលបត្រកម្ពុជា បានចេញសេចក្តីជូនដំណឹងរបស់សាធារណជន អំពីការទទួលស្គាល់ពាក្យស្នើសុំនៃការទទួលស្គាល់ធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និង ភ្នាក់ងារទូទាត់។ បន្ទាប់មក ក៏បានធ្វើការវាយតម្លៃលើពាក្យស្នើសុំ និង ចុះវាយតម្លៃដល់ទីកន្លែងលើបុគ្គលដាក់ពាក្យស្នើសុំនីមួយៗ ទៅតាមលក្ខណៈវិនិច្ឆ័យរួចមក គណៈកម្មការមូលបត្រកម្ពុជាបានធ្វើការអនុម័តផ្តល់ការទទួលស្គាល់ធ្វើ

ជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រដល់ធនាគារពាណិជ្ជចំនួន ០៣ (បី) និង អនុម័តផ្តល់ការទទួលស្គាល់ធ្វើជាភ្នាក់ងារបញ្ជិកាមូលបត្រភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់-ងារ ទូទាត់ដល់ក្រុមហ៊ុន និងធនាគារចំនួន ០៣ (បី) គឺមាន:

១.ធនាគារ អេស៊ីលីដា ភីអិលស៊ី

២. ធនាគារ កាណាឌីយ៉ា អ.ក

៣. ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី ។

➢ ការផ្តល់ការអនុញ្ញាតដល់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ធ្វើជាប្រតិបត្តករទីផ្សារមូលបត្រប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និង ទូទាត់មូលបត្រ និង ប្រតិបត្តិកររក្សារទុកមូលបត្រ ចំនួន ០១ (មួយ) ។

**កថាខណ្ឌទី ៣ ការដាក់ឲ្យដំណើរការទីផ្សារមូលបត្រកម្ពុជា**

ស្របពេលដែលប្រទេសកម្ពុជា កំពុងតែមានភាពរីកចម្រើននូវវិស័យហិរញ្ញវត្ថុដែលគួរឲ្យមានការកត់សម្គាល់នោះ ដែលនៅទីបំផុតទីផ្សារមូលបត្រមួយស្ថិតក្នុងដំណាក់កាលចុងក្រោយ នៃការលេចរូបរាងឡើង ។ ដែលនេះសបញ្ជាក់ឲ្យឃើញថា ប្រទេសកម្ពុជាកំពុងឈានចូលដល់ ដំណាក់កាលថ្មីមួយនៃការវិវឌ្ឍវិស័យហិរញ្ញវត្ថុ ស្របតាម " **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០៦-២០១៥**" និង យុទ្ធសាស្ត្រចតុកោណដំនាក់កាលទី ២ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមចក្ខុវិស័យដឹកនាំជាប្រចាំ ប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

យោងតាមយុទ្ធសាស្ត្រទាំងពីរខាងលើនេះ ការបង្កើតទីផ្សារមូលបត្រមានសារៈសំខាន់ សម្រាប់ក្រុមហ៊ុននានា ក៏ដូចជាសម្រាប់សេដ្ឋកិច្ចជាតិទាំងមូល តាមរយៈការលើកកម្ពស់អភិបាលកិច្ចសាជីវកម្ម និង បង្កើតប្រសិទ្ធិភាពនៃការគ្រប់គ្រងក្រុមហ៊ុន ដោយធ្វើអោយមានយន្តការច្បាស់លាស់ក្នុងការគ្រប់គ្រងហានិភ័យ មានគណនេយ្យភាព និង តម្លាភាពក្នុងកិច្ចការអាជីវកម្ម និង ការប្រកាន់ខ្ជាប់នូវក្រមវិជ្ជាជីវៈច្បាស់លាស់ ដែលជាបុរេលក្ខខណ្ឌការទាក់ទាញទុនរយៈពេលវែងពីសាធារណជនទាំងនៅក្នុង និងក្រៅប្រទេស សម្រាប់ពង្រីកអាជីវកម្ម និង ពង្រីកលទ្ធភាពប្រកួតប្រជែងក្នុងទីផ្សារអន្តរជាតិ ព្រមទាំងផ្តល់នូវជម្រើសមួយទៀតដល់សាធារណជនក្នុងការសន្សំប្រាក់ និងការវិនិយោគ។ គួររំលឹកផងដែរថា ដើម្បីឈានមកដល់កាបង្កើតក្រុមហ៊ុនចំរុះនេះ ចំណុចចាប់ផ្តើតបានកើតឡើងតាមរយៈការចុះអនុស្សារណៈយោគយល់គ្នារវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា និងឯកឧត្តម **ដុក ស៊ូ ហាន់** ( Duck-Soo Han) ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ និងសេដ្ឋកិច្ចកូរ៉េនៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០៦ នៅទីក្រុង Hyderabad ប្រទេសឥណ្ឌា ក្នុងឱកាសប្រជុំរដ្ឋ-

មន្ត្រីហិរញ្ញវត្ថុ នៃអាស៊ាន+៣ទល់គ្នានឹងការប្រជុំ ADB ប្រចាំឆ្នាំ ។ បន្ទាប់មក នៅថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០៦ ការចុះអនុស្សារណៈយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការ ក្នុងការបង្កើតទីផ្សារមូលបត្រ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ និងនៅថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៨ ការចុះអនុស្សារណៈយោគយល់គ្នា ស្តីពីការសម្រេចជ្រើសរើសយកក្រុមហ៊ុនផ្សារមូលបត្រកូរ៉េជាដៃគូយុទ្ធសាស្ត្រតែមួយគត់នៅក្នុងគម្រោងបង្កើតទីផ្សារមូលបត្រ មុននឹងឈានដល់ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការបង្កើតក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ( Joint-Venture Agreement on the Establishment of the Cambodia Securities Exchange Co., Ltd) នៅថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៩ ។ ហើយការបង្កើតក្រុមហ៊ុនចំរុះនេះឡើងត្រូវបានទទួលយកចិត្តទុកដាក់ខ្ពស់ ពីប្រមុខដឹកនាំនៃប្រទេសទាំងពីរ កម្ពុជា និង កូរ៉េ ។ ជាមួយគ្នានេះ រដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ក៏បានផ្តល់ជំនួយបច្ចេកទេស តាមរយៈភ្នាក់ងារអន្តរជាតិសម្រាប់ការអភិវឌ្ឍន៍កូរ៉េ (KOICA) សម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញមូលបត្រ ដល់មន្ត្រីជំនាញកម្ពុជា ពិសេសមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង គណៈកម្មការមូលបត្រកម្ពុជា ព្រមទាំងក្រុមហ៊ុនរដ្ឋ ដែលកំពុងត្រៀមខ្លួនបំពេញនីតិវិធីនៃការបោះផ្សាយលក់មូលបត្រនាពេលខ្លីខាងមុខ ។

បន្ទាប់មក នាថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១១ ក្រុមហ៊ុនទីផ្សារមូលបត្រ ត្រូវបានសម្ពោធដាក់ឲ្យដំណើរការជាផ្លូវការ ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ឧបនាយករដ្ឋមន្ត្រី **គាត់ ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធានគណៈកម្មការមូលបត្រកម្ពុជា និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។ ម្យ៉ាងទៀត ការលេចរូបរាងឡើងនូវក្រុមហ៊ុនទីផ្សារមូលបត្រនេះ គឺស្តែងចេញពីសមិទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ (KRX) ក្រុមហ៊ុនផ្សារមូលបត្រ (CSX ) ក្រុមហ៊ុនមូលបត្រ ក៏ដូចជាស្ថាប័នពាក់ព័ន្ធដទៃទៀត រួមទាំងវិស័យឯកជន ប្រទេសជាមិត្ត និងដៃគូអភិវឌ្ឍន៍ ក្នុងការចូលរួមយ៉ាងសកម្មធ្វើឲ្យសម្រេចបាននូវការត្រៀមលក្ខណៈជាស្រេចទាំងផ្នែកគតិយុត្ត ធនធានមនុស្ស និងបច្ចេកទេស។ ទីផ្សារមូលបត្រដែលមានដំណើរការពេញលេញមានន័យថា ក្រុមហ៊ុនដែលបោះផ្សាយលក់មូលបត្រ ជាសាធារណៈ បានធ្វើការលក់មូលបត្ររបស់ខ្លួនក្នុងទីផ្សារដំបូង (Primary Market) ឬហៅថា IPO (Initial Public Offering) និង បន្ទាប់មកមូលបត្រទាំងនោះត្រូវបានយកទៅចុះបញ្ជីសម្រាប់ការជួញដូរ ឬ ទិញលក់បន្ត នៅក្នុងទីផ្សារបន្ទាប់ (Secondary Market) នៅក្នុងប្រព័ន្ធជួញដូរ

របស់ក្រុមហ៊ុនផ្សារមូលបត្រ[៣]។

## ផ្នែកទី ៤ទិសដៅការងាររបស់ គណៈកម្មការមូលបត្រកម្ពុជា

### កថាខណ្ឌទី ១ ការបន្តការកសាងហេដ្ឋារចនាសម្ព័ន្ធគតិយុត្ត

ក្រៅពីមានផែនការ និងសកម្មភាពនៅក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធគតិយុត្តនាពេលបច្ចុប្បន្ន ហើយនោះ **គ.ម.ក** ក៏មានទិសដៅនាពេលអនាគតក្នុងការធ្វើអោយមានភាពរឹងមាំ ពេញលេញ គ្រប់ជ្រុងជ្រោយនៃបទដ្ឋានគតិយុត្ត និងអាចគ្រប់គ្រងទីផ្សារមូលបត្របានប្រកបដោយប្រសិទ្ធភាព តម្លាភាព ភាពត្រឹមត្រូវ យុត្តិធម៌ និង សណ្តាប់ធ្នាប់ ដោយត្រូវបន្តនូវសកម្មភាពរបស់ខ្លួនបន្តទៀតទៅលើការកសាងបទដ្ឋានគតិយុត្តថ្មីៗបន្ថែមទៀត ដើម្បីអាចឆ្លើយតបទៅនឹងតម្រូវការ និងស្ថានភាពជាក់ស្តែងនៃការវិវត្តន៍របស់ទីផ្សារមូលបត្រនៅកម្ពុជា ។ មូលហេតុដូច្នេះហើយ **គ.ម.ក** នាពេលបច្ចុប្បន្នបានកំពុងបន្តការសិក្សាស្រាវជ្រាវ និងរៀបចំនូវបទប្បញ្ញត្តិគាំទ្រដែលចាំបាច់ ដែលនៅមានការខ្វះចន្លោះ ទាក់ទងទៅនឹងការស៊ើបអង្កេតអំពើល្មើស និងបទល្មើសនៅក្នុងវិស័យមូលបត្រ ការដោះស្រាយវិវាទនៅក្នុងវិស័យមូលបត្រ ទណ្ឌកម្មរដ្ឋបាល និង ការផាកពិន័យអន្តរការណ៍ ដែលធ្វើឲ្យមានភាពរឹងមាំផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមូលបត្រ ការទទួលស្គាល់ក្រុមហ៊ុន ឬ បុគ្គលនានាដែលធ្វើអាជីវកម្ម ឬផ្តល់សេវាកម្មពាក់ព័ន្ធនឹងវិស័យមូលបត្រ ។

ការគ្រប់គ្រងទីផ្សារមូលបត្រប្រកបដោយប្រសិទ្ធិភាពខ្ពស់ និង ធានាបាននូវការអភិវឌ្ឍន៍ទៅមុខបានជាដរាបនោះ គឺពឹងផ្អែកទៅលើកត្តារឹងមាំនៃបទដ្ឋានគតិយុត្ត ផ្សារភ្ជាប់នឹងបទដ្ឋានគតិយុត្តផ្សេងៗទៀត សម្រាប់គ្រប់គ្រង និងដាក់ឲ្យអនុវត្ត ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ ទីផ្សារមូលបត្របានយ៉ាងប្រសើរ ។ម្យ៉ាងវិញទៀត របត់នយោបាយ ស្ថានភាពសេដ្ឋកិច្ច និងបរិការណ៍សង្គមមានការប្រែប្រួលជាប្រចាំ ពីមួយថ្ងៃទៅមួយថ្ងៃ រីឯទីផ្សារមូលបត្រ ក៏មានដំណើរការវិវត្តន៍ទៅមុខជាបន្តបន្ទាប់ផងដែរ ជាពិសេសការរីកចម្រើននៃបច្ចេកវិទ្យា ដែលធ្វើអោយមានប្រភេទឧបករណ៍ ហិរញ្ញវត្ថុថ្មីៗ ការលេចចេញនូវបទល្មើស ឬអំពើល្មើសប្លែកៗ នៅក្នុងទីផ្សារមូលបត្រ ដូច្នេះគឺទាមទារឲ្យ **គ.ម.ក** ត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការរៀបចំបទប្បញ្ញត្តិគតិយុត្តថ្មីៗ ដើម្បីដើរឲ្យទាន់ទៅនឹងស្ថានភាពជាក់ស្តែង ក្នុងការគ្រប់គ្រងទៅលើសកម្មភាពធុរកិច្ច ឬឧបករណ៍ហិរញ្ញវត្ថុ ឬបទល្មើស ដែលទើបតែកើតឡើងក្នុងបរិបទថ្មីនេះ។

### កថាខណ្ឌទី ២ ការពង្រឹងសមត្ថភាពស្ថាប័ន និងមន្ត្រីជំនាញរបស់ គ.ម.ក

[៣] សន្ទរកថារបស់ឧបនាយករដ្ឋមន្ត្រី **គាត ឈន់** ក្នុងពិធីសម្ពោធដាក់ឲ្យដំណើរការ ក្រុមហ៊ុនទីផ្សារមូលបត្រ

ទន្ទឹមនឹងមានការរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ ចំពោះវិស័យមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា **គ.ម.ក** ដែលជាស្ថាប័នត្រួតពិនិត្យលើវិស័យនេះ ក៏មានការអភិវឌ្ឍចំពោះស្ថាប័នរបស់ខ្លួនឲ្យមានការីកចម្រើនផងដែរ ។ ក្នុងន័យនេះមានន័យថា **គ.ម.ក** ត្រូវតែពង្រឹងសមត្ថភាពស្ថាប័ន ក៏ដូចជាមន្ត្រីដែលបម្រើការងារនៅក្នុងស្ថាប័នឲ្យមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីអនុវត្តមុខងារ និងតួនាទីរបស់ខ្លួនអោយស្របទៅតាមច្បាប់ បទដ្ឋានគតិយុត្តជាធរមាន ប្រកបដោយតម្លាភាព ការទទួលខុសត្រូវខ្ពស់ និងអភិបាលកិច្ចល្អ ។ ជាមួយគ្នានេះផងដែ **គ.ម.ក** ក៏មានគម្រោង និងជ្រើសរើសមន្ត្រីបន្ថែម ដើម្បីឆ្លើយតបទៅនឹងទំហំការងារ និងការអភិវឌ្ឍរបស់ទីផ្សារមូលបត្រនៅកម្ពុជា ។ ម្យ៉ាងវិញទៀត ក្នុងការពង្រឹងសមត្ថភាពរបស់មន្ត្រី **គ.ម.ក** នោះ ស្ថាប័ននេះនៅតែបន្តបញ្ជូនមន្ត្រីរបស់ខ្លួនដើម្បីចូលរួមនៅក្នុងសិក្ខាសាលា វគ្គបណ្តុះបណ្តាលផ្សេងៗ ទាំងក្នុង និងក្រៅប្រទេស ក្នុងការទទួលបាននូវចំណេះដឹង និងបទពិសោធន៍បន្ថែមទៀត ដើម្បីអនុវត្តការងាររបស់ខ្លួនឲ្យមានប្រសិទ្ធិភាពខ្ពស់ ។

**កថាខណ្ឌទី ៣ ការពង្រឹងការអនុវត្តច្បាប់ និងនីតិកម្ម**

ការពង្រឹងការអនុវត្តច្បាប់ និងនីតិកម្ម គឺជាបេសកកម្មជានិរន្តរ៍របស់ **គ.ម.ក** ដែលជានីយ័តករមូលបត្រ ។ ការពង្រឹងការអនុវត្តច្បាប់នេះ ស្តែងឡើងតាមរយៈយន្តការជាច្រើន ដែលក្នុងនោះរួមមានការឃ្លាំមើលការជួញដូរជាប្រចាំនៅក្នុងទីផ្សារមូលបត្រ ការពិនិត្យលើឯកសារ និងចុះត្រួតពិនិត្យដល់ទីកន្លែងចំពោះការធ្វើអាជីវកម្មរបស់ក្រុមហ៊ុនមូលបត្រ និងចូលរួមក្នុងទីផ្សារមូលបត្រនានា ថែមទាំងធ្វើការទទួលពាក្យបណ្តឹងពាក់ព័ន្ធនឹងបទល្មើស អំពើល្មើសពាក់ព័ន្ធនឹងវិស័យមូលបត្រ ព្រមទាំងធ្វើការស៊ើបអង្កេត និង រៀបចំបញ្ជូនសំណុំរឿងទៅតុលាការមានសមត្ថកិច្ច ។

ជាមួយគ្នានេះ មន្ត្រីជំនាញរបស់ **គ.ម.ក** បានកំពុងបន្តយកចិត្តទុកដាក់យ៉ាងខ្លាំង ទៅលើករណីយកិច្ចពង្រឹងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងមូលបត្រ ដោយធ្វើសហប្រតិបត្តការយ៉ាងសកម្មទាំងក្នុង និងជាមួយក្រសួងស្ថាប័ននានា ដើម្បីបង្ការស្វែងរក និងបង្ក្រាបការប្រព្រឹត្តល្មើសច្បាប់ ការប្រព្រឹត្តខុសលក្ខខណ្ឌនៃការអនុញ្ញាត អាជ្ញាប័ណ្ណ ការទទួលស្គាល់ និងសកម្មភាពផ្ទុយច្បាប់របស់បុគ្គលទាំងឡាយ ដែលចូលរួមក្នុងទីផ្សារមូលបត្រ ។

**កថាខណ្ឌទី ៤ ការរៀបចំយន្តការដោះស្រាយវិវាទនៅក្នុងវិស័យមូលបត្រ**

ដោយសារតែវិស័យមូលបត្រ គឺជាវិស័យថ្មី និងមានលក្ខណៈស្មុគស្មាញ ដូច្នេះហើយបញ្ហា និងវិវាទដែលកើតឡើងក្នុងវិស័យនេះក៏កើតឡើងមានច្រើនផងដែរ ករណីនេះត្រូវអោយមាននូវដំណោះស្រាយមួយប្រកបដោយប្រសិទ្ធិភាព យុត្តិធម៌ និងជាពិសេសអាចធានាបាននូវឆាប់រហ័ស និងចំណាយសោហ៊ុយតិច ។ ទន្ទឹមនឹងបរិបទនាពេលបច្ចុប្បន្នេះ **គ.ម.ក** ក៏បានកំពុងរៀបចំសេចក្តីព្រាងប្រកាស

ស្តីពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នៅក្នុងវិស័យមូលបត្រ ដែលសេចក្តីព្រាងប្រកាសនេះ បញ្ញត្តិ យន្តការ នីតិវិធី និងបញ្ហាសំខាន់ៗ ផ្សេងៗទៀតពាក់ព័ន្ធនឹងការដោះស្រាយវិវាទ ដែលកើតមានឡើងនៅក្នុងទីផ្សារមូលបត្រ ។ មន្ត្រីជំនាញរបស់ **គ.ម.ក** ការធ្វើការសិក្សាស្រាវជ្រាវស៊ីជម្រៅទៅលើបណ្តាវិធាននានាពាក់ព័ន្ធទៅនឹងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និង ពិសេសពិនិត្យមើលលម្អិតទៅលើនីតិវិធី ព្រមទាំងការរៀបចំដំណើរការដោះស្រាយវិវាទរបស់និយ័តករមូលបត្របរទេស ជាអាទិ៍ ប្រទេសថៃ វៀតណាម ម៉ាឡេស៊ី សឹង្ហបុរី សាធារណរដ្ឋកូរ៉េ បារាំង សហរដ្ឋអាមេរិក អូស្ត្រាលី ។ល។ ដើម្បីទទួលបាននូវគំនិត និងបទពិសោធន៍ ក៏ដូចជាវិធីសាស្ត្រពិសេសដែលធានាបាននូវការដោះស្រាយវិវាទប្រកបដោយភាពជោគជ័យ ស្វែងរកនូវដំណោះស្រាយឈ្នះឈ្នះ សម្រាប់ភាគីវិវាទភាពរហ័ស និងចំណាយតិច ។

**កថាខណ្ឌទី ៥ ការបណ្តុះបណ្តាល ការផ្សព្វផ្សាយ និង ទំនាក់ទំនងអន្តរជាតិ**

ក្នុងទិសដៅអភិវឌ្ឍន៍ធនធានមនុស្ស និងពង្រីកនូវការយល់ដឹងរបស់បុគ្គលដែលបម្រើការងារនៅក្នុងវិស័យឯកជនពាក់ព័ន្ធនឹងវិស័យមូលបត្រ ក៏ដូចជាសាធារណជនអំពីបរិការណ៍នៃទីផ្សារមូលបត្រពិភព-លោក និងបទប្បញ្ញត្តិជាធរមានថ្មីៗ ពាក់ព័ន្ធនឹងវិស័យមូលបត្រនៅកម្ពុជា ការបណ្តុះបណ្តាល គឺជាការងារអាទិភាពសម្រាប់ **គ.ម.ក** ។ ក្នុងន័យនេះ **គ.ម.ក** បាននឹងកំពុងរៀបចំនូវផែនការបណ្តុះបណ្តាលមួយឲ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ ទាំងសម្រាប់ក្រុមហ៊ុន វិនិយោគិន និងសារណៈជនទូទៅ ។ ដើម្បីធានាបាននូវទីផ្សារមូលបត្រប្រកបដោយប្រសិទ្ធភាព និងមានសណ្តាប់ធ្នាប់ ព្រមទាំងដើម្បីឲ្យអនុលោមទៅតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងមូលបត្រ ដែលបានអនុម័តនាពេលកន្លងមកដែលមានចែងពាក់ព័ន្ធនឹងគុណវុឌ្ឍន៍របស់រូបវន្តបុគ្គល ដែលបម្រើការងារក្នុងវិស័យមូលបត្រ បន្ទាប់ពីបានទទួលអាជ្ញាប័ណ្ណ ការអនុញ្ញាត និងការទទួលស្គាល់ **គ.ម.ក** បានរៀបចំនូវផែនការបណ្តុះបណ្តាល និងការប្រឡងយកវិញ្ញាបនប័ត្រជំនាញមូលបត្រ សម្រាប់ទទួលស្គាល់រូបវន្តបុគ្គលក្នុងវិស័យមូលបត្រ ។

ម្យ៉ាងទៀត ការផ្សព្វផ្សាយ គឺជាយានមួយ ដែលជួយឲ្យសាធារណជនជាតិ និងអន្តរជាតិមានការយល់ដឹងពីវិស័យមូលបត្រនៅកម្ពុជា ក៏ដូចជាបង្កើននូវការទុកចិត្តរបស់សាធារណជនជាតិ និងអន្តរជាតិចំពោះទីផ្សារមូលបត្រនៅកម្ពុជា **គ.ម.ក** នៅតែបន្តធ្វើការផ្សព្វផ្សាយអំពីច្បាប់ បទប្បញ្ញត្តិជាធរមានដែលត្រូវបានអនុម័តជាបន្តបន្ទាប់។

ដើម្បីធានាបាននូវប្រសិទ្ធិភាពនៃការផ្សព្វផ្សាយ **គ.ម.ក** តែងតែចាត់បញ្ជូនមន្ត្រីរបស់ខ្លួនឲ្យចូលរួមធ្វើជាវាគ្មិននៅតាមប៉ុស្តិ៍វិទ្យុ ទូរទស្សន៍ជាតិ និង អន្តរជាតិ និងសិក្ខាសិលានានាដែលរៀនចំឡើង

ដោយស្ថាប័នពាក់ព័ន្ធ ។ មួយវិញទៀត **គ.ម.ក** នៅតែបន្តផ្តល់ការអនុញ្ញាតដល់សារព័ត៌មានជាតិ និង អន្តរជាតិឲ្យចូលជួបសម្ភាសន៍ផ្ទាល់ជាមួយ **គ.ម.ក** ដើម្បីបំភ្លឺនូវរាល់ចម្ងល់ទាំងឡាយ ក៏ដូចជាដើម្បីជាការបកស្រាយឲ្យសាធារណជនបានយល់ច្បាស់ពីវិស័យមូលបត្រនៅកម្ពុជា ថែមទាំងបន្តបោះ-ផ្សាយនូវកម្រងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រ ។ ព្រមជាមួយគ្នានេះផងដែរ **គ.ម.ក** តែងតែធ្វើបច្ចុប្បន្នកម្មនូវព័ត៌មានពាក់ព័ន្ធនឹងវិស័យមូលបត្រនៅកម្ពុជា ហើយ **គ.ម.ក** ក៏កំពុងធ្វើបច្ចុប្បន្នកម្មគេហទំព័ររបស់ខ្លួន ដើម្បីផ្តល់នូវភាពងាយស្រួលដល់សាធារណជនក្នុងការទទួលបាននូវព័ត៌មាន ។ ក្រៅពីការបណ្តុះបណ្តាលដែលរៀបចំដោយ **គ.ម.ក** ផ្ទាល់ **គ.ម.ក** ក៏មានកិច្ចសហប្រតិបត្តការជាមួយក្រុមហ៊ុនមូលបត្រ ឬបន្ទាប់ពីបានទទួលនូវផ្លែផ្កា ក្នុងការចូលរួមការអភិវឌ្ឍវិស័យមូលបត្រនៅកម្ពុជា ពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការល្អជាមួយដៃគូអន្តរជាតិ តាមរយៈការចុះកិច្ចព្រមព្រៀងជាមួយដៃគូពាក់ព័ន្ធផ្សេងៗ **គ.ម.ក** បន្តយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការពង្រឹង និងបង្កើតនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការអន្តរជាតិនេះ។ ដើម្បីសម្រេចឲ្យបាននូវទិសដៅនេះ **គ.ម.ក** និង រីតចំណងការងារ ទំនាក់ទំនងអន្តរជាតិ និងកិច្ចសហប្រតិបត្តិការជាមួយនិយ័តករមូលបត្រក្នុងតំបន់ និងពិភពលោក ។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានបកស្រាយយ៉ាងក្បោះក្បាយអំពី **ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា** រួចមក យើងឃើញថាស្ថាប័ននេះ មាននូវបេសកកម្ម បង្កើត និងរក្សាឲ្យមានទំនុកចិត្តពីអ្នកវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការការពារសិទ្ធិស្របច្បាប់ របស់អ្នកវិនិយោគ និងធានាឲ្យមានការបោះផ្សាយ និងការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវ។ លើកកម្ពស់ការគ្រប់គ្រងទីផ្សារមូលបត្រឲ្យមានប្រសិទ្ធភាព និងជំរុញការអភិវឌ្ឍទីផ្សារនេះឲ្យមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយ។ ជំរុញឲ្យមានភាពសម្បូរបែបនៃឧបករណ៍សញ្ញ័យ តាមរយៈការទិញមូលបត្រ និង ឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត។ ជំរុញឲ្យមានការធ្វើវិនិយោគទុនពីបរទេស និងការចូលរួមក្នុងទីផ្សារមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ជួយសម្រួលដល់ការធ្វើឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ហេតុនេះយើងអាចសន្និដ្ឋានបានថា ចំពោះការបង្កើតឡើងនូវស្ថាប័ននេះកើតឡើងនៅក្នុងកម្ពុជានេះឡើង ដើម្បីធានាឲ្យបាននូវការគ្រប់គ្រងលើវិស័យក្នុងការចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ តាមរយៈការគាំពារចំពោះក្រុមហ៊ុមូលបត្រ និងអ្នកវិនិយោគិន ដោយបង្កើតនូវច្បាប់ និងបទដ្ឋាគតិ-យុត្ត ដើម្បីទប់ស្កាត់ បង្ក្រាប នូវបទល្មើសដែលទាក់ទងទៅនឹងវិស័យមូលបត្រនៅកម្ពុជា ដែលជាវិស័យដ៏ថ្មីស្រឡាងសម្រាប់កម្ពុជា ។ ម្យ៉ាងទៀត ទោះបីជាស្ថាប័ននេះទើបតែបង្កើតឡើងនៅក្នុងរយៈពេលខ្លីយ៉ាងណាក៏ដោយ តែស្ថាប័នមួយនេះបាននឹងដើរតួនាទីយ៉ាងសំខាន់ ក្នុងនាមជាអាជ្ញាធរគ្រប់គ្រប់លើវិស័យមូលបត្រនៅកម្ពុជា ។ យ៉ាងណាមិញ នៅក្នុងការប្រតិបត្តិការនាពេលកន្លងមក យើងសង្កេតឃើញថាស្ថាប័នមួយនេះ ទទួលបាននូវការគាំទ្រយ៉ាងខ្លាំងពីសំណាក់អ្នកវិនិយោគិនជាតិ និងអន្តរជាតិ ជាងនេះទៅទៀតថែមទាំមានការគាំទ្រពីសំណាក់ប្រជាពលរដ្ឋ នៃព្រះរាជណាចក្រកម្ពុជាផងដែរ ។

មិនត្រឹមតែប៉ុណ្ណោះទេ ចំពោះការបង្កើតគណៈកម្មការមូលបត្រកម្ពុជានេះឡើង ក៏ជាការបង្ហាញឲ្យពិភពលោកឃើញថា រាជរដ្ឋាភិបាលកម្ពុជា មានឆន្ទៈ និងបានតាំងចិត្តយ៉ាងមុតមាំដាក់ចេញនូវផែនការចក្ខុវិស័យអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០៦ -២០១៥ និង បានធ្វើបច្ចុប្បន្នភាពទៅជាផែនការចក្ខុវិស័យអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ ២០១១- ២០២០ ដើម្បីឈានឆ្ពោះទៅរកការអភិវឌ្ឍន៍ប្រទេស ប្រកបដោយចីរភាព និងប្រសិទ្ធិផ្តល់នូវសមិទ្ធផលខ្ពស់ ។

ទន្ទឹមនឹងនេះដែរ ដើម្បីឆ្លើយតបទៅនឹងការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល អ្នកវិនិយោគិនជាតិ និងអន្តរជាតិ ព្រមទាំងប្រជាពលរដ្ឋផងនោះ គណៈកម្មការមូលបត្រកម្ពុជាកំពុងតែអនុត្តយ៉ាង

ខ្ជាប់ខ្ជួន ដោយខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត នៅក្នុងការពង្រឹងបទដ្ឋានគតិយុត្តិ នានាដែលទាក់ទងទៅនឹងវិស័យមូលបត្រ ដើម្បីធ្វើអោយមានទំនុកចិត្តពីសំណាក់អ្នកវិនិយោគិនជាតិ និងអន្តរជាតិថែមទាំបាននឹងកំពុងធ្វើការផ្សព្វផ្សាយព័ត៌មាននានា ដែលជាចលករមួយនៅក្នុងការធ្វើឲ្យវិស័យមូលបត្រនៅកម្ពុជាមានការរីកចំរើននាពេលអនាគត ។

## អនុសាសន៍

ដើម្បីឲ្យគណៈកម្មការមូលបត្រកម្ពុជា មានដំណើរការ និងការប្រព្រឹត្តិទៅបានល្អនៅក្នុងការអនុវត្តនូវសម្តកិច្ច ជាអាជ្ញាធរលើវិស័យមូលបត្រ ជានិយ័តករមូលបត្រ គប្បីគួតែះ

១. ពង្រឹង ពង្រីកច្បាប់ មានន័យថា ច្បាប់ដែលទាក់ទងនៅនឹងមូលបត្រនៅកម្ពុជា មានកម្រិតតិចតួចនៅឡើយ បើប្រៀបធៀបនឹងបណ្តាប្រទេសដ៏ទៃទៀត ហេតុនេះរាជរដ្ឋាភិបាល ក៏ដូចជាសភាជាតិកម្ពុជា ត្រូវខិតខំបង្កើនបង្កើតនូវអត្ថបទគតិយុត្តនានា ដើម្បីឲ្យការអនុវត្តប្រព្រឹត្តទៅបានយ៉ាងរលូន ស្របទៅតាមច្បាប់ ។ ចំណែកឯការពង្រឹងច្បាប់ មានន័យថា ពេលមានអត្ថបទច្បាប់នានាហើយ ត្រូវពង្រឹងការអនុវត្តឲ្យបានល្អប្រសើរ ទើបច្បាប់ដែលបានអនុម័តហើយនោះមានប្រសិទ្ធិភាព ។

២.ពង្រឹងធនធានមនុស្ស មានន័យថា មន្ត្រីទាំងក្របខណ្ឌមុខងាសារធារណៈ ទាំងមន្ត្រីលក្ខន្តិកៈបំរើការងារនៅក្នុងគណៈកម្មការមូលបត្រកម្ពុជា ត្រូវតែមានជំនាញ និងបទពិសោធន៍យ៉ាងច្បាស់លាស់តម្រូវឲ្យមានការបណ្តុះបណ្តាលតាមជំនាញ តាមផ្នែក ពិសេសធ្វើការផ្លាស់ប្តូរបទពិសោធន៍ពីបណ្តាប្រទេសនានាលើពិភពលោក ។

៣.ផ្តល់នូវប្រាក់បៀវត្សឲ្យបានគ្រប់គ្រាន់ដល់មន្ត្រីនៅក្នុងស្ថាប័ន ដើម្បីធានាជីវភាពរស់នៅសមរម្យ ដើម្បីជៀសវៀងមន្ត្រីនៃស្ថាប័ននេះយកពេលបំរើការងារនៅក្នុងស្ថាប័នទៅបំរើការងារនៅកន្លែងការងារផ្សេង ដើម្បីរកប្រាក់កម្រៃមកផ្គត់ផ្គង់ជីវភាពរស់នៅ ដែលធ្វើអោយជះឥទ្ធិពលទៅលើប្រសិទ្ធិភាពការងារនៅក្នុងស្ថាប័នមានការធ្លាក់ចុះ ។

៤. ជម្រុញឲ្យមានការបង្កើតវគ្គបណ្តុះបណ្តាលអោយបានច្រើន នៅតាមបណ្តាលខេត្ត រាជធានីផ្សេងៗ ដើម្បីផ្សព្វផ្សាយអំពីវិស័យមូលបត្រនៅកម្ពុជា ដែលជាវិស័យថ្មីស្រឡាងនេះ ។

៥. ពង្រីកប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអោយមានលក្ខណៈធំទូលាយ តាមរយៈទូរទស្សន៍ ដោយអញ្ជើញវាគ្មិនដែលមានបទពិសោធន៍ខាងវិស័យមូលបត្រ ធ្វើការបកស្រាយអំពីគុណសម្បត្តិរបស់វិស័យនេះ ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ក៏ដូចជាធ្វើការពន្យល់អំពីប្រភេទនៃ មូលបត្រដែលអនុញ្ញាតឲ្យធ្វើការបោះផ្សាយជាសាធារណៈ និងបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធក្នុងវិស័យនេះ និងជាពិសេសត្រូវចាត់មន្ត្រីដែលមានជំនាញ ដើម្បីចុះទៅធ្វើតាមបណ្តាលខេត្ត-រាជធានី ដើម្បីបង្កើតជាសិក្ខាសាលាអោយបានច្រើន ទាក់ទងទៅនឹងប្រធានបទមូលបត្រ ។

៦. រាជរដ្ឋាភិបាល ត្រូវតាមដាន និងយកចិត្តទុកដាក់ខ្ពស់បំផុត ក្នុងការជំរុញអោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាសេនាធិការ និង ជាប្រធាននៃគណៈកម្មការមូលបត្រនេះ ដោយ

ត្រូវផ្តល់អនុសាសន៍ល្អៗដល់អគ្គនាយកនៃ **គ.ម.ក** ក្នុងនាមជាប្រធាននៃស្ថាប័ននេះ ដើម្បីធ្វើអោយដំណើការរបស់ស្ថាប័ននេះមានភាពរលូន ។

# ឯកសារយោង

- រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣
- ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ឆ្នាំ ១៩៩៩
- ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ ២០០៥
- ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧
- ច្បាប់ស្តីពីក្ស័យធន ឆ្នាំ ២០០៧
- ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៩
- ច្បាប់ស្តីពីលក្ខន្តិៈមន្ត្រីរាជការស៊ីវិល ឆ្នាំ ១៩៩៤
- ច្បាប់ស្តីពីមូលបត្ររដ្ឋ ឆ្នាំ ២០០៦
- ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ឆ្នាំ ២០០៧
- ព្រះរាជក្រឹត្យនស/រកត/ ០៧០៨/៩២៨ ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៨
- អនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈកម្មការមូលបត្រកម្ពុជា
- អនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៩ ស្តីពីការអនុវត្តច្បាប់បោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- អនុក្រឹត្យលេខ ៩២៣ អនក្រ.តត ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០៨៨ ស្តីពីការតែងតាំងមន្ត្រីរាជការ
- ប្រកាសលេខ ០០២ គមក.ប្រ.ក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០០៩ ស្តីពីការដាក់ឲ្យ អនុវត្តបទបញ្ជាផ្ទៃក្នុងសម្រាប់ការគ្រប់គ្រងមន្ត្រីរបស់គណៈកម្មការមូលបត្រកម្ពុជា
- ប្រកាសលេខ ០០៣ គមក.ប្រក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៩ ស្តីពីលក្ខន្តិកៈនៃមន្ត្រីរបស់គណៈកម្មការមូលបត្រកម្ពុជា
- ប្រកាសលេខ ០០៧ គមក. ប្រ.ក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃគណៈកម្មការមូលបត្រកម្ពុជា

- ប្រកាសលេខ ០០៨ គមក. ប្រ.ក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានកិច្ចការគតិយុត្ត នៃគណៈកម្មការមូលបត្រកម្ពុជា
- ប្រកាសលេខ ០១២ គមក. ប្រ.ក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ នៃគណៈកម្មការមូលបត្រកម្ពុជា
- ប្រកាសលេខ ០១៣ គមក. ប្រ.ក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ នៃគណៈកម្មការមូលបត្រកម្ពុជា
- ប្រកាសលេខ ០១៤ គមក. ប្រ.ក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ
- ប្រកាសលេខ ០១៥ គមក. ប្រ.ក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នៃគណៈកម្មការមូល បត្រកម្ពុជា
- ប្រកាសលេខ ០១៦ គមក. ប្រ.ក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុង នៃគណៈកម្មការមូល បត្រកម្ពុជា
- យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៣ ឆ្នាំ ២០១៣
- សន្ទានុក្រម ប្រើនៅក្នុងច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- https://en.wikipedia.org/wiki/Stock_exchange
- https://en.wikipedia.org/wiki/U.S._Securities_and_Exchange_Commission
- http://www.secc.gov.kh/khmer/